សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université royale de droit et des sciences économiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការបែងចែកមត៌ក

សរសេរសារណាចាប់ពីថ្ងៃទី ២៧ ខែ មេសា ដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **សាន គឹមប្រណី**

សាស្ត្រាចារ្យណែនាំ
**លោកគ្រូ ហេង មូរ៉ា**

ថ្នាក់បរិញ្ញាបត្រ**នីតិសាស្ត្រ**
ជំនាន់ទី **២១**

ឆ្នាំចូលសិក្សា **២០១៧**
ឆ្នាំសរសេរបាយការណ៍ **២០២១**

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំសូមសម្តែង នូវការគោរពនិងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ លោកឪពុក អ្នកម្តាយដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចរហូតដល់ពេលនេះ ដោយក្តី មេត្តា ករុណា មុទិតា និងឧបេក្ខាជាអនេកប្បការបំផុត ចំពោះ កូនដោយមិនគិតអំពីឧបសគ្គអ្វីទាំងអស់ចំពោះខ្លួនឡើយ ដែលលោកទាំងពីរបានធ្វើពលិកម្មគ្រប់យ៉ាងសម្រាប់ការសិក្សារបស់កូនទទួលបាននូវចំណេះដឹងដ៏ថ្លៃថ្លា ។

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងខ្ពង់ខ្ពស់ចំពោះ ឯកឧត្តមសាកលវិទ្យាធិការ និង សាកលវិទ្យាធិការរង ព្រមទាំងសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រ សេដ្ឋកិច្ច ដែលបាន លះបង់អស់ពីសមត្ថភាព កម្លាំងកាយ ទាំងកម្លាំងកាយ កម្លាំងចិត្តនិងកម្លាំងប្រាជ្ញា និងពេលវេលាដ៏មានតម្លៃ ក្នុងគោលបំណងដើម្បីអប់រំទូន្មាន ដឹកនាំបង្ហាត់ដល់នាងខ្ញុំ។ យើងខ្ញុំបានទទួលយកចំណេះដឹងនេះរហូតដល់ អាចបញ្ចប់ការសិក្សាដោយជោគជ័យ ដោយសារតែគុណូបការៈរបស់លោកនេះហើយ។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណ កោតសរសើរ និងប្រសិទ្ធិពរជ័យជូនដល់ចំពោះ លោក សាស្ត្រាចារ្យ **ហេខ មូរ៉ា** ដែលជាសាស្ត្រាចារ្យណែនាំ។ លោកគ្រូបានចំណាយពេលវេលាជាច្រើន រួមទាំង លះបង់ញើសឈាម និងកម្លាំងចិត្ត ដើម្បីជួយណែនាំផ្តល់នូវដំបូន្មាន និងតម្រង់ទិសយើងខ្ញុំរហូតដល់សារណា នេះទទួលបានបញ្ចប់ដោយជោគជ័យ។

ជាទីបញ្ចប់ យើងខ្ញុំ សូមប្រសិទ្ធិពរជ័យ សិរី មង្គល វិបុលសុខគ្រប់ប្រការចូលកើតមានដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តអ្នកអាន ឲ្យជួបប្រទះ នូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## **អារម្ភកថា**

មនុស្សគ្រប់រូបតែងមានចម្ងល់ថាក់តមកដើម្បីអ្វី? សំនួរនេះ គឺពុំមានចម្លើយល្អឥតខ្ចោះទេ។ ប៉ុន្តែមនុស្សគ្រប់រូបនៅតែព្យាយាមរស់ពីមួយថ្ងៃទៅមួយថ្ងៃ ហើយក៏បន្សល់ទុកមត៌ក និងកាតព្វកិច្ចដល់កូនចៅ នៅពេលដែលបានទទួលមរណភាព។ ទំនាស់ក៏អាចកើតមានបន្តបន្ទាប់ នៅដំណាក់កាលបែងចែកមត៌ក។

ក្នុងនាមខ្ញុំជា ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ មានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងដែលនាងខ្ញុំចែករំលែកនូវចំណេះដឹង ដែលខិតខំសិក្សាស្រាវជ្រាវ កន្លងមកហើយចងក្រងជាកិច្ចការស្រាវជ្រាវមួយ ដែលអាចផ្តល់ឱកាសដល់ខ្ញុំបង្ហាញពីសមត្ថភាព និងលទ្ធភាពនៃការយល់ដឹងទាក់ទងទៅនឹង ប្រធានបទ "ការបែងចែកមត៌ក" ដែលជាផ្នែកមួយនៃមុខវិជ្ជានីតិរដ្ឋប្បវេណី ហើយបានដឹកនាំ និងផ្តល់ដំបូន្មានពីសំណាក់ លោកសាស្ត្រាចារ្យ **ហេង ម៉ូរ៉ា**។ នាងខ្ញុំសង្ឃឹមថា កម្រងអត្ថបទស្រាវជ្រាវនេះ អាចផ្តល់ចំណេះដឹងមួយផ្នែក និងជាស្ពានចម្លងសម្រាប់បណ្តាអ្នកសិក្សាស្រាវជ្រាវ និងសិស្ស និស្សិត ជំនាន់ក្រោយបន្តការសិក្សាស្រាវជ្រាវបន្ថែម។

ជាទីបញ្ចប់នាងខ្ញុំ សូមធ្វើការអភ័យទោសទុកជាមុន ចំពោះកំហុសខុសឆ្គងទាំងឡាយដែល កើតមានឡើង ដោយអចេតនាតាមរយៈ កំហុសអក្ខរាវិរុទ្ធ ការប្រើប្រាស់ពាក្យពេចន៍មិនសមស្របជាដើម។ ជាពិសេសនាងខ្ញុំសង្ឃឹមថា អ្នកអានអាចយោគយល់ អធ្យាស្រ័យ ហើយនាងខ្ញុំរង់ចាំទទួលរាល់ការកែតម្រូវពីសំណាក់សាស្ត្រាចារ្យ សិស្ស និស្សិត មិត្តអ្នកអាន ដោយក្តី សោមនស្សរីករាយ។

ថ្ងៃ.......................... ខែ........ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ភ្នំពេញ, ថ្ងៃទី................... ខែ........ ឆ្នាំ ២០២១

និស្សិតឈ្មោះ

**សាខ គីមប្រណី**

# មាតិកា

**សេចក្តីផ្តើម** ............ ១

## ជំពូកទី១

## ការចាប់ផ្តើមសន្តតិកម្ម

**១.១ បទប្បញ្ញត្តិទូទៅ** ............ ៤
១.១.១ អានុភាពនៃសន្តតិកម្ម ............ ៤
១.១.២ ភាពគ្រប់លក្ខណសម្បត្តិជាសន្តតិជន (តាមច្បាប់ និងមតកសាសន៍) ............ ៦
១.១.២.១ សន្តតិជនដែលទទួលមរណភាព ............ ៦
១.១.២.២ អភ័ព្វបុគ្គលនៃសន្តតិកម្ម ............ ៧
១.២.២.៣ ការផ្តាច់មត៌កពីសន្តតិជន ............ ៨
**១.២ ប្រភេទនៃសន្តតិកម្ម** ............ ៨
១.២.១ សន្តតិកម្មតាមច្បាប់ ............ ៨
១.២.១.១ សន្តតិជនក្នុង ៣ លំដាប់ ............ ៩
១.២.១.២ សន្តតិកម្មរបស់សហព័ទ្ធ ............ ១០
១.២.១.៣ សន្តតិកម្មជំនួស ............ ១៣
១.២.២ សន្តតិកម្មតាមមតកសាសន៍ ............ ១៤
១.២.២.១ សមត្ថភាពក្នុងការធ្វើមតកសាសន៍ ............ ១៦
១.២.២.២ ការលុបចោលនូវមតកសាសន៍ ............ ១៦
១.២.២.៣ អានុភាពនៃមតកសាសន៍ ............ ១៧
ក. អានុភាពនៃមតកសាសន៍ ............ ១៧
ខ. អានុភាពនៃការកំណត់ចំណែកមត៌ក ............ ១៧

## ជំពូកទី២

## ការបែងចែកមត៌ក

**២.១ ការគណនាចំណែកមត៌ក** ............ ១៩

២.១.១ ការគណនាចំណែកមត៌កតាមច្បាប់ ........ ១៩
២.១.២ ការគណនាចំណែកមត៌កក្នុងករណីមានផលប្រយោជន៍ពិសេស ........ ២២
២.១.៣ ការគណនាចំណែកមត៌កក្នុងករណីមានភាគនៃវិភាគទាន ........ ៣២
២.១.៤. ភាគបម្រុង (ការបែងចែកមត៌កតាមមតកសាសន៍) ........ ៣៤

**២.២ ការរៀបចំបែងចែកមត៌ក ........ ៤៧**

២.២.១ ការពិភាក្សាបែងចែកមត៌ក ........ ៤៨
២.២.១.១ ការពិភាក្សារវាងសហសន្តតិជន ........ ៤៨
២.២.១.២ ការបែងចែកដោយតុលាការ ........ ៥១
២.២.២ សិទ្ធិ និងកាតព្វកិច្ចរបស់សហសន្តតិជន ........ ៥១

**២.៣ លំហូរនៃការបែងចែកមត៌ក ........ ៥៧**

២.៣.១ ទំហំនៃសន្តតិជន ........ ៥៨
២.៣.២ ចំណែកសន្តតិកម្មតាមច្បាប់ ........ ៥៨
២.៣.៣ ទំហំនៃមត៌ក ........ ៥៩
២.៣.៤. ការវាយតម្លៃមត៌ក ........ ៥៩
២.៣.៥. ការកំណត់ចំណែកមត៌កជាក់ស្តែង ........ ៦០
២.៣.៦. ដីកាសម្រេចបែងចែកមត៌ក ........ ៦០

**ជំពូកទី៣**

**ការយល់ព្រម និងការបោះបង់សន្តតិកម្ម**

**៣.១ ការយល់ព្រមសន្តតិកម្ម ........ ៦២**

៣.១.១ ការយល់ព្រមទាំងស្រុង ........ ៦២
៣.១.២ ការយល់ព្រមដោយមានកម្រិត ........ ៦៣

**៣.២ ការបោះបង់នូវសន្តតិកម្ម ........ ៦៤**

# សេចក្តីផ្តើម

សត្វលោកអាចកើត រស់រានមានជីវិត ហើយក៏អាចបាត់បង់ទៅវិញដោយពុំមានការព្រៀងទុក ហើយនេះគឺជាអ្វីដែលធម្មជាតិបានចារទុក និងជាជោគវាសនាដែលមិនកែប្រែបានរបស់សត្វលោក។ ហេតុនេះហើយទើបមានពាក្យពេចន៍មួយបានចែងថា "កើត ចាស់ ឈឺ ស្លាប់" ដែលពិតជាឆ្លុះ បញ្ចាំង ពីភាពជាក់ស្តែងនៃជីវិតរបស់សត្វលោកគ្រប់រូប មិនអាស្រ័យលើមនុស្ស ឬសត្វឡើយ។ កាលណា បុគ្គល ម្នាក់ក្នុងបុគ្គលរាប់លាននាក់បាត់បង់ជីវិត និងលាចាកពីលោកនេះទៅ ទ្រព្យសម្បត្តិ និងបំណុល បុគ្គលរូបនោះមិនអាចយកតាមខ្លួនបានទេ សូម្បីតែកាក់មួយ ដែលដាក់បង់ ចូលទៅក្នុង មាត់ក៏យកទៅមិនបានផង។ លុយកាក់ មាសប្រាក់ ទ្រព្យសម្បត្តិ ដីធ្លីស្រែចម្ការ ទោះបីមានច្រើនប៉ុណ្ណា ក៏យកទៅមិនបានដែរ ត្រូវទុកចោលនៅលើផែនដីនេះទាំងអស់ ។ កើតមកទទេ ពេលស្លាប់ទៅវិញ ក៏ទៅទទេ ។

យ៉ាងណាមិញ កាតព្វកិច្ច និងទ្រព្យដែលនៅសេសសល់ តែងតែក្លាយជាកម្មវត្ថុ នៃលទ្ធកម្មកម្មសិទ្ធិ របស់កូនចៅ។ អាស្រ័យហេតុនេះ ការរស់នៅក្រោមដំបូលតែមួយ ការណ៍ដែលមាននាមថាជា ញាតិទៅ នឹងបុគ្គលណាម្នាក់សុទ្ធតែត្រូវបានតភ្ជាប់ទៅនឹងផលប្រយោជន៍ ឬកាតព្វកិច្ច មួយចំនួនដែល យើងនឹក ស្មានមិនដល់។ កាកប្រាក់ ដីធ្លី បំណុលដែលជាកាតព្វកិច្ចសេសសល់ ក៏អាចក្លាយទៅជាកម្មវត្ថុនៃជម្លោះ ដែលអាចធ្វើអោយគ្រួសារបែកបាក់ និង ឈ្លក់វង្វេងនឹងទ្រព្យសម្បត្តិដែរ។

អាស្រ័យហេតុនេះ ទើបកិច្ចការស្រាវជ្រាវនេះ បានសរសេរឡើង ក្នុងគោលបំណងអោយ អ្នក អាន យល់អោយច្បាស់ពីរបបនៃការចែករំលែកទ្រព្យ និងកាតព្វកិច្ច ដែល សេស សល់ក្រោយ ពី មតកជន បាន ទទួលមរណភាព។

នាងខ្ញុំជឿជាក់ថា កម្រងសារណារបស់យើងខ្ញុំនឹងចូលរួមចំណែកមួយផ្នែកក្នុងការផ្តល់ នូវចំណេះដឹងលើការគ្រប់គ្រងទ្រព្យសម្បត្តិនេះជូនប្រជាពលរដ្ឋ ដើម្បីយកទៅអនុវត្តក្នុងសង្គមក៏ដូចជាសិស្សានុសិស្សជំនាន់ក្រោយៗក្នុងការស្វែងយល់ពីបញ្ហានេះ។ បន្ថែមពីនេះ ទៅទៀត គន្ថីទី ៨ នៃក្រមរដ្ឋប្បវេណី មានចំណងជើងថា "សន្តតិកម្ម" ដែលអាចផ្តល់ជាមូលដ្ឋានដល់បងប្អូនយល់បន្ថែម និងច្បាស់លាស់ជាងនេះ អំពីប្រធានបទសន្តតិកម្ម។ យ៉ាងណាមិញ កិច្ចការស្រាវជ្រាវនេះនឹងផ្តោតសំខាន់ទៅលើរបៀបបែងចែកមត៌ក។ ស្របគ្នានេះដែរ នាងខ្ញុំក៏ សូមអភ័យទោសចំពោះកំហុសដោយអចេតនាលើផ្នែកណាមួយ ឬក៏ឃ្លាណាមួយ។ នាងខ្ញុំរង់ចាំដោយក្តីសោមនស្សរីករាយចំពោះការរិះគន់ដើម្បីស្ថាបនារបស់លោក លោកស្រី និងប្រិយមិត្តដែលបានអាននូវ

សៀវភៅនេះ។ យើងខ្ញុំមានតែម្រាមដៃដប់ក្នុងការគោរពអរគុណដល់អស់លោក លោកស្រី និង ប្រិយមិត្តអ្នកអាន ដែលចំណាយពេលវេលាក៏មានតម្លៃក្នុងការអាន និងស្វែងយល់ ស្នាដៃរបស់យើងខ្ញុំ។

# ជំពូកទី១

# ការចាប់ផ្តើមសន្តតិកម្ម

ជាក់ស្តែង របបសន្តតិកម្មត្រូវបានបែងចែកជា ២ ប្រភេទ ដែលមានដូចជា គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្ត និង គោលការណ៍ជម្រះបញ្ជី។[1] ក្រមរដ្ឋប្បវេណីនៃច្បាប់ទ្វីប និង ក្រមរដ្ឋប្បវេណីជប៉ុនទៀតសោតបានប្រើប្រាស់ គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តមកធ្វើជាមូលដ្ឋាន ក្នុងការតាក់តែងជាបទប្បញ្ញត្តិច្បាប់។ ហេតុដូច្នេះ ក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជាសព្វថ្ងៃស្ថិតនៅក្រោមរបបសន្តតិកម្មដែលគោរពទៅតាមគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្ត ដោយយោងទៅតាមខ្លឹមសារនៃបទប្បញ្ញត្តិច្បាប់។

គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ គឺជាគោលការណ៍ដែលសន្តតិជនអាចទទួលទាំងស្រុងនូវសិទ្ធិនិងករណីកិច្ចដែលនៅសល់ពីមតកជនដែលជាអ្នកបានទទួលមរណៈភាព ហើយមត៌កត្រូវបានបែងចែកក្នុងករណីមានសហសន្តតិជនច្រើននាក់។ ក្នុងករណីដែល កាតព្វកិច្ចធ្ងន់ធ្ងរហួសហេតុពេក ដែលអាចផ្តល់ផលវិបាកដល់សន្តតិជនដែលត្រូវស្នង នោះសន្តតិជនអាចបោះបង់សន្តិកម្ម ឬយល់ព្រមដោយមានកម្រិត ដើម្បីសម្រួលដល់សន្តតិជនត្រូវស្នងកាតព្វកិច្ចដែលនៅសេសសល់។ រីឯគោលការណ៍ជម្រះបញ្ជី គឺជាគោលការណ៍ដែលត្រូវជម្រះបញ្ជីទាំងអស់នូវសិទ្ធិបំណុលនិងកាតព្វកិច្ចរបស់ មតកជនពេលដែលសន្តតិកម្មកើតមានឡើង។ សន្តតិជនវិញត្រូវស្នងត្រឹមទ្រព្យនោះតែក្នុងករណីដែលមានទ្រព្យសកម្មតែប៉ុណ្ណោះ។ ក្នុងករណីដែល កាតព្វកិច្ចធ្ងន់ធ្ងរហួសហេតុពេក ដែលអាចផ្តល់ផលពិបាកដល់សន្តតិជនដែលត្រូវស្នង នោះសន្តតិជនត្រូវប្រកាសឲ្យមានក្ស័យធននៃមតកនោះដើម្បី កុំឲ្យសន្តតិជនទទួលនូវបន្ទុកកាតព្វកិច្ចធ្ងន់ធ្ងរនោះ។[2]

សន្តតិកម្ម ជារួមត្រូវបានផ្តល់ជានិយមន័យថា ជាការផ្ទេរលទ្ធកម្មទ្រព្យពីមតកជនដែលបានទទួលមរណភាពទៅដល់សន្តតិជន។ យោងតាម សទ្ទានុក្រមផ្នែករដ្ឋប្បវេណី "សន្តតិកម្ម (Succession) គឺជាការផ្ទេរនូវ សិទ្ធិនិងករណីយកិច្ច របស់មតកជនទៅឱ្យសន្តតិជន (Successor) ម្នាក់ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់"។[3] ដោយផ្អែកតាមនិយមន័យខាងលើ យើងអាចវែកញែក បានថា សន្តតិកម្មអាចធ្វើឡើងតាមច្បាប់ ដោយបញ្ញត្តិសម្រាប់ការបែងចែកនោះនៅក្នុងក្រមរដ្ឋប្បវេណី និងតាមឆន្ទៈមតកជនដែលបែងចែកមត៌កនោះ។ បន្ថែមពីនេះ ការផ្ទេរ

[1] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, ទំព័រ ១

[2] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, ទំព័រ ១

[3] សទ្ទានុក្រមផ្នែករដ្ឋប្បវេណី, លេខ ១៤៣

កម្មសិទ្ធិពីមតកជនដែលទទួលមរណភាពមកឱ្យមនុស្សនៅរស់សន្តតិជន គឺជា ការផ្ទេរនូវបេតិកភណ្ឌ សិទ្ធិ និង ករណីយកិច្ច ទ្រព្យសម្បត្តិ និង បំណុលទាំងឡាយដែលនៅសេសសល់។ ប៉ុន្តែ សិទ្ធិ និង កាតព្វកិច្ច ណា ដែល មាន លក្ខណៈ ផ្តាច់មុខ គឺ មិនអាច ក្លាយជាកម្មវត្ថុ នៃ សន្តតិកម្ម បានឡើយ។ អាស្រ័យហេតុនេះ ការធ្វើយន្តការ សន្តតិកម្មនេះ គឺអាចធ្វើក្រោម ២ ទម្រង់ ដែលរួមមាន សន្តតិកម្មតាមច្បាប់ និងមតកសាសន៍(តាមឆន្ទៈ)។

សន្តតិកម្មដែលផ្អែកតាមឆន្ទៈរបស់មតកជន ហៅថា **សន្តតិកម្មមានបណ្តាំ** ឬ **សន្តតិកម្មតាមមតកសាសន៍** ដែលត្រូវបានគេនិយមប្រើប្រាស់ច្រើនក្នុងបរិបទច្បាប់។ ក្នុងករណីមតកជនធ្វើបណ្តាំដែលជាទម្រង់របស់សន្តតិកម្មតាមមតកសាសន៍ នោះច្បាប់ត្រូវផ្តល់អាទិភាពដល់ឆន្ទៈមតកជន ដែលជាម្ចាស់ទ្រព្យបានធ្វើនៅមុនពេលស្លាប់ និងអនុវត្តតាមខ្លឹមសារដែលមានចែងក្នុងលិខិតបណ្តាំនោះ។ ក្នុងករណីដែលមតកជនមិនបានគ្រោងទុកជាមុនដោយមានអវត្តមាននៃបណ្តាំនោះរបស់មតកជននោះ ចាំបាច់ត្រូវអនុវត្តយន្តការតាមច្បាប់ដើម្បីបែងចែកចំណែកឱ្យសន្តតិជន។ យន្តការដែលត្រូវអនុវត្តគឺមានទម្រង់ជា **សន្តតិកម្មតាមច្បាប់** ទៅតាមការកំណត់ ដោយបទប្បញ្ញត្តិ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី។[4]

## ១.១ បទប្បញ្ញត្តិទូទៅ

សន្តតិកម្មត្រូវតែចាប់ផ្តើមឡើងក្រោយពេលដែលមាន មរណភាពរបស់មតកជន ផ្អែកតាមមាត្រា ១១៤៥ នៃក្រមរដ្ឋប្បវេណី។ អាស្រ័យហេតុនេះ ច្បាប់មិនទទួលស្គាល់សន្តតិកម្មនៅពេលដែលមតកជននៅរស់ លើកលែងតែមានករណីដូចជាមតកជនបានបាត់ខ្លួន រហូតដល់ត្រូវបានចាត់ទុកថាគាត់ទទួលមរណភាព[5] ដូច្នេះ ទើបច្បាប់ទទួលស្គាល់ថា សន្តតិកម្មនេះអាចប្រព្រឹត្តទៅបាន។

### ១.១.១ អានុភាពនៃសន្តតិកម្ម

តាមរយៈគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ សិទ្ធិ និងករណីយកិច្ចទាំងឡាយ ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ត្រូវតែបន្សល់ដល់សន្តតិជន។ មាត្រា ១១៤៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីបានបញ្ជាក់ថា សន្តតិកម្ម ត្រូវធ្វើឡើងដោយផ្អែកតាមមូលដ្ឋាននៃតាមគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ ។

[4] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៤៥

[5] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤១, ៤៥

ដូច្នេះក្រមរដ្ឋប្បវេណី បានជ្រើសរើសយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ ហើយពុំបានជ្រើសរើសយក គោលការណ៍ជម្រះបញ្ជីនោះទេ។ អាស្រ័យហេតុនេះ សន្តតិជនត្រូវទទួលសិទ្ធ និងករណីយកិច្ច "ចាប់ពីពេលដែលចាប់ ផ្តើមសន្តតិកម្ម"[6] ក្នុងគោលបំណងឱ្យមាននិរន្តរភាពតាមផ្លូវច្បាប់។[7]

បន្ថែមពីនេះទៀត សន្តតិកម្មអចលនវត្ថុ អាចទទួលបន្តដោយស្វ័យប្រវត្តិនូវ អចលនវត្ថុដែលជាមត៌កនៅពេលដែលមតកជនទទួលមរណភាព ដោយមិនចាំបាច់ធ្វើការចុះបញ្ជី ពាក់ព័ន្ធនឹងការណ៍ដែលបានធ្វើសន្តតិកម្មក្រោមទម្រង់ សន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍ឡើយ។ យើងអាចធ្វើការពិចារណាបានថា ប្រសិនបើមានការចុះបញ្ជីជាល័ក្ខខ័ណ្ឌដើម្បីទទួលបន្តតាមសន្តតិកម្ម នោះក្នុងអំឡុងពេលមុនសន្តតិជនធ្វើការចុះបញ្ជី ពុំមានអត្ថិភាពម្ចាស់កម្មសិទ្ធិអចលនវត្ថុឡើយ ការណ៍នេះអាចផ្តល់ជាស្ថានភាពដែលទ្រព្យនោះធ្លាក់ ទៅជាទ្រព្យរដ្ឋ។ ក្នុងករណីដែលវត្ថុទាំងនោះ ពុំអាចធ្វើសន្តតិកម្មដោយសន្តតិជនតាមច្បាប់បាន ចាំបាច់ត្រូវអោយបន្តដោយជនដទៃទៀត ឬក៏មានករណីមួយចំនួនដែលមានសហសន្តតិជន (ករណីនៃសហសន្តតិកម្ម)។ បន្ថែមពីនេះសហសន្តតិជនណាម្នាក់អាចទទួលវត្ថុទាំងនោះដោយឯកឯង ដោយមិនស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគ ដូចមានចែងក្នុងមាត្រា ១១៤៨ ទេ។ ដូច្នេះយើងអាចកំណត់ថា វត្ថុទាំងនេះត្រូវទទួលបន្ត ដោយយោងតាមឆន្ទៈរបស់មតកជន ឬ តាមទំនៀមទម្លាប់ដែលមាន ទោះបីជាមានប្រពន្ធ និងឪពុកម្តាយជាសហសន្តតិជនក៏ដោយ។

**កំណត់សម្គាល់ ៖**

ម្យ៉ាងទៀត ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៥៩៣ និង មាត្រា ៦០២ បានចែងថា កាតព្វកិច្ចសន្តតិកម្មត្រូវធ្វើការជម្រះបញ្ជីសិនមុននឹងធ្វើការបែងចែកមត៌ក ជាអាទិ៍ហើយមើលទៅដូចជាគោលការណ៍ជម្រះបញ្ជីដែរ ក៏ប៉ុន្តែ នៅក្នុងមាត្រា ៦០៥ និងមាត្រា ៥៨៣ បានចែងថា សន្តតិជនដែលមានភាគបម្រុង មាន

[6] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៤៧

[7] "ក្រមរដ្ឋប្បវេណីជប៉ុន", Civil Code of Japan (Part IV and Part V (Tentative translation), Act No. 89 of April 27, 1896, Translation date: January 30, 2014

Article 896 From the time of commencement of inheritance, an heir shall succeed blanket rights and duties attached to the property of the decedent; provided that this shall not apply to rights or duties of the decedent that are purely personal.

Retrieved from: http://www.japaneselawtranslation.go.jp/law/detail/?id=2252&vm=2&re=02&new=1

ករណីយកិច្ចទទួលបន្តនូវការសងបំណុល ព្រមទាំងមិនអាចបោះបង់សន្តតិកម្មបានទេ ហើយបញ្ហានេះអាចចាត់ទុកថាជាគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិមួយប្រភេទដែរ។[8]

មាត្រា ១១៤៨._ ការទទួលបន្តសិទ្ធិលើទ្រព្យសម្បត្តិ ក្នុងករណីដែលមានសន្តតិជន ច្រើននាក់
១-ប្រសិនបើមានសន្តតិជនច្រើននាក់ សហសន្តតិជនម្នាក់ៗ ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ច តាមសមាមាត្រនៃចំណែកមត៌កនោះ ។ ប៉ុន្តែ សិទ្ធិ ឬ ករណីយកិច្ចដែល មិនអាចបែងចែក បានតាមលក្ខណៈនៃសិទ្ធិ ឬ ករណីយកិច្ចនោះ ត្រូវទទួលបន្ត ដោយ អវិភាគីយ៍ ។
២-មត៌កនេះ នឹងត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន ។

ក្នុងករណីដែលមានសន្តតិជនច្រើននាក់ ការទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចរបស់មតកជន ដោយសហសន្តតិជនម្នាក់ៗ ទៅតាម សមាមាត្រនៃចំណែកមត៌កដែលខ្លួនត្រូវស្នង ក្នុងករណីដែលមានសន្តតិជនច្រើននាក់ដោយផ្អែកតាមកថាខណ្ឌទី១ ។

- ក្នុងករណីដែលមតកជនមានសិទ្ធិលើបំណុលជាប្រាក់ចំពោះតតិយជន យើងអាចធ្វើការបែង ចែកសិទ្ធិលើបំណុលនេះ តាមចំណែកមត៌កដែលច្បាប់បានកំណត់ដល់សហសន្តតិជននីមួយៗ ដោយស្វ័យប្រវត្តិ ដោយមិនចាំបាច់រង់ចាំពេលបែងចែកមត៌កទេ ។
- ក្នុងករណីដែលមតកជនមានកាតព្វកិច្ច ចំពោះ តតិយជន ប្រសិនបើកាតព្វកិច្ចនោះជាប្រាក់ ជាអាទិ៍ដែលអាចបែងចែកបាន ត្រូវបែងចែកតាមចំណែកមត៌កដែលច្បាប់ បានកំណត់ ហើយ សហសន្តតិជនត្រូវទទួលករណីយកិច្ចសងកាតព្វកិច្ច របស់មតកជន ប្រសិនបើមិនបានបោះបង់ចោលការស្នងនោះទេ ហើយករណីកិច្ចនេះត្រូវធ្វើទៅតាមសមាមាត្រនៃចំណែកមត៌កដែលច្បាប់បានកំណត់ លើកលែងតែសហសន្តតិជនមិនបានបោះបង់ សន្តតិកម្មនោះទេ ។

### ១.១.២ ភាពគ្រប់លក្ខណសម្បត្តិជាសន្តតិជន (តាមច្បាប់ និងមតកសាសន៍)

#### ១.១.២.១ សន្តតិជនដែលទទួលមរណភាព

ជនដែលបានទទួលមរណភាព នាពេលសន្តិកម្មបានចាប់ផ្តើម មិនអាចក្លាយជាសន្តតិជនបានទេ។[9]

[8] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា ១១៤៧.
[9] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៤៩ កថាខណ្ឌទី ១

### ១.១.២.២ អភ័ព្វបុគ្គលនៃសន្តតិកម្ម

ប្រសិនបើសន្តតិជនមានបានទទួលមរណភាព គ្រប់គ្រាន់សម្រាប់ការទទួលបានសន្តតិជនហើយមែនទេ? តើសន្តតិជនដែលមានក្នុង ៣ លំដាប់នោះ គឺសន្តតិជនដោយស្វ័យប្រវត្តមែនដែរឬទេ? ជាក់ស្តែង សន្តតិជន ក្នុង ៣ លំដាប់នោះ អាចក្លាយជាសន្តតិជនដោយផ្អែកតាមកាលៈទេសៈ និងអង្គហេតុមួយចំនួន។ យ៉ាងណាមិញ នាមជាសន្តតិជននេះអាចត្រូវបានដកហូតបាន ហើយបុគ្គលនេះត្រូវបានគេអោយឈ្មោះថា អភ័ព្វបុគ្គល។ អាស្រ័យហេតុនេះ តើកត្តាអ្វីខ្លះដែលនាំឲ្យបុគ្គលនេះត្រូវបានរឹបអូសពីនាមជាសន្តតិជន និងបាត់បង់លក្ខណៈសម្បត្តិក្នុងការទទួលមត៌ក?

យោងតាមមាត្រា១១៥០ បុគ្គលដែលត្រូវបានកំណត់ថាជាអភ័ព្វបុគ្គលដែលពុំអាចក្លាយជាសន្តតិជន ឬទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បានឡើយ មានកំណត់ដូចខាងក្រោម៖

(ក) បុគ្គលដែលបានទទួលទោសដោយមានចេតនាធ្វើឃាត ឬប៉ុនប៉ងធ្វើឃាតលើមតកជន ឬលើជនដែលមានលំដាប់សន្តតិកម្មមុន ឬស្មើគ្នាទោះជាដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី។

(ខ) បុគ្គលដែលដឹងអំពីការសម្លាប់មតកជនតែមិនបានរាយការណ៍ ឬមិនបានប្តឹងលើកលែងតែករណីពិសេសខ្លះ។

(គ) បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើលុបចោល ឬកែប្រែមតកសាសន៍ដោយការឆបោក ឬគំរាមកំហែង ។

(ឃ) បុគ្គលដែលបានឲ្យមតកជនធ្វើលុបចោល ឬកែប្រែមតកសាសន៍ដោយការឆបោក ឬគំរាមកំហែង។

(ង) បុគ្គលដែលបានក្លែងកែបន្លំបំផ្លាញចោល ឬលាក់ទុកនូវលិខិតមតកសាសន៍។

មតកជនកាល អាចដាក់ពាក្យសុំទៅតុលាការឲ្យផ្តាច់មតកពីជនដែលបានប្រព្រឹត្តដូចខាងក្រោម៖

(ក) បើជននោះបានធ្វើបាបចំពោះមតកជន។

(ខ) បើជននោះបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ។

(គ) បើជននោះអាចមកមើលថែទាំមតកជននៅពេលមានជំងឺ ប៉ុន្តែមិនមកថែទាំ។

(ឃ) បើជននោះបានទទួលការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារមួយជីវិត។

(ង) បើជននោះបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឲ្យកត់សម្គាល់ជាអាទិ៍។[10]

[10] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១១៥០

### ១.២.២.៣ ការផ្តាច់មត៌កពីសន្តតិជន

កាលដែលនៅរស់ មតកជនមានសិទ្ធិអាចដាក់ពាក្យសុំទៅតុលាការ ក្នុងគោលបំណងចង់ផ្តាច់មតកជនបានដែលត្រូវសន្មតថាសន្តតិជននោះ មិនអាចទទួលសន្តតិកម្មបាន។ បើជនដែលត្រូវបានសម្រេចថាជាសន្តតិជនដែលមានភាគបម្រុង បានប្រព្រឹត្តនូវសកម្មភាពដែលបានកំណត់ខាងក្រោម ៖

១. បើបានធ្វើបាបចំពោះមតកជន ។

២. បើបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ ។

៣. បើអាចមកមើលថែទាំមតកជននៅពេលដែលមានជម្ងឺ ប៉ុន្តែមិនមកថែទាំ។

៤. បើបានទទួលសាលក្រម ឬសាលដីកាផ្តន្ទាទោសអោយជាប់ពន្ធធនាគារអស់មួយជីវិត។

៥. បើបានប្រព្រឹត្តអពើល្មើសធ្ងន់ធ្ងរគួរអោយកត់សំគាល់។

យ៉ាងណាមិញ ជនដែលត្រូវបានគេសន្មតថា ត្រូវបានផ្តាច់ពីសន្តតិកម្មនេះ អាចធ្វើវិវាទអំពីអត្ថិភាព ឬនត្ថិភាពនៃមូលហេតុនៃការផ្តាច់មត៌កនេះបាន។[11]

## ១.២ ប្រភេទនៃសន្តតិកម្ម

### ១.២.១ សន្តតិកម្មតាមច្បាប់

ក្នុងរឿងក្តីសន្តតិកម្ម យើងតែងតែមានចម្ងល់ថា នរណាដែលអាចក្លាយជាសន្តតិជន និងចាត់ចែងទៅលើទ្រព្យសម្បត្តិដែលមាន ឬ ទទួលករណីយកិច្ចបន្តពីមតកជន។ មនុស្សមួយចំនួនប្រហែលអាចនឹងមានការភាន់ច្រឡំ ពាក់ព័ន្ធនឹងការបែងចែកតាមច្បាប់ និងតាមឆន្ទៈរបស់មតកជន។ ដូច្នេះហើយទើបវិវាទអាចកើតមានជាពិសេសនៅពេលដែលកម្មវត្ថុនៃវិវាទនោះជាទ្រព្យសម្បត្តិដែលនៅសេសសល់។ សន្តតិជនដែលបានកំណត់តាមច្បាប់ ជាជនដែលអាចមានអត្តភាពក្នុងការទទួលបានមត៌កនោះ លុះត្រាតែមតកជនបានសរសេរមតកសាសន៍ដែលថែងផ្ទុយពីនេះ។ ដើម្បីអោយសន្តតិជនទទួលសន្តតិកម្មបាន សន្តតិជនត្រូវមានលក្ខណៈសម្បត្តិដូចជា៖

- ជនដែលមានជីវិត(លើកលែងទារកក្នុងគភ៌)
- ជនដែលមិនត្រូវបានផ្តាចមត៌ក
- ជនដែលមិនមែនជាអភ័ព្វបុគ្គល [12]

[11] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១១៥១

[12] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៤៩

ក្នុងករណីគ្មានបណ្តាំមត៌ក ច្បាប់កំណត់ថា កេរ្តិ៍មតកត្រូវចែកទៅឲ្យសន្តតិជនដែលមាន៣លំដាប់។ ជាគោលការណ៍ សន្តតិជនរបស់មតកជន មានចំនួន ៣លំដាប់ដោយ ផ្អែកតាមមាត្រា១១៥៦ មាត្រា១១៥៩ និងមាត្រា១១៦០នៃក្រមរដ្ឋប្បវេណី ដែលមានដូចខាងក្រោម:

**១.២.១.១ សន្តតិជនក្នុង ៣ លំដាប់**

សន្តតិជនទាំង ៣ លំដាប់ ត្រូវបានច្បាប់ចែងក្នុងមាត្រា ដែលរួមមាន៖

មាត្រា ១១៥៦._ សន្តតិជនដែលមានលំដាប់ទី១

១- កូនរបស់មតកជន ត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី១។

២- កូនរបស់មតកជន ទោះបីជាកូនបង្កើតក្តី ឬ កូនសុំក្តី ត្រូវមានចំណែកមត៌កស្មើៗគ្នា។

មាត្រា ១១៥៩._ សន្តតិជនដែលមានលំដាប់ទី ២

១- បើមតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់របស់មតកជននោះ ត្រូវក្លាយជាសន្តតិជន។ ប៉ុន្តែ រវាងបុគ្គលដែលមានថ្នាក់ញាតិខុសគ្នា ត្រូវយកបុព្វញាតិដែលនៅជិតជាងគេមុន។

២- ប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន មានចំនួនច្រើននាក់ បុព្វញាតិផ្ទាល់នីមួយៗត្រូវទទួលចំណែក មត៌កស្មើៗគ្នា។

មាត្រា ១១៦០._ សន្តតិកម្មដែលមានលំដាប់ទី ៣

១- បើមតកជនពុំមានទាំងបច្ឆាញាតិផ្ទាល់ ទាំងបុព្វញាតិផ្ទាល់ ដែលត្រូវក្លាយជាសន្តតិជនទេ បងប្អូនបង្កើតរបស់មតកជននោះ ត្រូវក្លាយជាសន្តតិជន។

២- បើបងប្អូនបង្កើតមានចំនួនច្រើននាក់ បងប្អូនបង្កើតម្នាក់ៗត្រូវបានចំណែកមត៌កភាគស្មើៗគ្នា។ ប៉ុន្តែ ចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬ ម្តាយតែម្ខាងដូចគ្នា ត្រូវមាន ១ ភាគ ២ (មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុក និង ម្តាយទាំងសងខាងដូចគ្នា។

៣- បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) និង បញ្ញត្តិនៃមាត្រា ១១៥៨ (ចំណែកមត៌កក្នុងករណីនៃសន្តតិកម្មជំនួស) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបងប្អូនបង្កើតរបស់មតកជនដែលត្រូវក្លាយជា សន្តតិជន យោងតាមបញ្ញត្តិ នៃ កថាខណ្ឌទី១ និង ទី២ ខាងលើនេះ បានទទួលមរណភាព នៅមុនពេល ចាប់ផ្តើម សន្តតិកម្ម។

ដោយផ្អែកតាមមាត្រាខាងលើ សន្តតិជនទាំង៣លំដាប់រួមមាន៖

1. សន្តតិជនលំដាប់ទី១: ជាកូនរបស់មតកជន ទោះកូនបង្កើតក្តី កូនសុំក្តី ត្រូវមានចំណែកស្មើៗគ្នា។
2. សន្តតិជនលំដាប់ទី២: ករណីមតកជនពុំមានបច្ឆាញាតិផ្ទាល់ឬកូននោះទេ បុព្វញាតិផ្ទាល់ដូចជាឪពុកម្តាយ ត្រូវទទួលចំណែកមត៌កស្មើគ្នា។
3. សន្តតិជនលំដាប់ទី៣: ក្នុងករណីមតកជននោះពុំមានបច្ឆាញាតិនិងបុព្វញាតិផ្ទាល់ទេ បងប្អូនបង្កើតនឹងក្លាយទៅជាសន្តតិជន ដែលត្រូវទទួលចំណែកមតកស្មើៗគ្នា។ ប៉ុន្តែចំពោះបងប្អូនបង្កើតដែលមានឪពុកឬម្តាយតែម្ខាងដូចគ្នា ត្រូវទទួលបានណែកតែ១/២នៃចំណែកបងប្អូនមានឪពុកនិងម្តាយទាំងសងខាងដូចគ្នា។

### ១.២.១.២ សន្តតិកម្មរបស់សហព័ទ្ធ

មាត្រា ១១៦១._ សន្តតិកម្មរបស់សហព័ទ្ធ

១-សហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច ។

២-នៅក្នុងករណីដែលសហព័ទ្ធរបស់មតកជនត្រូវក្លាយជាសន្តតិជន បើមាន បុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវជាសន្តតិជនដែរ ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) ខាងលើនេះ សហព័ទ្ធនោះត្រូវមានលំដាប់ស្មើគ្នានឹងបុគ្គលនោះ ។

ក្នុងករណីដែលមតកជនមានសហព័ទ្ធ នោះសហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច។ សហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច ទោះបីជាមាន ឬគ្មានសន្តតិជនផ្សេងទៀតក៏ដោយ។ ក៏ប៉ុន្តែ ក្នុងករណីដែលជននោះជាអភ័ព្វបុគ្គល ឬជាបុគ្គលដែលត្រូវផ្តាច់ពីសន្តតិកម្ម ជននោះមិនអាចទទួលសន្តតិកម្មបានឡើយ ទោះបីជាសហព័ទ្ធរបស់មតកជនក៏ដោយ ។

មាត្រា ១១៦២._ ចំណែកមត៌ក ក្នុងករណីដែលមានសហព័ទ្ធ

ក្នុងករណីដែលសហព័ទ្ធរបស់មតកជន និង បុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវក្លាយជាសន្តតិជន ចំណែកមត៌ករបស់សន្តតិជន នឹងត្រូវមានតាមកំណត់ដូចខាងក្រោម នេះ :

ក-បើសហព័ទ្ធ និង បច្ឆាញាតិផ្ទាល់របស់មតកជននោះ ជាសន្តតិជន សហព័ទ្ធ និង កូននីមួយៗ របស់មតកជននោះ នឹងត្រូវទទួលចំណែកមត៌កស្មើគ្នា ។

ខ-បើសហព័ទ្ធ និង ឪពុកម្តាយរបស់មតកជន ជាសន្តតិជន ចំណែកមត៌ក របស់សហព័ទ្ធ ត្រូវជា ១ ភាគ ៣ (មួយភាគបី) ឯចំណែកមត៌ករបស់ឪពុក ម្តាយ ត្រូវជា ២ ភាគ ៣ (ពីរភាគបី) ។ ប៉ុន្តែ បើឪពុក ឬ ម្តាយ របស់មតកជនតែម្នាក់នៅរស់ ឪពុក ម្តាយនោះ និង សហព័ទ្ធ ត្រូវបានចំណែកមត៌កស្មើគ្នា ។

គ-បើសហព័ទ្ធ និង បុព្វញាតិផ្ទាល់ក្រៅពីឪពុក ម្តាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះ ជាសន្តតិជន ចំណែក មត៌ករបស់សហព័ទ្ធ ត្រូវជា ១ ភាគ ២ (មួយភាគពីរ) ឯចំណែកមត៌ករបស់បុព្វញាតិផ្ទាល់ ក្រៅពីឪពុកម្តាយ របស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសនោះ ត្រូវជា ១ ភាគ ២ (មួយភាគពីរ) ។

ក្រៅពីសហព័ទ្ធ ប្រសិនបើមានសន្តតិជនផ្សេងទៀតក្នុងលំដាប់ទីn (មិនថាលំដាប់ទី១, ២, ឬ៣) សហព័ទ្ធត្រូវតែទទួលសន្តតិកម្មក្នុងលំដាប់ដូចគ្នានឹងសន្តតិជននេះជានិច្ច ហើយការអនុវត្តបែបនេះ ក៏មានលក្ខណៈស្រដៀងទៅនឹងក្រមរដ្ឋប្បវេណីជប៉ុន មាត្រា៨៩០ផងដែរ។[13] សន្មតថា មតកជន មានបច្ឆាញាតិ ផ្ទាល់ដែលជាកូន ឬ ក៏មានសន្តតិជនជំនួសកូននោះ សហព័ទ្ធត្រូវទទួលសន្តតិកម្មជាមួយសន្តតិជននោះ។ ប្រសិនបើបុព្វញាតិផ្ទាល់របស់មតកជននោះ ដែលជាសន្តតិជនលំដាប់ទី២ ទទួលសន្តតិកម្ម សហព័ទ្ធត្រូវទទួលសន្តតិកម្មជាមួយសន្តតិជននោះដែរ ។ ប្រសិនបើមតកជនណាម្នាក់ គ្មានសន្តតិជនចាប់ពីលំដាប់ទី ១ ដល់លំដាប់ទី ៣

[13] "ក្រមរដ្ឋប្បវេណីជប៉ុន", Civil Code of Japan (Part IV and Part V (Tentative translation), Act No. 89 of April 27, 1896, Translation date: January 30, 2014

Article 890 The spouse of a decedent shall always be an heir. In this case, if there is a person to become an heir pursuant to the provisions of Article 887 or the preceding Article, the spouse shall be of the same rank as that person.

Retrieved from: http://www.japaneselawtranslation.go.jp/law/detail/?id=2252&vm=2&re=02&new=1

នោះទេ សហព័ទ្ធនឹងទទួលសន្តតិកម្មតែម្នាក់ឯងដោយយោងទៅតាមបញ្ញត្តិនៃកថាខណ្ឌទី១ ដោយអត្ថន័យនេះត្រូវបានបន្សល់ទុកតាំងពីក្រមរដ្ឋប្បវេណីចាស់[14] មកម្ល៉េះ។[15]

ក្នុងករណីដែលសហព័ទ្ធរបស់មតកជន និងបុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវក្លាយជាសន្តតិជន ចំណែកមត៌ករបស់សន្តតិជន នឹងត្រូវបានបែងចែក ដោយផ្អែកតាមមាត្រា១១៦២នៃក្រមរដ្ឋប្បវេណី ដែលដូចនឹងតាមការកំណត់ដូចខាងក្រោម ៖

ករណីទី១-បើសហព័ទ្ធនិងបច្ឆាញាតិផ្ទាល់របស់មតកជននោះដែលត្រូវជាកូនរបស់មតកជន សន្តតិជនទាំងអស់ត្រូវទទួលចំណែកមត៌កស្មើៗគ្នា។

ករណីទី២-បើសហព័ទ្ធនិងឪពុកម្តាយជាសន្តតិជន នោះសន្តតិជនទាំង៣រូប ត្រូវទទួលបាន ចំណែក១/៣ស្មើៗគ្នា។ បើមតកជនមានឪពុកឬម្តាយតែម្នាក់ នោះសហព័ទ្ធ និងឪពុកឬម្តាយដែលនៅរស់ត្រូវទទួលចំណែក ១/២ស្មើគ្នា។

ករណីទី៣-បើសហព័ទ្ធនិងបុព្វញាតិផ្ទាល់ក្រៅពីឪពុកម្តាយ ឬបងប្អូនបង្កើត ឬសន្តតិជនជំនួស នោះចំណែកមតករបស់សហព័ទ្ធ ត្រូវជា ១/២ ឯចំណែកមតកបុព្វញាតិផ្ទាល់ក្រៅពីឪពុកម្តាយ ឬបងប្អូនបង្កើត ឬសន្តតិជនជំនួស ត្រូវជា១/២។[16]

ការទទួលចំណែកមត៌ករបស់សហព័ទ្ធ ឱ្យស្ថិតនៅលំដាប់ស្មើជាមួយនឹង សន្តតិជនដែលផ្អែកតាមមាត្រា១១៦១កថាខណ្ឌទី២នេះ ពិតជាឆ្លុះបញ្ចាំងពីតថភាពសង្គមសព្វថ្ងៃ ដែលផ្តល់តម្លៃដល់គោលការណ៍ការងារក្រៅផ្ទះស្មើនឹងការងារគេហដ្ឋាន និងផ្តល់នូវគុណធម៌សង្គមឬសមភាពរវាងបុរសនិងនារីដែលមានក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ហើយក៏បានធ្វើបដិប្បញ្ញត្តិកម្មក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ដែលចាត់ទុកសហព័ទ្ធដែលជាប្រពន្ធនៅលំដាប់ទី៤។ ការកំណត់ក្នុងក្រមរដ្ឋប្បវេណីចាស់ខុសនេះ បានធ្វើទៅដោយមានការពិចារណាថា វាស្របនឹងបរិបទសង្គមនាសម័យកាលនោះ ដោយនីតិបញ្ញត្តិករព្រមទាំងបញ្ញត្តស្របគ្នានឹងការអនុញ្ញាតបុរសជាស្វាមីអាចមានប្រពន្ធច្រើន(របបទ្វេពន្ធភាព) រីឯ ប្រពន្ធវិញពុំអាចមានប្តីច្រើនឡើយដែលបង្ហាញពីវិសមភាពនៃសិទ្ធិរវាងបុរសនិងនារី។

[14] មាត្រា ៩៩៧ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

[15] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា ១១៦១

[16] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១១៦២

**១.២.១.៣ សន្តតិកម្មជំនួស**

សន្តតិកម្មជំនួស អាចអនុវត្តទៅបានតែក្នុង ក្នុងករណីដែលកូនរបស់មតកជនបានទទួលមរណភាពមុនពេលចាប់ផ្តើមសន្តតិកម្ម។ នោះក្នុងករណីបែបនេះ កូនរបស់ជននោះត្រូវក្លាយទៅជាសន្តតិជនជំនួសដោយផ្អែកលើមាត្រា ១១៥៧ ថ្មី។

មាត្រា ១១៥៧ ថ្មី._

១ បើកូនរបស់មតកជន បានទទួលមរណភាព នៅមុន ឬ ព្រមគ្នានឹងពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់ សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងល័ក្ខខណ្ឌដែលបានកំណត់ក្នុងបទប្បញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ខាងលើនេះឬដោយការផ្តាច់មត៌កកូនរបស់បុគ្គលនោះត្រូវក្លាយទៅជាសន្តតិជនជំនួស។ ប៉ុន្តែបញ្ញត្តិ នេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះបុគ្គលដែលមិនមែនជាបច្ឆាញាតិផ្ទាល់របស់មតកជន។

២ បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះត្រូវយកមកអនុវត្តជាបន្តបន្ទាប់ ចំពោះករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ ចំពោះអ្នកទទួលសន្តតិកម្មជំនួស។

ផ្អែកតាមកថាខណ្ឌទី១នៃ មាត្រា១១៥៧ថ្មី ប្រសិនបើកូនរបស់មតកជនបានទទួលមរណភាពមុនពេលដែល សន្តតិកម្ម ត្រូវបានចាប់ផ្តើម នោះកូនរបស់ជននោះ ឬចៅរបស់មតកជននោះ ត្រូវក្លាយទៅជាសន្តតិជន។ ក្នុងករណីដែលកូនរបស់មតកជនបានទទួលមរណភាព ក្រោយពេលចាប់ផ្តើមសន្តតិកម្ម កូនមតកជនដែលទទួលមរណភាពនោះទទួលសន្តតិកម្មរបស់មតកជនរួច ទើបកូនរបស់ជននោះនឹងទទួលសន្តតិកម្មបន្តទៀតដោយសារតែជនបានទទួលមរណភាពហើយ។ ប្រសិនបើចៅរបស់មតកជនមិនអាច ឬអាចទទួលសន្តតិកម្មជាក់ស្តែងដោយអាស្រ័យលើពេលមុន ឬ ពេលក្រោយនៃមរណភាពរបស់កូនមតកជនត្រូវបានគេយល់ថាមិនមានភាពសមរម្យឡើយ អាស្រ័យហេតុនេះទើប របបសន្តតិកម្មជំនួសលេចចេញជារូបភាពក្នុងការគ្រប់គ្រងស្ថានភាពបែបនេះ។

ការណ៍ដែលកូនរបស់មតកជនត្រូវបាត់បង់សិទ្ធិជាសន្តតិជន ដោយសារមូលហេតុដូចជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬ ត្រូវបានមតកជនផ្តាច់មត៌កជាអាទិ៍ ទោះបីជាសាមីខ្លួននេះបានបាត់បង់សិទ្ធិជារឿងដែលមិនអាចជៀសវាងបានក៏ដោយ ក៏ប៉ុន្តែកូនរបស់សាមីជនដែលបានបាត់បង់សិទ្ធជាសន្តតិជននោះ មិនគួរការបាត់បង់សិទ្ធិជាសន្តតិជនជាក់ស្តែង ដោយគ្មានកំហុសឡើយព្រោះវាមានលក្ខណៈមិនសមស្រប អាស្រ័យហេតុនេះបានជាគេទទួលស្គាល់ការធ្វើ សន្តតិកម្មជំនួស ដើម្បីកុំអោយមានភាពមិនសមស្របបែបនេះ។

បន្ថែមពីនេះ ឃ្លានេះ "បានទទួលមរណភាពមុនពេលចាប់ផ្តើមសន្តតិកម្ម" ក៏ត្រូវរាប់បញ្ចូលទាំងការទទួលមរណភាពព្រមគ្នារបស់សន្តតិជននិងមតកជនផងដែរ។ នៅពេលដែលមានករណីបែបនេះ យើងមិនត្រូវធ្វើសន្តតិកម្មទៅវិញទៅមកបានទេ។[17] បន្ថែមពីនេះ វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ១១៥៧ថ្មីនេះចែងថា ក្នុងករណីដែលមតកជន បានធ្វើការសុំកូនធម្មតានោះ នោះកូនរបស់កូនសុំធម្មតានោះ មិនអាចក្លាយជាសន្តតិជនជំនួសបានទេ។ ហេតុនោះកូនរបស់កូនសុំធម្មតា ដែលបានកើតក្រោយពីពេលមតកជនបានធ្វើការសុំកូន គឺជាបច្ចាញាតិផ្ទាល់របស់មតកជន។ អាស្រ័យហេតុនេះ កូនរបស់កូនសុំនោះអាចទទួលសន្តតិកម្មជំនួសបាន។

ឯឃ្លា "អនុវត្តជាបន្តបន្ទាប់" គឺត្រូវបានអនុវត្តក្នុងករណីដែលមានមរណភាពរបស់សន្តតិជនជំនួសមុនពេលដែលមានការចាប់ផ្តើមសន្តតិកម្ម ដើម្បីបើកជាផ្លូវមួយសម្រាប់ការធ្វើសន្តតិកម្មជំនួសបន្តទៀត។ ជាធម្មតា មតកជនអាចមានកូន ចៅ និងចៅទួត ហើយកូននិងចៅរបស់មតកជនក៏អាចទទួលមរណភាព អាស្រ័យហេតុនោះចៅទួតនឹងក្លាយជាសន្តតិជនជំនួសដោយផ្អែកតាមកថាខណ្ឌទី២នៃមាត្រានេះ។ ប្រសិនបើចៅទួតនេះបានទទួលមរណភាពដូចគ្នា គេនៅតែទទួលស្គាល់សន្តតិកម្មជំនួសបន្តបន្ទាប់ទៀត។ ម្យ៉ាងទៀត សន្តតិកម្មជំនួសជាបន្តបន្ទាប់នេះ អាចអនុវត្តចំពោះតែសន្តតិជនដែលជាកូន របស់មតកជនប៉ុណ្ណោះ។ ប្រសិនបើមតកជនមានបងប្អូនបង្កើតជាសន្តតិជនវិញ ច្បាប់អាចទទួលស្គាល់នូវការធ្វើសន្តតិកម្មជំនួសត្រឹមតែមួយតំណប៉ុណ្ណោះ (សូមមើលសេចក្តីកំណត់នៃមាត្រា ១១៦០)។[18]

### ១.២.២ សន្តតិកម្មតាមមតកសាសន៍

ក្រមរដ្ឋប្បវេណីបានបង្ហាញថា យើងប្រកាន់ភ្ជាប់នឹង គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន[19] ដែលទទួលស្គាល់ឆន្ទៈរបស់មតកជនក្នុងការបែងចែក និងចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនដោយសេរី។ អាស្រ័យហេតុនេះ មតកជន ដែលមានបំណងចង់ចាត់ចែងទ្រព្យសម្បត្តិដែលនៅសេសល់ក្រោយពេល ទទួលមរណភាព ឆន្ទៈមតកជននឹងត្រូវបានផ្តល់អាទិភាព និងអនុវត្តតាមបំណងរបស់មតកជន ។

[17] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា ១១៥៥

[18] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា១១៥៧

[19] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៣

មតកសាសន៍ ត្រូវបានផ្តល់និយមន័យ "ជាលិខិតបណ្តាំដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ ដែលកំណត់ដោយច្បាប់ ដើម្បីសំដែងឆន្ទៈចុងក្រោយ អំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីខ្លួនទទួលមរណភាព។"[20] អច្ច័យទាន សំដៅទៅ"ប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមតកសាសន៍។"[21]

សរុបសេចក្តីមក មតកសាសន៍ គឺជាការកំណត់អំពីចំណែកមត៌ក កំណត់ពីវិធីបែងចែកមត៌ក អនុប្បទាន និងកំណត់ពីអ្នកប្រតិបត្តិមតកសាសន៍ជាដើម ។

ទម្រង់មតកសាសន៍ ដែលមានកំណត់នៅក្នុងច្បាប់មានដូចជា៖

- **មតកសាសន៍តាមទម្រង់ធម្មតា**
  - ⇨ មតកសាសន៍ដោយលិខិតយថាភូត
  - ⇨ មតកសាសន៍ដោយលិខិតសម្ងាត់
  - ⇨ មតកសាសន៍ដោយលិខិតឯកជន
- **មតកសាសន៍តាមទម្រង់ពិសេស**
  - ⇨ មតកសាសន៍នៃជនដែលកំពុងជួបគ្រោះថ្នាក់ដល់ជីវិត
  - ⇨ មតកសាសន៍របស់ជនដែលជាប់ឃុំឃាំង
- **មតកសាសន៍តាមទម្រង់បំពេញបន្ថែម**
  - ⇨ មតកសាសន៍នៃជនស្ថិតក្រោយរបបអាណាព្យាបាលទូទៅ
  - ⇨ មតកសាសន៍របស់ជនដែលមិនអាចនិយាយបាន និង
  - ⇨ ទម្រង់មតកសាសន៍របស់បុគ្គលដែលមានសញ្ជាតិខ្មែរដែលរស់នៅបរទេស ជាអាទិ៍។[22]

ប្រសិនបើមតកសាសន៍បានធ្វើឡើងក្រោមទម្រង់ដែលពុំមានកំណត់ទីនេះ នោះមតកសាសន៍មិនមានអានុភាពតាមផ្លូវច្បាប់ឡើយ ។

[20] សទ្ធានុក្រមផ្នែករដ្ឋប្បវេណី, ល.រ ១១៨

[21] សទ្ធានុក្រមផ្នែករដ្ឋប្បវេណី, ល.រ ១៧៧

[22] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៧៣ រហូតដល់ ១១៧៩ និង ១១៨១

### ១.២.២.១ សមត្ថភាពក្នុងការធ្វើមតកសាសន៍

បុគ្គលដែលអាចធ្វើមតកសាសន៍បាន គឺជាបុគ្គលដែលជានីតិជន និងអនីតិជនដែលបានទទួលអត្តាធីនភាព។[23] ដោយហេតុតែក្រមរដ្ឋប្បវេណីបានអនុញ្ញាតអោយ អនីតិជនដែលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាល ឬពីអំណាចមេបា ក៏អាចធ្វើមតកសាសន៍បានដែរ អាស្រ័យហេតុនេះ អ្នកអាណាព្យាបាលទូទៅ ឬហិតូបត្ថម្ភកៈ មិនអាចលុបមតកសាសាសន៍ចោលបានទេ។[24] សរុបមក ជនដែលអាចធ្វើមតកសាសន៍បាន ម្ចាស់បណ្ដាំត្រូវតែជាជនដែលមានសមត្ថភាពខាងឆន្ទៈ។[25] ប៉ុន្តែក្នុងករណីដែលម្ចាស់បណ្ដាំស្ថិតក្រោមឥទ្ធិពលគ្រឿងស្រវឹងពេលធ្វើមតកសាសន៍នោះ មតកសាសន៍ត្រូវចាត់ទុកថា មោឃៈ។

ចំពោះម្ចាស់បណ្ដាំដែលជាជននៅក្រោមអាណាព្យាបាលទូទៅវិញ ជននោះត្រូវសះស្បើយមួយរយៈពេលឡើងវិញ ហើយមានសមត្ថភាពក្នុងការយល់ដឹង ដោយខ្លួនអាចធ្វើការវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។ ក្នុងការណ៍នេះ ចាំបាច់ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិតយ៉ាងតិច២នាក់ដើម្បីអោយវេជ្ជបណ្ឌិតដែលវត្តមានបញ្ជាក់បន្ថែលើលិខិតមតកសាសន៍នោះថា ម្ចាស់បណ្ដាំមិនមែនស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹងឡើយ។[26]

### ១.២.២.២ ការលុបចោលនូវមតកសាសន៍

ការលុបចោលនៃមតកសាសន៍ សំដៅទៅសកម្មភាពដែលតម្រូវអោយស្របទៅតាមទម្រង់កំណត់[27] ហើយទម្រង់នៃការលុបចោលនេះរួមមាន ការលុបចោលដោយទម្រង់នៃមតកសាសន៍[28] ការលុបចោលមតកសាសន៍ដោយការចាត់ចែងពេលនៅរស់[29] និងការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ជាអាទិ៍[30] ។

---

[23] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៦៨

[24] "សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា ១១៦៨

[25] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៦៩

[26] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៧៦

[27] "សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា ១១៨៨

[28] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៨៩

[29] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៩០

[30] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៩១

ម្ចាស់បណ្ដាំនៃមតកសាសន៍នោះអាចធ្វើការលុបចោលនូវមតកសាសន៍នោះមួយភាគ ឬទាំងមូលនៅពេលណាក៏បាន[31] បានសេចក្ដីថា ក្រោយពីបានធ្វើមតកសាសន៍រហូតដល់ពេលបានទទួលមរណភាព មតកជនអាចលុបចោលនូវមតកសាសន៍របស់ខ្លួននៅពេលណាក៏បានដែរ។[32]

### ១.២.២.៣ អានុភាពនៃមតកសាសន៍

#### ក. អានុភាពនៃមតកសាសន៍

ជាគោលការណ៍ មតកសាសន៍បង្កើតអានុភាព នៅពេលដែលម្ចាស់បណ្ដាំទទួលមរណភាព។[33] ព្រោះមតកសាសន៍ ឆ្លុះបញ្ចាំងពីឆន្ទៈរបស់ម្ចាស់បណ្ដាំក្នុងការសម្រេចនូវកម្មសិទ្ធទ្រព្យសម្បត្តិជាអាទិ៍ ក្រោយពេលដែលសាមីខ្លួនទទួលមរណភាព។[34] ប្រសិនបើមតកសាសន៍ ត្រូវបានភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ នោះមតកសាសន៍ ត្រូវមានអានុភាព ចាប់ពីពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញក្រោយម្ចាស់បណ្ដាំទទួលមរណភាព។[35]

ឧទាហរណ៍៖

១. ការធ្វើអច្ច័យទាននូវដីធ្លីដែលមានផ្ទះ ដោយតម្រូវអោយមានអាពាហ៍ពិពាហ៍នៃអច្ច័យលាភី នោះ ល័ក្ខខ័ណ្ឌបង្អង់គឺជាអាពាហ៍ពិពាហ៍នៃអច្ច័យលាភី។ អាស្រ័យហេតុនេះ អានុភាពនៃមតកសាសន៍នេះ នឹងកើតឡើង ប្រសិនបើអច្ច័យលាភីរៀបអាពាហ៍ពិពាហ៍ ក្រោយពេលម្ចាស់បណ្ដាំទទួលមរណភាព។

២. ការធ្វើអច្ច័យទាននូវឡានមួយគ្រឿង ដោយតម្រូវអោយអច្ច័យលាភីប្រឡងជាប់ជាសិស្សមេធាវី នោះការប្រឡងជាប់ជាសិស្សមេធាវីអច្ច័យលាភីជាល័ក្ខខ័ណ្ឌបង្អង់។ ផ្ទុយទៅវិញ អច្ច័យលាភីប្រឡងជាប់ជាសិស្សមេធាវីមុនម្ចាស់បណ្ដាំទទួលមរណភាព អាស្រ័យហេតុនេះ ពុំមានភ្ជាប់នូវល័ក្ខខណ្ឌទៀតទេ។[36]

#### ខ. អានុភាពនៃការកំណត់ចំណែកមត៌ក

ក្នុងករណីដែលមតកជន បានកំណត់ចំណែកមត៌ក ឬវិធីបែងចែកមត៌ក ដោយធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬច្រើនអោយចំពោះសន្តតិជនតែម្នាក់ ឬច្រើននាក់ដោយមតកសាសន៍ ទ្រព្យសម្បត្តិ

---

[31] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៨៨

[32] "សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា ១១៨៨

[33] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៩៤ ចំណុច ១

[34] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, សេចក្ដីកំណត់ ១១៩៤

[35] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៩៤ ចំណុច ២

[36] "សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា ១១៩៤

ជាក់លាក់នោះ ត្រូវធ្លាក់ទៅសន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះដោយស្វ័យប្រវត្តិ ព្រមគ្នានឹងពេលមតកសាសន៍នោះបង្កើតអានុភាព។[37] ជាធម្មតា ប្រសិនបើសហសន្តតិជនមិនព្រមព្រៀងនឹងការបែងចែកមត៌កនេះទេ នោះមត៌កនឹងនៅតែត្រឹមជា កម្មសិទ្ធិអវិភាគ ដែលមិនទាន់ត្រូវបានបែងចែក។ ប៉ុន្តែ ការកំណត់នូវវិធីបែងចែកមត៌ក តាមមតកសាសន៍ និង ការកំណត់ចំណែកមត៌ក ដោយការធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់ ពុំចាំបាច់ឆ្លងកាត់ការពិភាក្សាសន្តតិជនទេ នោះអានុភាពនៃការបែងចែក នេះមានជាប្រតិសកម្ម ចាប់ពីពេលដែលសន្តតិកម្មត្រូវបានចាប់ផ្តើម។[38]

ប្រសិនបើមតកជនបានធ្វើមតកសាសន៍ដោយភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ នោះល័ក្ខខ័ណ្ឌបង្អង់ចាំបាច់ត្រូវបានបំពេញទើបសន្តតិជនអាចទទួលបានមត៌កនោះ។ ល័ក្ខខណ្ឌនេះត្រូវបានបំពេញ នៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ទ្រព្យសម្បត្តិដែលបានកំណត់ខាងលើនេះ ត្រូវបានធ្លាក់ទៅសន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយប្រតិសកម្មគិតចាប់តាំងពីពេលដែលមតកជននោះ បានទទួលមរណភាព។[39] បានសេចក្តីថា មត៌កនោះនឹងស្ថិតក្រោមស្ថានភាពជាកម្មសិទ្ធិអវិភាគ រហូតដល់ល័ក្ខខណ្ឌបង្អង់ត្រូវបានបំពេញ ទើបទ្រព្យជាក់លាក់នោះ អាចផ្តល់ដល់សន្តតិជនតាមរយៈ ការកំណត់ចំណែកមត៌ក ឬតាមការកំណត់វិធីបែងចែកនោះ។[40]

[37] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៩៥

[38] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្លីទី៨ - ទី៩", ២០១០, មាត្រា ១១៩៥

[39] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៩៥

[40] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្លីទី៨ - ទី៩", ២០១០, មាត្រា ១១៩៥

# ជំពូកទី២

# ការបែងចែកមត៌ក

## ២.១ ការគណនាចំណែកមត៌ក

ក្រោយពីបានស្គាល់ពីសន្តតិជនរួច យើងអាចស្គាល់ពីបុគ្គលណាខ្លះដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានសន្តតិកម្ម។ យ៉ាងណាមិញ យើងប្រហែលជាអាចនឹងមានចម្ងល់ថាតើមត៌កទាំងនោះត្រូវធ្វើការបែងចែកយ៉ាងដូចម្តេច? ជាការពិតណាស់ ការបែងចែកកេរ្តិ៍មត៌ក គឺ មានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ចាប់ពី មាត្រា ១១៤៥ រហូតដល់ មាត្រា ១៣០៤ (សន្តតិកម្ម)។ បន្ថែមពីនេះទៅទៀត ការគណនាចំណែកមត៌កនេះត្រូវបានចែកចេញជាពីររបៀបដែល (ក)តាមច្បាប់ និង (ខ)ជនដែលមានផលប្រយោជន៍ពិសេស (គ)ភាគនៃវិភាគទាន។

### ២.១.១ ការគណនាចំណែកមត៌កតាមច្បាប់

ជាដំបូងយើងត្រូវក្រឡេកទៅមើលសន្តតិជនទាំង ៣ លំដាប់ដែលមានសន្តតិជនដែលមានលំដាប់ទី១ សន្តតិជនដែលមានលំដាប់ទី ២ និង សន្តតិជនដែលមានលំដាប់ទី ៣។ ដូច្នេះក្នុងករណីដែលមត៌កជនមានកូនដែលត្រូវនិងជាសន្តតិជនដែលមានលំដាប់ទីមួយត្រូវតែទទួលមត៌កជានិច្ច។

ចំណែកសន្តតិកម្មរបស់កូននីមួយៗគឺស្មើភាគគ្នា លុះត្រាតែសន្តតិជននោះបោះបង់សន្តតិកម្មឬក្លាយជាអភ័ព្វបុគ្គល។ បន្ថែមពីនេះ សហព័ទ្ធត្រូវជាសន្តតិជនជានិច្ច។

---

**ករណីសិក្សាទី ១៖** A ជាមត៌កជនមានកូន C D ហើយពុំមានសហព័ទ្ធឡើយ។

ចូរកំណត់អំពីចំណែកមត៌កតាមច្បាប់សម្រាប់សន្តតិជននីមួយៗ។

<u>ចម្លើយ៖</u>

- យោងតាមមាត្រា១១៥៦ កូនរបស់មតកជនត្រូវក្លាយជាសន្តតិជនលំដាប់ទី ១ និងត្រូវទទួលបានចំណែកមត៌កស្មើៗគ្នា។

ដូចនេះ C និង D គឺជាសន្តិជនដែលត្រូវទទួលបានចំណែកមត៌ក ១/២ (មួយភាគពីរ) ស្មើៗគ្នា។

**ករណីសិក្សាទី ២៖** A ជាមត៌កជនមានកូន C D ហើយ មានសហព័ទ្ធ B ឡើយ។

ចូរកំណត់អំពីចំណែកមត៌កតាមច្បាប់សម្រាប់សន្តតិជននីមួយៗ។

ចម្លើយ៖

- យោងតាមមាត្រា១១៥៦ កូនរបស់មតកជនត្រូវក្លាយជាសន្តតិជនលំដាប់ទី ១ និងត្រូវទទួលបានចំណែកមត៌កស្មើៗគ្នា។
- ផ្អែកតាមមាត្រា ១១៦១ សហព័ទ្ធ ត្រូវក្លាយជាសន្តតិជនជានិច្ច ហើយសហព័ទ្ធត្រូវមានលំដាប់ស្មើគ្នានឹងបុគ្គលដែលជាសន្តតិជនក្រៅពីសហព័ទ្ធនោះ (ក្នុងករណីនេះ បុគ្គលដែលជាសន្តតិជនក្រៅពីសហព័ទ្ធនោះ គឺ C D)។
- មាត្រា ១១៦២ ចំណុច ក បានចែងថា បើសហព័ទ្ធ និងបច្ឆាញាតិផ្ទាល់របស់មតកជននោះ ជាសន្តតិជន សហព័ទ្ធ និងកូននីមួយៗរបស់មតកជននោះ នឹងត្រូវទទួលបានចំណែកមត៌កស្មើគ្នា។

ដូចនេះ B C និង D នឹងត្រូវទទួលបានចំណែកមត៌ក ១/៣ (មួយភាគបី)ស្មើគ្នា ដោយធ្វើការយោងតាមមាត្រា ១១៥៦, ១១៦១, ១១៦២ ចំណុច ក នៃក្រមរដ្ឋប្បវេណី។

**ករណីសិក្សាទី ៣៖** A ជាមតកជន មានសហព័ទ្ធ B។ ក្នុងចំណងអាពាហ៍ពិពាហ៍ A និង B អ្នកទាំងពីរមានកូនចំនួន ៤ នាក់ គឺ C D E និង F។ មុនទទួលមរណភាព A បានទទួលស្គាល់កូន G ជាកូនបង្កើតដែលមាននៅក្នុងទំនាក់ទំនងលួចលាក់ជាមួយនឹង P។

ចូរកំណត់អំពីចំណែកមត៌កតាមច្បាប់សម្រាប់សន្តតិជននីមួយៗ។

ចម្លើយ ៖

- យោងតាមមាត្រា១១៥៦ កូនរបស់មតកជនត្រូវក្លាយជាសន្តតិជនលំដាប់ទី ១ និងត្រូវទទួលបានចំណែកមត៌កស្មើៗគ្នា។ កូនក្រៅចំណងអាពាហ៍ពិពាហ៍ក៏ត្រូវបានចំណែកមត៌កស្មើនឹងកូនកើតក្នុងចំណងអាពាហ៍ពិពាហ៍ដែរ។[41]
- មាត្រា ១១៦២ ចំណុច ក បានចែងថា បើសហព័ទ្ធ និងបច្ឆាញាតិផ្ទាល់របស់មតកជននោះ ជាសន្តតិជន សហព័ទ្ធ និងកូននីមួយៗរបស់មតកជននោះ នឹងត្រូវទទួលបានចំណែកមត៌កស្មើគ្នា។

[41] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា ១១៥៦

ដូចនេះ B C D E Fនិង G ត្រូវជាសហសន្តតិជន ហើយត្រូវទទួលបានចំណែកមត៌កស្មើគ្នា បានន័យថា សន្តតិជនទាំង ៦ នាក់ ត្រូវបានចំណែក ១/៦ (មួយភាគប្រាំមួយ) ស្មើគ្នា។

## ករណីសិក្សាទី ៤៖

មតកជន A មានសហព័ទ្ធម្នាក់ឈ្មោះ B។ ក្នុងចំណងអាពាហ៍ពិពាហ៍រវាង A និង B អ្នកទាំងពីរ មានកូន C D E F និង G។ លោក C បានរៀបអាពាហ៍ពិពាហ៍ជាមួយ O និងមានកូន ២នាក់ គឺ C1 និង C2។ លោក A និង លោក C បានទទួលមរណភាពជាមួយគ្នាដោយសារជម្ងឺកូវីដ១៩។

ចូរកំណត់អំពីចំណែកមត៌កតាមច្បាប់សម្រាប់សន្តតិជននីមួយៗ។

<u>ចម្លើយ ៖</u>

- មាត្រា ១១៦២ ចំណុច ក បានចែងថា បើសហព័ទ្ធ និងបច្ឆាញាតិផ្ទាល់របស់មតកជននោះ ជាសន្តតិជន សហព័ទ្ធ និងកូននីមួយៗរបស់មតកជននោះ នឹងត្រូវទទួលបានចំណែកមត៌កស្មើគ្នា។

សន្តតិជន B C D E F G ត្រូវបានចំណែកមត៌កស្មើគ្នា បានន័យថា សន្តតិជនទាំង ៦ នាក់ ត្រូវបានចំណែក ១/៦ (មួយភាគប្រាំមួយ) ស្មើគ្នា។

- មាត្រា ១១៥៧ថ្មី កថាខណ្ឌទី ១ បានកំណត់ថា កូនរបស់ បុគ្គល (កូនរបស់មតកជនដែលបានទទួលមរណភាពនៅមុន ឬព្រមគ្នានឹងពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សន្តតិកម្ម ឬ ដោយការផ្តាច់មត៌ក) ត្រូវក្លាយជាសន្តតិជនជំនួស។
- មាត្រា ១១៥៨ បានកំណត់ថា ក្នុងករណីដែលមានបច្ឆាញាតិច្រើន ចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់រៀងៗខ្លួននោះត្រូវទទួលបាន ត្រូវបែងចែកស្មើៗគ្នា រវាងបច្ឆាញាតិទាំងឡាយនោះ។

ដោយសន្តតិជន C បានទទួលមរណភាព ហើយលោក C មានបច្ឆាញ្ញាតិផ្ទាល់ C1 C2 ដែលត្រូវក្លាយជាសន្តតិជនជំនួស ត្រូវបានចំណែកមត៌ក ១/៦/២ = ១/១២ (មួយភាគដប់ពីរ) ស្មើគ្នា។

ដូចនេះ សន្តតិជន B D E F G ត្រូវបានចំណែកមត៌កស្មើគ្នា បានន័យថា សន្តតិជនទាំង ៦ នាក់ ត្រូវបានចំណែក  ១/៦ (មួយភាគប្រាំមួយ) ស្មើគ្នា ឯ C1 C2 ដែលជាសន្តតិជនជំនួស ត្រូវបានចំណែកមត៌ក ១/១២ (មួយភាគដប់ពីរ) ស្មើគ្នា។

**ករណីសិក្សាទី ៥៖**

លោក A ជាមតកជន មានសហព័ទ្ធម្នាក់ឈ្មោះ B។ លោក A មានឪពុកម្តាយបង្កើតឈ្មោះ X និង Y និងឪពុកម្តាយក្មេកឈ្មោះ O និង P។ លោកស្រី Y បានទទួលមរណភាពកាលពីឆ្នាំ ២០១៥ ដោយបន្សល់ទុកកូនបង្កើតចំនួន ៣នាក់ គឺ A I និង V។

ចូរកំណត់អំពីចំណែកមត៌កតាមច្បាប់សម្រាប់សន្តតិជននីមួយៗ។

ចម្លើយ ៖

- មាត្រា ១១៥៩ កថាខណ្ឌទី១ បានចែងថា បើមតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់របស់មតកជននោះ ត្រូវក្លាយជា សន្តតិជន។
- មាត្រា ១១៦២ ចំណុច ខ បានចែងថា បើសហព័ទ្ធ និងឪពុកម្តាយរបស់មតកជននោះ ជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធ ត្រូវជា ១ ភាគ ៣ ឯចំណែកមត៌ករបស់ឪពុកម្តាយ ត្រូវជា ២ ភាគ ៣។ ប៉ុន្តែ បើឪពុក ឬម្តាយ របស់មតកជនតែម្នាក់នៅរស់ ឪពុកម្តាយនោះ និងសហព័ទ្ធ ត្រូវបានចំណែកមត៌កស្មើគ្នា។

យោងតាមមាត្រា ១១៦២-ខ សហព័ទ្ធB និងឪពុកY ត្រូវបានចំណែកមត៌កស្មើគ្នា នោះសន្តតិជនទាំង ២ ត្រូវទទួលបានចំណែក ១ ភាគ ២ ស្មើគ្នា។

---

## ២.១.២ ការគណនាចំណែកមត៌កក្នុងករណីមានផលប្រយោជន៍ពិសេស

ការសម្រួលចំណែកមត៌ក គឺជាវិធានធ្វើឲ្យមានសមភាពជាក់ស្តែងនៅក្នុងចំណោមសន្តតិជន ដែលបានទទួលនូវផលប្រយោជន៍ពិសេសឬប្រទានកម្មនៅមុនពេលម្ចាស់ទ្រព្យបានស្លាប់។ ផលប្រយោជន៍ពិសេសជាផលប្រយោជន៍ដែល បុគ្គលណាម្នាក់ឬច្រើននាក់បានទទួលជាប្រទានកម្មនៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងៗទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ ឬដែលទទួលបានអច្ច័យទានពីមតកជន។ អច្ច័យទានដែលត្រូវបានផ្តល់ទៅសន្តតិជន ក៏ ត្រូវចាត់ទុកថាជាផលប្រយោជន៍ពិសេសផងដែរ ប៉ុន្តែពុំត្រូវរាប់បញ្ចូលក្នុងការគណនានោះទេព្រោះអច្ច័យទានពុំទាន់ត្រូវបានបែងចែកទៅឲ្យសន្តតិជនឡើយ នៅពេលចាប់ផ្តើមសន្តតិកម្ម។

មាត្រា ១១៦៣._ ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស

១. នៅក្នុងចំណោមសហសន្តិជនទាំងអស់ បើមានបុគ្គលណាបានទទួលប្រទានកម្មនៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ ឬបានទទួលអច្ច័យទានពីមតកជន តម្លៃសរុបនៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ដោយបូកបញ្ចូលនូវតម្លៃនៃប្រទានកម្ម ត្រូវចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់ដែលនៅសល់ ក្រោយពីការតម្លៃនៃប្រទានកម្ម ឬអច្ច័យទាននោះ ចេញពីចំណែកមត៌កដែលត្រូវបានគណនា តាមបញ្ញត្តិនៃផ្នែកទី១ (សន្តតិជន)និងផ្នែកទី២ (សន្តតិកម្មរបស់សហព័ន្ធ) គឺជាចំណែកមត៌ករបស់បុគ្គលនោះ។

២. បើតម្លៃនៃប្រទានកម្ម ឬអច្ច័យទានស្មើគ្នានឹងតម្លៃនៃចំណែកមត៌ក ឬលើសតម្លៃនៃចំណែកមត៌ក សហសន្តតិជននោះពុំអាចទទួលចំណែកមត៌កនោះបានឡើយ។

---

**ករណីសិក្សាទី១៖** មតកជន A មានឪពុកម្តាយ X Y ដែលទទួលមរណភាពនៅឆ្នាំ ២០១៥។ នៅពេលចាប់ផ្តើមសន្តតិកម្ម ឪពុកម្តាយរបស់ X ឈ្មោះ Q និង R និង ម្តាយរបស់ Y ឈ្មោះ I និងសហព័ទ្ធឈ្មោះ B នៅរស់រានមានជីវិត។ មតកជន A បន្សល់ទុកនូវទ្រព្យសម្បត្តិជាមត៌កដូចខាងក្រោម ៖

| | |
|---|---|
| ប្រាក់នៅក្នុងធនាគារចំនួន | USD ៤២,០០០ |
| ដីមួយកន្លែងមានតម្លៃ | USD ៨០,០០០ |
| ផ្ទះមួយល្វែងមានតម្លៃ | USD ១៨០,០០០ |

កាលនៅរស់ មតកជន A បានធ្វើប្រទានកម្មនូវដីមួយកន្លែងមានតម្លៃ USD ១៤០,០០០ ឱ្យលោកស្រី R និងបានឱ្យទៅលោក T ជាជីតានូវប្រាក់ចំនួន USD ៦០,០០០។

<u>ចម្លើយ៖</u>

ប្រាក់នៅក្នុងធនាគារចំនួន USD ៤២,០០០

ដីមួយកន្លែងមានតម្លៃ USD ៨០,០០០

ផ្ទះមួយល្វែងមានតម្លៃ USD ១៨០,០០០

R ទទួលបានប្រទានកម្ម USD ១៤០,០០០

T ទទួលបានប្រទានកម្ម USD ៦០,០០០

យោងតាមមាត្រា ១១៦២ (គ) នៃក្រមរដ្ឋប្បវេណី

- B ទទួលបាន ១ភាគ២
- Q, R និង I ទទួលបាន ១ភាគ៦

<u>វិធីសម្រួលចំណែកមត៌ក ក្នុងករណីមានផលប្រយោជន៍ពិសេស</u>

១. ទ្រព្យសម្បត្តិជាមូលដ្ឋាន

យោងតាមមាត្រា ១១៦៣(១) នៃក្រមរដ្ឋប្បវេណី យើងបាន

ទ្រព្យសម្បត្តិមូលដ្ឋាន = មត៌កនៅពេលចាប់ផ្តើម + ប្រទានកម្ម + អច្ច័យទាន

៤២,០០០+៨០,០០០+១៨០,០០០+១៤០,០០០= ៤៤២,០០០

២. ចំណែកមត៌ករបស់សន្តតិជន

ចំណែកមត៌ករបស់សន្តតិជន=ទ្រព្យជាមូលដ្ឋាន x ចំណែកមត៌កតាមច្បាប់-តម្លៃនៃប្រទានកម្មដែល សន្តតិជនទទួលបាន

- ⇨ ចំណែកមត៌ករបស់ B= ៤៤២,០០០ x ១/២=២២១,០០០
- ⇨ ចំណែកមត៌ករបស់ Q= ៤៤២,០០០ x ១/៦=៧៣,៦៦៦.៦៦
- ⇨ ចំណែកមត៌ករបស់ I= ៤៤២,០០០ x ១/៦=៧៣,៦៦៦.៦៦
- ⇨ ចំណែកមត៌ករបស់ R= ៤៤២,០០០ x ១/៦-១៤០,០០០= -៦៦,៣៣៣.៣៤។

R មិនអាចទទួលបានចំណែកមត៌កឡើង ពីព្រោះ ទទួលបានប្រទានកម្មច្រើនជាងចំណែកមត៌ ដោយយោងតាមមាត្រា១១៦៣ ចំណុច២នៃក្រមរដ្ឋប្បវេណី ក។

៣. គណនាសមាមាត្រនៃចំណែកមត៌ក

ផ្អែកតាមមាត្រា ១១៦៥ (២) និងមាត្រា ១១៦៣ (១) នៃក្រមរដ្ឋប្បវេណី យើងបាន៖

តម្លៃនៃចំណែកមត៌កដែលសន្តតិជនត្រូវទទួលបាន=តម្លៃនៃចំណែកមត៌ករបស់សន្តតិជន x ទ្រព្យសម្បត្តិជាក់ស្តែង/តម្លៃសរុមនៃចំណែកមត៌ករបស់សន្តតិជន

ទ្រព្យសម្បត្តិជាក់ស្តែង=៣០២,000

តម្លៃសរុបនៃចំណែកមត៌ករបស់សន្តតិជន=៣៦៨,៣៣៣.៣២

ដូច្នេះចំណែកមត៌កដែលសន្តតិជន៖

- ⇨ តម្លៃចំណែកមត៌ក B =២២១,000 x ៣០២,000/៣៦៨,៣៣៣.៣២=១៧៩,០១០
- ⇨ តម្លៃចំណែកមត៌ក Q =៧៣,៦៦៦.៦៦-៣០២,000/៣៦៨,៣៣៣.៣២=៥៩,៦៦៩.៩៩
- ⇨ តម្លៃចំណែកមត៌ក I ត្រូវទទួលបាន=៧៣,៦៦៦.៦៦-៣០២,000/៣៦៨,៣៣៣.៣២=៥៩,៦៦៩.៩៩

**ករណីសិក្សាទី២៖** មតកជន D មានបងប្អូនបង្កើតចំនួន ៤ នាក់ឈ្មោះ C G E និង F។ F គឺជាបងប្អូនបង្កើតរួមឪពុកជាមួយ D។ ក្រៅពីនេះ D មានសហព័ទ្ធ ឈ្មោះ B។ នៅឆ្នាំ ២០១៥ C បានទទួលមរណភាពដោយបន្សល់ទុកកូនពីរនាក់គឺ C1 និង C2។

មតកជន A បន្សល់ទុកនូវទ្រព្យសម្បត្តិជាមត៌កដូចខាងក្រោម ៖

ប្រាក់នៅក្នុងធនាគារចំនួន USD ៨0,000

អលង្ការមានតម្លៃ USD ១៥,000

រថយន្តមានតម្លៃ USD ៦,000

កាលនៅរស់ មតកជន A បានធ្វើអំណោយនូវម៉ូតូមួយមានតម្លៃ USD ៣0,000 ឱ្យ C និងបានឱ្យប្រាក់ទៅលោក F នូវប្រាក់ចំនួន USD ៥,000។

ចម្លើយ៖

ប្រាក់នៅក្នុងធនាគារចំនួន USD ៨0,000

អលង្ការមានតម្លៃ USD ១៥,000

រថយន្តមានតម្លៃ USD ៦,000

F ទទួលបានប្រទានកម្ម USD ៥,000

ដោយយោងតាមមាត្រា ១១៦២ ( គ )

- B ទទួលបាន ១ភាគ២
- G , E ទទួលបាន ១ភាគ៧
- F C1 C2 ទទួលបាន ១ភាគ១៤

<u>វិធីសម្រួលចំណែកមត៌ក ក្នុងករណីមានផលប្រយោជន៍ពិសេស</u>

១. ទ្រព្យសម្បត្តិជាមូលដ្ឋាន

យោងតាមមាត្រា ១១៦៣(១)នៃក្រមរដ្ឋប្បវេណី

ទ្រព្យសម្បត្តិមូលដ្ឋាន = មត៌កនៅពេលចាប់ផ្ដើម+ប្រទានកម្ម+ អច្ច័យទាន

នាំឱ្យទ្រព្យសម្បត្តិមូលដ្ឋាន= ៨0,000+១៥,000+៦,000+៥,000=១0៦,000

២. ចំណែកមត៌ករបស់សន្តតិជន

ចំណែកមត៌ករបស់សន្តតិជន=ទ្រព្យជាមូលដ្ឋាន x ចំណែកមត៌កតាមច្បាប់-តម្លៃនៃប្រទានកម្មដែល សន្តតិជនទទួលបាន

ដូច្នេះ តម្លៃចំណែកមត៌កដែលសន្តតិជនត្រូវទទួលបាន

- ⇨ ចំណែកមត៌ករបស់B=១0៦,000 x ១/២=៥៣,000
- ⇨ ចំណែកមត៌ករបស់G=១0៦,000១ x ១/៧=១៥,១៤២.៣៥
- ⇨ ចំណែកមត៌ករបស់E=១0៦,000១ x ១/៧=១៥,១៤២.៣៥
- ⇨ ចំណែកមត៌ករបស់F= ១0៦,000១ x ១/១៤-៥,000=២,៥៧១.៤២
- ⇨ ចំណែកមត៌ករបស់C1= ១0៦,000១ x ១/១៤=៧,៥៧១.៤២
- ⇨ ចំណែកមត៌ករបស់C2= ១0៦,000១ x ១/១៤=៧,៥៧១.៤២

**ករណីសិក្សាទី៣៖** មតកជន A មានកូនបង្កើតចំនួន ៥ នាក់ឈ្មោះ C D E F និង G។ ក្រៅពីនេះ A មានសហព័ទ្ធ ឈ្មោះ B។

មតកជន A បន្សល់ទុកនូវទ្រព្យសម្បត្តិជាមត៌កដូចខាងក្រោម ៖

ប្រាក់នៅក្នុងធនាគារចំនួន USD ៤៥,000

អលង្ការមានតម្លៃ USD ១០,000

រថយន្តមានតម្លៃ USD ៥,000

កាលនៅរស់ មតកជន A បានធ្វើប្រទានកម្មឱ្យសហសន្តតិជនដូចខាងក្រោម ៖

B ទទួលបានដីដែលមានតម្លៃ USD ៥០,000

C ទទួលបានប្រាក់ USD ៤,000

D ទទួលបានប្រាក់ USD ៣,000

E ទទួលបានម៉ូតូ USD ២,000

<u>ចម្លើយ៖</u>

ប្រាក់នៅក្នុងធនាគារចំនួន USD ៤៥,000

អលង្ការមានតម្លៃ USD ១០,000

រថយន្តមានតម្លៃ USD ៥,000

B ទទួលបានប្រទានកម្ម USD ៥០,000

C ទទួលបានប្រាក់ USD ៤,000

D ទទួលបានប្រាក់USD ៣,000

E ទទួលបានម៉ូតូបSD ២,000

យោងតាមមាត្រា ១១៦២ (ក)

- B C D E F G ទទួលបាន ១ភាគ៦

វិធីសម្រួលចំណែកមត៌ក ក្នុងករណីមានផលប្រយោជន៍ពិសេស

១. ទ្រព្យសម្បត្តិជាមូលដ្ឋាន

យោងតាមមាត្រា ១១៦៣(១) នៃក្រមរដ្ឋប្បវេណី យើង

ទ្រព្យសម្បត្តិមូលដ្ឋាន = មត៌កនៅពេលចាប់ផ្ដើម+ប្រទានកម្ម+ អច្ច័យទាន

ទ្រព្យសម្បត្តិមូលដ្ឋាន=៤៥,000+១0,000+៥,000+៥0,000+៤,000+៣,000+២,000= ១១៩,000

២. ចំណែកមត៌ករបស់សន្តតិជន

ចំណែកមត៌ករបស់សន្តតិជន=ទ្រព្យជាមូលដ្ឋាន x ចំណែកមត៌កតាមច្បាប់-តម្លៃនៃប្រទានកម្មដែល សន្តតិជនទទួលបាន

- ⇨ ចំណែកមត៌ករបស់B= ១១៩,000 x ១/៦-៥0,000=-៣0,១៦៦.៦៧
- ⇨ ចំណែកមត៌ករបស់C= ១១៩,000 x ១/៦-៤,000=១៥.៨៣៣.៣៣
- ⇨ ចំណែកមត៌ករបស់D= ១១៩,000 x ១/៦-៣,000=១៦,៨៣៣.៣៣
- ⇨ ចំណែកមត៌ករបស់E= ១១៩,000 x ១/៦-២,000=១៧,៨៣៣.៣៣
- ⇨ ចំណែកមត៌ករបស់F= ១១៩,000 x ១/៦=១៩,៨៣៣.៣៣
- ⇨ ចំណែកមត៌ករបស់G= ១១៩,000 x ១/៦=១៩,៨៣៣.៣៣

យោងតាមមាត្រា១១៦៣ (២) នៃក្រមរដ្ឋប្បវេណី B មិនអាចទទួលបានចំណែកមត៌កឡើង ពីព្រោះទទួលបានប្រទានកម្មច្រើនជាងចំណែកមត៌ក។

៣. សមាមាត្រនៃចំណែកមត៌ក

យោងតាមមាត្រា ១១៦៥ (២) និងមាត្រា ១១៦៣ (១) នៃក្រមរដ្ឋប្បវេណី យើងបាន៖

តម្លៃនៃចំណែកមត៌កដែលសន្តតិជនត្រូវទទួលបាន=តម្លៃនៃចំណែកមត៌ករបស់សន្តតិជន x ទ្រព្យសម្បត្តិជាក់ស្ដែង/តម្លៃសរុបនៃចំណែកមត៌ករបស់សន្តតិជន

ទ្រព្យសម្បត្តិជាក់ស្តែង=៦០,០០០

តម្លៃសរុបនៃចំណែកមត៌ករបស់សន្តតិជន=៩០,១៦៦.៦៥

ដូច្នេះតម្លៃចំណែកមត៌កដែលសន្តតិជនត្រូវទទួលបាន

- ⇨ តម្លៃចំណែកមត៌កC ត្រូវទទួលបាន=១៥,៨៣៣.៣៣ x ៦០,០០០/៩០,១៦៦.៦៥=១៥,៤៤៩.៩៩
- ⇨ តម្លៃចំណែកមត៌កD ត្រូវទទួលបាន=១៦,៨៣៣.៣៣ x ៦០,០០០/៩០,១៦៦.៦៥=១១,១០៩.៩៩

  តម្លៃចំណែកមត៌កE ត្រូវទទួលបាន=១៧,៨៣៣.៣៣ x ៦០,០០០/៩០,១៦៦.៦៥=១១,៧៦៩.៩៩

  តម្លៃចំណែកមត៌កF ត្រូវទទួលបាន=១៩,៨៣៣.៣៣ x ៦០,០០០/៩០,១៦៦.៦៥=១៣,០៨៩.៩៩

  តម្លៃចំណែកមត៌កG ត្រូវទទួលបាន=១៩,៨៣៣.៣៣ x ៦០,០០០/៩០,១៦៦.៦៥=១៣,០៨៩.៩៩

**ករណីសិក្សាទី៤៖** មតកជន A មានឪពុកម្តាយ X Y ដែលទទួលមរណភាពនៅឆ្នាំ ២០១៨។ នៅពេលចាប់ផ្តើមសន្តតិកម្ម ឪពុកម្តាយរបស់ X ឈ្មោះ O និង ឪពុកម្តាយរបស់ Y ឈ្មោះ Q និង R ព្រមទាំងសហព័ទ្ធរបស់ A ឈ្មោះ B នៅរស់រានមានជីវិត។

មតកជន A បន្សល់ទុកនូវទ្រព្យសម្បត្តិជាមត៌កដូចខាងក្រោម ៖

ដី L1 មានតម្លៃ USD ៥៥,០០០

ប្រាក់ក្នុងធនាគារមានចំនួន USD ៦២,០០០

រថយន្តមានតម្លៃ USD ៧០,០០០

វីឡាមួយខ្នងតម្លៃ USD ៨២,០០០

កាលនៅរស់ មតកជន A បានធ្វើប្រទានកម្មឱ្យសហសន្តតិជនដូចខាងក្រោម ៖

O ទទួលបានប្រាក់ចំនួន USD ១៩២,០០០

B ទទួលបានដី L2តម្លៃ USD ៦៣,០០០

P ទទួលបានប្រាក់ USD ១៦,០០០

R ទទួលបានប្រាក់ USD ៥,000

ចម្លើយៈ

ដី L1 មានតម្លៃ USD ៥៥,000

ប្រាក់ក្នុងធនាគារមានចំនួន USD ៦២,000

រថយន្តមានតម្លៃ USD ៧0,000

វីឡាមួយខ្នងតម្លៃ USD ៨២,000

O ទទួលបានប្រាក់ចំនួនUSD ១៩២,000

B ទទួលបានដី L2តម្លៃ USD ៦៣,000

P ទទួលបានប្រាក់ USD ១៦,000

R ទទួលបានប្រាក់ USD ៥,000

យោងតាមមាត្រា ១១៦២ (គ)

B ទទួលបាន ១ភាគ២

Q R O ទទួលបាន ១ភាគ៦

វិធីសម្រួលចំណែកមត៌ក ក្នុងករណីមានផលប្រយោជន៍ពិសេស

១. ទ្រព្យសម្បត្តិជាមូលដ្ឋាន

យោងតាមមាត្រា ១១៦៣ ចំណុច នៃក្រមរដ្ឋប្បវេណី យើងបាន

ទ្រព្យសម្បត្តិមូលដ្ឋាន = មត៌កនៅពេលចាប់ផ្តើម+ប្រទានកម្ម+អច្ច័យទាន

ទ្រព្យសម្បត្តិមូលដ្ឋាន=៥៥,000+៦២,000+៨២,000+១៩២,000+៦៣,000+៥,000= ៥២៩,000

២. ចំណែកមត៌ករបស់សន្តតិជន

ចំណែកមត៌ករបស់សន្តតិជន=ទ្រព្យជាមូលដ្ឋាន x ចំណែកមត៌កតាមច្បាប់-តម្លៃនៃប្រទានកម្មដែល សន្តតិជនទទួលបាន

- ⇨ ចំណែកមត៌ករបស់B= ៥២៩,000 x ១/២-៦៣,000=២០១,៥00
- ⇨ ចំណែកមត៌ករបស់Q= ៥២៩,000 x ១/៦=៨៨,១៦៦.៦៦
- ⇨ ចំណែកមត៌ករបស់R= ៥២៩,000 x ១/៦-៥,000=៨៣,១៦៦.៦៦
- ⇨ ចំណែកមត៌ករបស់O= ៥២៩,000 x ១/៦-១៩២,000=-១0៣,000។

យោងតាមមាត្រា១១៦៣(២)នៃក្រមរដ្ឋប្បវេណី R មិនអាចទទួលបានចំណែកមត៌កឡើង

ពីព្រោះO ទទួលបានប្រទានកម្មច្រើនជាងចំណែកមត៌ក។

៣. សមាមាត្រនៃចំណែកមត៌ក

យោងតាមមាត្រា ១១៦៥ ( ២) និងមាត្រា ១១៦៣ (១) នៃក្រមរដ្ឋប្បវេណី យើងបាន៖

តម្លៃនៃចំណែកមត៌កដែលសន្តតិជនត្រូវទទួលបានតម្លៃនៃចំណែកមត៌ករបស់សន្តតិជន។
ទ្រព្យសម្បត្តិជាក់ស្តែង/តម្លៃសរុបនៃចំណែកមត៌ករបស់សន្តតិជន
ទ្រព្យសម្បត្តិជាក់ស្តែង=២៦៩,000

តម្លៃសរុបនៃចំណែកមត៌ករបស់សន្តតិជន=៣៧២,៨៣៣.៣២

ដូច្នេះតម្លៃចំណែកមត៌កដែលសន្តតិជនត្រូវទទួលបាន

- ⇨ តម្លៃចំណែកមត៌ក B ត្រូវទទួលបាន=២០១,៥00 x ២៦៩,000/៣៧២,៨៣៣.៣២=១៤៣,0៦៥
- ⇨ តម្លៃចំណែកមត៌ក Q ត្រូវទទួលបាន=៨៨,១៦៦.៦៦ x ២៦៩,000/៣៧២,៨៣៣.៣២ =៦២,៥៩៨.៣២
- ⇨ តម្លៃចំណែកមត៌កRត្រូវទទួលបាន=៨៣,១៦៦.៦៦-២៦៩,000/៣៧២,៨៣៣.៣២=៥៩,0៤៨.៩៩

### ២.១.៣ ការគណនាចំណែកមត៌កក្នុងករណីមានភាគនៃវិភាគទាន

យោងតាមមាត្រា ១១៦៦ ភាគនៃវិភាគទាន ត្រូវបានថែងឡើងដើម្បីសម្រួលចំណែកមត៌កដោយ ការសម្រួលចំណែកមត៌កក្នុងចំណោមសន្តតិជនម្នាក់ឬច្រើននាក់ ព្រោះសន្តតិជននោះបានធ្វើបង្ហាញពីសកម្មភាពថែរក្សា ឬបង្កើនទ្រព្យសម្បត្តិដល់មតកជន ថែទាំមតកជន ឬផ្តល់ជាសេវាកម្មដទៃដែលជាការចម្រើនផលដល់មតកជន។ បញ្ញត្តិនេះគឺជាការឆ្លុះបញ្ចាំងភាពជាក់ស្តែងពីការចំណាយនៅក្នុងចំណោមសន្តតិជនដែលបុគ្គលណាម្នាក់ឬច្រើននាក់ សម្រាប់មតកជន មុនពេលសន្តតិកម្មចាប់ផ្តើម។[42]

**រូបមន្ត៖**

មត៌កជាក់ស្តែង = មត៌កពេលចាប់ផ្តើមសន្តតិកម្ម - ភាគនៃវិភាគទាន

ចំណែកមត៌កនៃអ្នកធ្វើភាគវិភាគទាន = មត៌កជាក់ស្តែង / ចំនួនសន្តតិជន + ភាគនៃវិភាគទាន

ភាគីអាចព្រមព្រៀងទៅតាមករណីជាក់ស្តែង ប៉ុន្តែបើការពិភាក្សា មិនចុះសម្រុងគ្នា ជាអាទ៍ អាចស្នើសុំមក តុលាការកំណត់។ បន្ថែមពីនេះការវិនិច្ឆ័យនូវការបែងចែកមត៌ក យើងអាចទាមទារអោយ តុលាការ កំណត់តម្លៃនៃភាគនៃវិភាគទាន។ ប្រសិនបើមានករណីដែលភាគនៃវិភាគទាន មានចំនួនច្រើនជាងចំណែក មត៌កដែលមានកំណត់ក្នុងបណ្តាំមត៌ក ត្រូវយក បណ្តាំមត៌កជាគោល យោងតាមមាត្រា ១១៦៣ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។

ចំពោះក្រមរដ្ឋប្បវេណីជប៉ុន មានបញ្ញត្តិថា មិនឱ្យធ្វើការទាមទារឱ្យតុលាការធ្វើការ កំណត់តែភាគនៃវិភាគទានដាច់ដោយឡែកទេ (មាត្រា ៩០៤-២ កថាខណ្ឌទី ៤) ។

---

**ករណីសិក្សាទី១៖** មតកជនមានសន្តតិជន ៣ នាក់ A B និង C ដែលត្រូវទទួល សន្តតិកម្មស្មើភាគគ្នាទៅលើមត៌កចំនួន ២០០០ ដុល្លារ ហើយ A បានផ្តល់សេវាកម្មលើកិច្ចការរបស់មតកជន ដែលមានតម្លៃស្មើនឹង ៥០០ ដុល្លារ។

ចម្លើយ៖

[42] អ៊ុំ ប៉ូលី, "ការបែងចែកមត៌ក", ១២ មករា ២០១៨

- យោងតាមមាត្រា១១៦៦-១ ក្នុងចំណោមសហសន្តតិជនទាំងឡាយ បើមានបុគ្គលណាបានធ្វើវិភាគទានពិសេសដើម្បីថែរក្សាឬ បង្កើនទ្រព្យសម្បត្តិរបស់មតកជន ដោយការផ្តល់សេវកម្មលើ កិច្ចការរបស់មតកជន ឬ ដោយការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ ឬ ដោយការថែទាំ ព្យាបាលមតកជន ឬ ដោយវិធីផ្សេងទៀត តម្លៃដែលដកភាគនៃវិភាគទានរបស់បុគ្គលនោះ ដែលបានកំណត់តាមការពិភាក្សារបស់សហសន្តតិជន ចេញពីតម្លៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ត្រូវចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់នៃភាគ នៅក្នុងសន្តតិកម្ម ដែលបានគណនាតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) និង ផ្នែកទី ២ (សន្តតិកម្មរបស់សហព័ទ្ធ) បូកនឹងភាគវិភាគទាន ត្រូវជាចំណែកមត៌ករបស់ជននោះ ។

⇨ ទ្រព្យដែលត្រូវបានចាត់ទុកថាជាមត៌កគឺ ១៥០០ ដុល្លារ

ដោយ ២០០០-៥០០ ហើយត្រូវបែងចែកមត៌កនោះស្មើភាគគ្នា (ម្នាក់បាន ៥០០)។ ឯចំណែកមត៌កជាក់ស្តែងរបស់ A ត្រូវ (+៥០០ ដុល្លារ)ទៀត ដូច្នេះ A បាន ១០០០ ដុល្លារ B និង C បាន ៥០០ ដុល្លារម្នាក់ ។

**ករណីសិក្សាទី២៖** ករណីមានភាគនៃវិភាគទាន និងផលប្រយោជន៍ពិសេស ក្នុងពេលតែមួយ

ឧទាហរណ៍ ៖ A មតកជន B C D ជាសន្តតិជន មុនពេលស្លាប់ បានឱ្យផ្ទះទៅ C សម្រាប់ជាចំណងដៃនៃអាពាហ៍ពិពាហ៍ ដែលមានតម្លៃ ៥.០០០ និងឱ្យលុយនៅធនគារទៅ D ដែលមាន ចំនួន ១.០០០។ ប៉ុន្តែ B បានចំណាយថ្លៃព្យាបាល និងធ្វើបុណ្យសពឱ្យ A ដែលមានចំនួន ៤.០០០ ហើយមត៌កដែលបន្សល់ទុកគឺ ៧.០០០។

<u>ចម្លើយ៖</u>

មត៌កសរុប = ៧.០០០ + ៥.០០០ + ១.០០០ - ៤.០០០ = ៩.០០០

ចំណែកមត៌ករបស់ C = (៩.០០០ ៖ ៣) - ៥.០០០= - ២.០០០

ចំណែកមត៌ករបស់ D = (៩.០០០ ៖ ៣) - ១.០០០= ២.០០០

ចំណែកមត៌ករបស់ B = (៩.០០០ ៖ ៣) + ៤.០០០ = ៧.០០០

C មិនចាំបាច់សងវិញនោះទេ។ មត៌កជាក់ស្តែងមានតែ ៧.០០០ នោះ៖

⇨ D = (២.០០០ x ៧.០០០) ៖ ៩.០០០ =១.៥៥៥

⇨ B = (៧.០០០ x ៧.០០០) ៖ ៩.០០០ =៥.៤៤៥

**ករណីសិក្សាទី៣៖** មតកជន A ឱ្យ B ស្នងទ្រព្យស្មើនឹង ៣០០ ដុល្លារ ហើយឱ្យ C ស្នងទ្រព្យស្មើនឹង ៤០០ ដុល្លារ ហើយទោះបីជាតម្លៃនៃភាគវិភាគទានរបស់ D មាន ៤០០ ដុល្លារ ក៏ដោយ ក៏មិនអាចគិតឱ្យលើស ៣០០ ដុល្លារ ដែលជាចំនួនគណនាដោយយក ១០០០ ដុល្លារ ដកនឹង ៣០០ ដុល្លារ ហើយដកនឹង ៤០០ ដុល្លារទេ។
ចម្លើយ៖

- យោងតាមមាត្រា១១៩៥-១ បើមតកជន បានកំណត់ចំណែកមត៌ក ឬ វិធីបែងចែកមត៌ក ដោយធ្វើអនុប្បទាន ទ្រព្យសម្បត្តិជាក់លាក់តែមួយឬច្រើន ឱ្យ ចំពោះសន្តតិជនតែម្នាក់ ឬច្រើននាក់ ដោយមតកសាសន៍ ទ្រព្យសម្បត្តិជាក់លាក់នោះ ត្រូវធ្លាក់ទៅសន្តតិជនដែលនឹងត្រូវទទួល ទ្រព្យសម្បត្តិនោះដោយស្វ័យប្រវត្តិ ព្រមគ្នានឹងពេលមតកសាសន៍នោះបង្កើតអានុភាព ។

ដូច្នេះប្រសិនបើមានមតកសាសន៍បានកំណត់នូវម្ចាស់នៃទ្រព្យ ទ្រព្យនោះត្រូវផ្ទេរទៅម្ចាស់ដូចដែលមានចែងក្នុងមតកសាសន៍ នៅពេលដែលមតកសាសន៍មានអានុភាព។ ដូច្នេះ ទ្រព្យនោះមិនមែនជាកម្មវត្ថុនៃការបែងចែកមត៌ក។ [43]

---

## ២.១.៤. **ភាគបម្រុង** (**ការបែងចែកមត៌កតាមមតកសាសន៍**)

ក្រមរដ្ឋប្បវេណី បានបញ្ញត្តិអំពីការបែងចែកមត៌កតាមបញ្ញតិច្បាប់ (សន្តតិកម្មតាមច្បាប់) និង តាមឆន្ទៈរបស់មតកជន (មតកសាសន៍) ដោយបានធ្វើការកត់សម្គាល់ទៅលើ ការធ្វើមតកសាសន៍ដែលមានមតកជនជាម្ចាស់បណ្តាំបង្ហាញនូវឆន្ទៈរបស់ខ្លួនក្នុងការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន មុនសាមីខ្លួនទទួលមរណភាព។ យ៉ាងណាមិញ ម្ចាស់បណ្តាំដែលជ្រើសរើសរបៀបនៃការបែងចែកមត៌កនេះ អាចធ្វើអោយមានការបំពានដល់ចំណែករបស់សហសន្តតិជនណាមួយ។ ការណ៍នេះតែងកើតឡើង នៅពេលដែល មតកជនបានកំណត់

[43] អ៊ីវ ប៉ូលី, "ការបែងចែកមត៌ក", ១២ មករា ២០១៨

ក្នុងបណ្តាំថា នឹងបែងចែកមត៌កទៅឱ្យជនដទៃក្រៅពីសន្តតិជន ឬសន្តតិជនណាម្នាក់ច្រើនហួសហេតុ។ ដោយសារការបែងចែកដ៏អយុត្តិធម៌នេះហើយទើបបណ្តាលអោយមាន សន្តតិជនដទៃទៀតទទួលបានមត៌កតិចតួច ហើយមានកាតព្វកិច្ចច្រើនលើសលុប។ អាស្រ័យហេតុនេះ ដើម្បីធានាថាគ្មានការបំពានលើសិទ្ធិលើភាគបម្រុងរបស់សន្តតិជន ហៅថា **ភាគបម្រុង**។[44] ភាគបម្រុង សំដៅទៅ ចំណែកមួយដែលត្រូវបានច្បាប់បម្រុងទុកឱ្យអ្នកដែលមានសិទ្ធិលើភាគបម្រុង។ ភាគបម្រុង ត្រូវរាប់បញ្ចូលទាំងមត៌ក និងទ្រព្យសម្បត្តិមួយចំនួនដែលមានមុនពេលមរណភាពរបស់មតកជន ដូចជាប្រទានកម្ម និងតម្លៃនៃផលប្រយោជន៍ពិសេស ដោយហេតុថា ប្រសិនបើទ្រព្យសម្បត្តិដែលជាមូលដ្ឋានសម្រាប់គណនាភាគបម្រុងនេះត្រូវបានកំណត់ត្រឹមមត៌ក នោះអាចមានករណីមួយចំនួន ដែលមតកជនគាត់អាចចាត់ចែងទ្រព្យសម្បត្តិបានតាមរយៈប្រទានកម្មជាដើម ដែលអាចធ្វើឱ្យប៉ះពាល់ដល់ចំណែករបស់សន្តតិជន។[45] សហព័ទ្ធមានសិទ្ធិលើភាគបម្រុងជានិច្ច។ បើមានសន្តតិជនលំដាប់ទី១ ជាអ្នកមានសិទ្ធិលើភាគបម្រុង នោះសន្តតិជនលំដាប់ទី២ មិនមានសិទ្ធិនេះឡើយ។

**ក្រមរដ្ឋប្បវេណីកម្ពុជា បានកំណត់អ្នកមានសិទ្ធិលើភាគបម្រុង រួមមាន៖**

- បច្ឆាញាតិផ្ទាល់ ឬសន្តតិជនជំនួសរបស់ខ្លួន
- ឪពុកម្តាយ និងជីដូនជីតា
- សហព័ទ្ធ។

**ឯចំណែកនៃភាគបម្រុងត្រូវបានកំណត់ដូចខាងក្រោម៖**

- ១ ភាគ ៣ នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីដែលមានតែសន្តតិជនជាឪពុកម្តាយ ឬជីដូនជីតាប៉ុណ្ណោះ
- ១ ភាគ ២ នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីផ្សេង។
- ប្រសិនបើសន្តតិជនមានច្រើននាក់ នោះអ្នកមានសិទ្ធិលើភាគបម្រុងអាចទទួលបានភាគបម្រុងតាមសមាមាត្រនៃចំណែកមត៌ករបស់ខ្លួន[46]

---

[44] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា ១២៣០
[45] ប៊ុន វិទូ និង ឡេង ពុទ្ធិតារា, "យល់ដឹងផ្នែកច្បាប់៖ របបភាគបម្រុង" , ដកស្រង់ពីគំណរវេបសាយ៖ http://ciclg.com/en/article/235
[46] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១២៣០

**ករណីសិក្សាទី១** ៖ លោក A ជាមតកជនបានទទួលមរណភាព ឆ្នាំ២០២០។ លោក A មានសហព័ទ្ធ B និងកូនចំនួន ៤នាក់ ឈ្មោះ C D E និង F។ លោក A គឺជាកូនបំណុលនៃ Z ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ដែលសិទ្ធិលើបំណុលមិនទាន់បានសងមានចំនួន USD 250,000។ លោក A កាលនៅរស់ធ្លាប់ធ្វើប្រទានកម្មឱ្យលោក D នូវទឹកប្រាក់ចំនួន USD ៤៣,000 ដើម្បីបើកអាជីវកម្ម។ លោក A ធ្លាប់បានធ្វើប្រទានកម្មជូន ឱពុក X នូវប្រាក់ចំនួន USD ២៥,000 កាលពី ៦ ខែមុនពេលគាត់ទទួលមរណភាព។ នៅពេលចាប់ផ្តើមសន្តតិកម្ម លោក A មានទ្រព្យសម្បត្តិដូចខាងក្រោម ៖

ដី L1 តម្លៃ USD 120,000

ដី L2 តម្លៃ USD 250,000

ផ្ទះមួយខ្នង តម្លៃ USD 350,000

ភាគហ៊ុននៃក្រុមហ៊ុន ក ខ គ តម្លៃ USD 200,000

កាលនៅរស់ លោក A បានធ្វើមតកសាសន៍ក្រោមទម្រង់លិខិតយថាភូត ដែលមានខ្លឹមសារ ៖

ឱ្យ ដី L1 ទៅ C

ឱ្យ ដី L2 ទៅ E

ឱ្យផ្ទះ និងភាគហ៊ុន ទៅ F។

**<u>សំនួរ</u>**

១. ចូរអ្នកគណនាសិទ្ធិលើភាគបម្រុងរបស់សន្តតិជននីមួយៗ។

២. ផ្អែកតាមអង្គហេតុខាងលើ តើមានសន្តតិជនណាខ្លះដែលត្រូវបានគេបំពានភាគបម្រុង និងថាតើភាគបម្រុងដែលត្រូវបានបំពានមានចំនួនប៉ុន្មាន?

ចម្លើយ៖

លោក A គឺជាកូនបំណុលនៃ Z ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ដែលសិទ្ធិលើបំណុលមិនទាន់បានសងមានចំនួន USD 250,000

លោក A កាលនៅរស់ធ្លាប់ធ្វើប្រទានកម្មឱ្យលោក D នូវទឹកប្រាក់ចំនួន USD ៤៣,០០០ ដើម្បីបើកអាជីវកម្ម។

លោក A ធ្លាប់បានធ្វើប្រទានកម្មជូន ឪពុក X នូវប្រាក់ចំនួន USD ២៥,០០០ កាលពី ៦ ខែមុនពេលគាត់ទទួលមរណភាព។

នៅពេលចាប់ផ្តើមសន្តតិកម្ម លោក A មានទ្រព្យសម្បត្តិដូចខាងក្រោម ៖

ដី L1 តម្លៃ USD 120,000

ដី L2 តម្លៃ USD 250,000

ផ្ទះមួយខ្នង តម្លៃ USD 350,000

ភាគហ៊ុននៃក្រុមហ៊ុន ក ខ គ តម្លៃ USD 200,000

កាលនៅរស់ លោក A បានធ្វើមតកសាសន៍ក្រោមទម្រង់លិខិតយថាភូត ដែលមានខ្លឹមសារ ៖

ឱ្យ ដី L1 ទៅ C

ឱ្យ ដី L2 ទៅ E

ឱ្យផ្ទះ និងភាគហ៊ុន ទៅ F។

១. គណនាសិទ្ធិលើភាគបម្រុងរបស់សន្តតិជននីមួយៗ

ជំហានទី១

- ទ្រព្យជាមូលដ្ឋាន

ទ្រព្យជាមូលដ្ឋាន = ទ្រព្យពេលចាប់ផ្តើមសន្តតិកម្ម + ផលប្រយោជន៍ពិសេស + ប្រទានកម្ម - កាតព្វកិច្ច

⇨ ១២០,០០០ + ២៥០,០០០ + ៣៥០,០០០ + ២០០,០០០ + ៤៣,០០០ + ២៥,០០០ - ២៥០,០០០ = ៧៣៨,០០០

ជំហានទី២

- សិទ្ធលើភាគបម្រុងសរុប

សិទ្ធលើភាគបម្រុងសរុប = ទ្រព្យជាមូលដ្ឋាន x ១/២ ឬ ១/៣

⇨ ៧៣៨,000 x ១/២

= ៣៦៩,000

ជំហានទី៣

- ការគណនាសិទ្ធិលើភាគបម្រុងនៃសន្តតិជននីមួយៗ

សិទ្ធិលើភាគបម្រុងរបស់សន្តតិជន = សិទ្ធិលើភាគបម្រុងសរុប x ចំណែកមត៌កតាមច្បាប់របស់សន្តតិជន

ដូចនេះសិទ្ធិលើភាគបម្រុងនៃសន្តតិជននីមួយៗ

⇨ សិទ្ធិលើភាគបម្រុងរបស់សន្តតិជន B = ៣៦៩,000 x ១/៥ = USD ៧៣,៨00

⇨ សិទ្ធិលើភាគបម្រុងរបស់សន្តតិជន C = ៣៦៩,000 x ១/៥ = USD ៧៣,៨00

⇨ សិទ្ធិលើភាគបម្រុងរបស់សន្តតិជន D = ៣៦៩,000 x ១/៥ = USD ៧៣,៨00

⇨ សិទ្ធិលើភាគបម្រុងរបស់សន្តតិជន E = ៣៦៩,000 x ១/៥ = USD ៧៣,៨00

⇨ សិទ្ធិលើភាគបម្រុងរបស់សន្តតិជន F = ៣៦៩,000 x ១/៥ = USD ៧៣,៨00

២. សន្តតិជនដែលត្រូវបានគេបំពានភាគបម្រុង

<u>សន្តតិជន B</u>

- ការគណនានូវអត្ថភាព ឬ នត្ថិភាពនៃការបំពានភាគបម្រុង ចំនួនទឹកប្រាក់ដែលបានដោយសារសន្តតិកម្ម

ចំនួនទឹកប្រាក់ដែលបានដោយសារសន្តតិកម្ម = 0

តម្លៃនៃការទទួលផលប្រយោជន៍ពិសេស = 0

តម្លៃកាតព្វកិច្ចសន្តតិកម្ម = ២៥0,000 x ១/៥ = USD ៥0,000

ចំនួនទឹកប្រាក់នៃភាគបម្រុង > ចំនួនទឹកប្រាក់ដែលបានដោយសារសន្តតិកម្ម + តម្លៃនៃការទទួលផលប្រយោជន៍ពិសេស - តម្លៃកាតព្វកិច្ចសន្តតិកម្ម

⇨ ៧៣,៨00 > -៥0,000

ដូចនេះ B ត្រូវបានគេបំពានភាគបម្រុង

- គណនាចំនួនទឹកប្រាក់ដែលបានបំពាន

ចំនួនទឹកប្រាក់នៃភាគបម្រុង - ចំនួនទឹកប្រាក់នៃទ្រព្យដែលបានដោយសារសន្តតិកម្ម - តម្លៃនៃការទទួលផលប្រយោជន៍ពិសេស + តម្លៃកាតព្វកិច្ចសន្តតិកម្ម

⇨ ៧៣,៨០០ - 0 - 0 + ៥0,000

= ១២៣,៨០០

ដូចនេះ ចំនួនដែលបានបំពាន= USD ១២៣,៨០០

<u>សន្តតិជន C</u>

- ការគណនានូវអត្ថភាព ឬ នត្ថិភាពនៃការបំពានភាគបម្រុង

ចំនួនទឹកប្រាក់ដែលបានដោយសារសន្តតិកម្ម = ដី L1 តម្លៃ USD 120,000 ទៅC

តម្លៃនៃការទទួលផលប្រយោជន៍ពិសេស = 0

តម្លៃកាតព្វកិច្ចសន្តតិកម្ម = ២៥0,000 x ១/៥ = ៥0,000

ចំនួនទឹកប្រាក់នៃភាគបម្រុង > ចំនួនទឹកប្រាក់ដែលបានដោយសារសន្តតិកម្ម + តម្លៃនៃការទទួលផលប្រយោជន៍ពិសេស - តម្លៃកាតព្វកិច្ចសន្តតិកម្ម

⇨ ២៤,៦០០ > ១២0,000 - ៥0,000

⇨ ២៤,៦០០ < ៧0,000

ដូចនេះ C មិនត្រូវបានគេបំពានភាគបម្រុង

<u>សន្តតិជន D</u>

- ការគណនានូវអត្ថភាព ឬ នត្ថិភាពនៃការបំពានភាគបម្រុង

ចំនួនទឹកប្រាក់ដែលបានដោយសារសន្តតិកម្ម = 0

តម្លៃនៃការទទួលផលប្រយោជន៍ពិសេស = លោក A កាលនៅរស់ធ្លាប់ធ្វើប្រទានកម្មឱ្យលោក D នូវទឹកប្រាក់ចំនួន USD ៤៣,000 ដើម្បីបើកអាជីវកម្ម

តម្លៃកាតព្វកិច្ចសន្តតិកម្ម = ២៥0,000 x ១/៥ = ៥0,000

ចំនួនទឹកប្រាក់នៃភាគបម្រុង > ចំនួនទឹកប្រាក់ដែលបានដោយសារសន្តតិកម្ម + តម្លៃនៃការទទួលផលប្រយោជន៍ពិសេស - តម្លៃកាតព្វកិច្ចសន្តតិកម្ម

⇨ ៧៣,៨០០ > ៤៣,000 - ៥០,000

⇨ ៧៣,៨០០ > -៧,000

ដូចនេះ D ត្រូវបានគេបំពានភាគបម្រុង

- គណនាចំនួនទឹកប្រាក់ដែលបានបំពាន

ចំនួនទឹកប្រាក់នៃភាគបម្រុង - ចំនួនទឹកប្រាក់នៃទ្រព្យដែលបានដោយសារសន្តតិកម្ម - តម្លៃនៃការទទួលផលប្រយោជន៍ពិសេស + តម្លៃកាតព្វកិច្ចសន្តតិកម្ម

⇨ ៧៣,៨០០ - ៤៣,000 + ៥០,000

= ៨០,៨០០

ដូចនេះ ចំនួនដែលបានបំពាន= USD ៨០,៨០០

<u>សន្តតិជន E</u>

- ការគណនានូវអត្ថភាព ឬ នត្ថិភាពនៃការបំពានភាគបម្រុង

ចំនួនទឹកប្រាក់ដែលបានដោយសារសន្តតិកម្ម = ដី L2 តម្លៃ USD 250,000

តម្លៃនៃការទទួលផលប្រយោជន៍ពិសេស = 0

តម្លៃកាតព្វកិច្ចសន្តតិកម្ម = ២៥០,000 x ១/៥ = ៥០,000

ចំនួនទឹកប្រាក់នៃភាគបម្រុង > ចំនួនទឹកប្រាក់ដែលបានដោយសារសន្តតិកម្ម + តម្លៃនៃការទទួលផលប្រយោជន៍ពិសេស - តម្លៃកាតព្វកិច្ចសន្តតិកម្ម

⇨ ៧៣,៨០០ > ២៥០,000 - ៥០,000

⇨ ៧៣,៨០០ < ២០០,000

ដូចនេះ E មិនត្រូវបានគេបំពានភាគបម្រុងទេ

<u>សន្តតិជន F</u>

- ការគណនានូវអត្ថភាព ឬ នត្ថិភាពនៃការបំពានភាគបម្រុង

ចំនួនទឹកប្រាក់ដែលបានដោយសារសន្តតិកម្ម = ផ្ទះមួយខ្នង តម្លៃ USD 350,000, ភាគហ៊ុននៃក្រុមហ៊ុន តម្លៃ USD 200,000

តម្លៃនៃការទទួលផលប្រយោជន៍ពិសេស = 0

តម្លៃកាតព្វកិច្ចសន្តតិកម្ម = ២៥០,០០០ x ១/៥ = ៥០,០០០

ចំនួនទឹកប្រាក់នៃភាគបម្រុង > ចំនួនទឹកប្រាក់ដែលបានដោយសារសន្តតិកម្ម + តម្លៃនៃការទទួលផលប្រយោជន៍ពិសេស - តម្លៃកាតព្វកិច្ចសន្តតិកម្ម

⇨ ៧៣,៨០០ > ៣៥០,០០០ + ២០០,០០០ - ៥០,០០០

⇨ ៧៣,៨០០ < ៥០០,០០០

ដូចនេះ F មិនត្រូវបានគេបំពានភាគបម្រុងទេ

**ករណីសិក្សាទី២** ៖ លោក A ជាមតកជនបានទទួលមរណភាពឆ្នាំ២០២១។ លោក A មានសហព័ទ្ធម្នាក់ឈ្មោះ B និង ឪពុកម្តាយបង្កើតឈ្មោះ X និង Y។ នៅឆ្នាំ ២០១២ លោក O និង លោកស្រី P បានសុំលោក A ធ្វើជាកូនចិញ្ចឹម និងបានសុំកូនធម្មតាជាមួយនឹងលោក A ត្រឹមត្រូវតាមនីតិវិធីច្បាប់។ កាលនៅរស់ លោក A ធ្លាប់ធ្វើប្រទានកម្មឱ្យលោក X នូវប្រាក់ចំនួន USD 23,000។ លោក A ធ្លាប់មានទំនាក់ទំនងលួចលាក់ជាមួយកញ្ញា S និងបានផ្ទេរដីមួយកន្លែងតម្លៃ USD 50,000 កាលពីខែកុម្ភៈ ឆ្នាំ២០២១។ លោក A ជាកូនបំណុលនៃ លោក Z នូវទឹកប្រាក់ចំនួន USD 300,000។

នៅពេលលោក A ទទួលមរណភាព លោក A មានទ្រព្យសម្បត្តិដូចខាងក្រោម ៖

| | |
|---|---|
| ដី L1 | តម្លៃ USD 150,000 |
| ដី L2 | តម្លៃ USD 350,000 |
| ដី L3 | តម្លៃ USD 650,000 |
| ផ្ទះវីឡាមួយខ្នង | តម្លៃ USD 900,000 |
| រថយន្តទំនើប | តម្លៃ 780,000 |

លោក A បានធ្វើមតកសាសន៍ដែលមានខ្លឹមសារកំណត់ចំណែកមត៌កដូចខាងក្រោម ៖

ដី L1 តម្លៃ USD 150,000 ឱ្យ B

ដី L2 តម្លៃ USD 350,000 ឱ្យ X

ដី L3 តម្លៃ USD 650,000 ឱ្យ Y

ផ្ទះវីឡាមួយខ្នង តម្លៃ USD 900,000 ឱ្យ Y

រថយន្តទំនើប តម្លៃ 780,000 ឱ្យ X

**<u>សំនួរ</u>**

១. ចូរអ្នកគណនាសិទ្ធិលើភាគបម្រុងរបស់សន្តតិជននីមួយៗ។

២. ផ្អែកតាមអង្គហេតុខាងលើ តើមានសន្តតិជនណាខ្លះដែលត្រូវបានគេបំពានភាគបម្រុង និងថាតើភាគបម្រុងដែលត្រូវបានបំពានមានចំនួនប៉ុន្មាន?

ចម្លើយ៖

កាលនៅរស់ លោក A ធ្លាប់ធ្វើប្រទានកម្មឱ្យលោក X នូវប្រាក់ចំនួន USD 23,000។ លោក A ធ្លាប់មានទំនាក់ទំនងលួចលាក់ជាមួយកញ្ញា S និងបានផ្ទេរដីមួយកន្លែងតម្លៃ USD 50,000 កាលពីខែកុម្ភៈ ឆ្នាំ២០២១។ លោក A ជាកូនបំណុលនៃ លោក Z នូវទឹកប្រាក់ចំនួន USD 300,000។

នៅពេលលោក A ទទួលមរណភាព លោក A មានទ្រព្យសម្បត្តិដូចខាងក្រោម ៖

ដី L1 តម្លៃ USD 150,000

ដី L2 តម្លៃ USD 350,000

ដី L3 តម្លៃ USD 650,000

ផ្ទះវីឡាមួយខ្នង តម្លៃ USD 900,000

រថយន្តទំនើប តម្លៃ 780,000

លោក A បានធ្វើមតកសាសន៍ដែលមានខ្លឹមសារកំណត់ចំណែកមត៌កដូចខាងក្រោម ៖

ដី L1 តម្លៃ USD 150,000 ឱ្យ B

ដី L2 តម្លៃ USD 350,000 ឱ្យ X

ដី L3 តម្លៃ USD 650,000 ឱ្យ Y

ផ្ទះវីឡាមួយខ្នង តម្លៃ USD 900,000 ឱ្យ Y

រថយន្តទំនើប តម្លៃ 780,000 ឱ្យ X

១. គណនាសិទ្ធិលើភាគបម្រុងរបស់សន្តតិជននីមួយៗ

ជំហានទី១

- ទ្រព្យជាមូលដ្ឋាន

ទ្រព្យជាមូលដ្ឋាន = ទ្រព្យពេលចាប់ផ្តើមសន្តតិកម្ម + ផលប្រយោជន៍ពិសេស + ប្រទានកម្ម - កាតព្វកិច្ច

⇨ ១៥០,០០០ + ៣៥០,០០០ + ៦៥០,០០០ + ៩០០,០០០ + ៧៨០,០០០ + ២៣,០០០ + ៥០,០០០ - ៣០០,០០០ = ២,៦០៣,០០០

ជំហានទី២

- សិទ្ធលើភាគបម្រុងសរុប

សិទ្ធលើភាគបម្រុងសរុប = ទ្រព្យជាមូលដ្ឋាន x ១/២ ឬ ១/៣

⇨ ២,៦០៣,០០០ x ១/៣

= ៨៦៧,៦៦៦.៦៦៧

ជំហានទី៣

- ការគណនាសិទ្ធិលើភាគបម្រុងនៃសន្តតិជននីមួយៗ

សន្តតិជនមានដូចជា B X Y ឯ O P មិនអាចក្លាយជាបុព្វញាតិផ្ទាល់របស់ A ទេ ព្រោះការសុំមកចិញ្ចឹមនោះគ្រាន់ជាការសុំកូនធម្មតា (មាត្រា ១០២០)

សិទ្ធិលើភាគបម្រុងរបស់សន្តតិជន = សិទ្ធិលើភាគបម្រុងសរុប x ចំណែកមត៌កតាមច្បាប់របស់សន្តតិជន

ដូចនេះសិទ្ធិលើភាគបម្រុងនៃសន្តតិជននីមួយៗ

⇨ សិទ្ធិលើភាគបម្រុងរបស់សន្តតិជន B = ៨៦៧,៦៦៦.៦៦៧ x ១/៣ = ២៨៩,២២២.២២២

⇨ សិទ្ធិលើភាគបម្រុងរបស់សន្តតិជន X = ៨៦៧,៦៦៦.៦៦៧ x ១/៣ = ២៨៩,២២២.២២២

⇨ សិទ្ធិលើភាគបម្រុងរបស់សន្តតិជន Y = ៨៦៧,៦៦៦.៦៦៧ x ១/៣ = ២៨៩,២២២.២២២

២. សន្តតិជនដែលត្រូវបានគេបំពានភាគបម្រុង

<u>សន្តតិជន B</u>

- ការគណនានូវអត្ថភាព ឬ នត្ថិភាពនៃការបំពានភាគបម្រុង

ចំនួនទឹកប្រាក់ដែលបានដោយសារសន្តតិកម្ម = ដី L1 តម្លៃ USD 150,000

តម្លៃនៃការទទួលផលប្រយោជន៍ពិសេស = 0

តម្លៃកាតព្វកិច្ចសន្តតិកម្ម = ៣០០,០០០ x ១/៣ = ១០០,០០០

ចំនួនទឹកប្រាក់នៃភាគបម្រុង > ចំនួនទឹកប្រាក់ដែលបានដោយសារសន្តតិកម្ម +

តម្លៃនៃការទទួលផលប្រយោជន៍ពិសេស - តម្លៃកាតព្វកិច្ចសន្តតិកម្ម

⇨ ២៨៩,២២២.២២២ > ១៥០,០០០ + 0 - ១០០,០០០

⇨ ២៨៩,២២២.២២២ > ៥០,០០០

ដូចនេះ B ត្រូវបានគេបំពានភាគបម្រុង

- គណនាចំនួនទឹកប្រាក់ដែលបានបំពាន

ចំនួនទឹកប្រាក់នៃភាគបម្រុង - ចំនួនទឹកប្រាក់នៃទ្រព្យដែលបានដោយសារសន្តតិកម្ម - តម្លៃនៃការទទួលផលប្រយោជន៍ពិសេស + តម្លៃកាតព្វកិច្ចសន្តតិកម្ម

⇨ ២៨៩,២២២.២២២ - ១៥០,០០០ - 0 + ១០០,០០០

= ២៣៩,២២២.២២២

ដូចនេះ ចំនួនដែលបានបំពាន= USD ២៣៩,២២២.២២២

<u>សន្តតិជន X</u>

- ការគណនានូវអត្ថភាព ឬ នត្ថិភាពនៃការបំពានភាគបម្រុង

ចំនួនទឹកប្រាក់ដែលបានដោយសារសន្តតិកម្ម = ដី L2 តម្លៃ USD 350,000 ឱ្យ X, រថយន្តទំនើប តម្លៃ 780,000 ឱ្យ X

តម្លៃនៃការទទួលផលប្រយោជន៍ពិសេស = កាលនៅរស់ លោក A ធ្លាប់ធ្វើប្រទានកម្មឱ្យលោក X នូវប្រាក់ចំនួន USD 23,000

តម្លៃកាតព្វកិច្ចសន្តតិកម្ម = ៣០០,០០០ x ១/៣ = ១០០,០០០

ចំនួនទឹកប្រាក់នៃភាគបម្រុង > ចំនួនទឹកប្រាក់ដែលបានដោយសារសន្តតិកម្ម + តម្លៃនៃការទទួលផលប្រយោជន៍ពិសេស - តម្លៃកាតព្វកិច្ចសន្តតិកម្ម

⇨ ២៨៩,២២២.២២២ > ៣៥០,០០០ + ៧៨០,០០០ + ២៣,០០០ - ១០០,០០០

⇨ ២៨៩,២២២.២២២ < ១,០៥៣,០០០

ដូចនេះ X មិនត្រូវបានគេបំពានភាគបម្រុងទេ

<u>សន្តតិជន Y</u>

- ការគណនានូវអត្ថភាព ឬ នត្ថិភាពនៃការបំពានភាគបម្រុង

ចំនួនទឹកប្រាក់ដែលបានដោយសារសន្តតិកម្ម = ដី L3 តម្លៃ USD 650,000 ឱ្យ Y, ផ្ទះវីឡាមួយខ្នង តម្លៃ USD 900,000 ឱ្យ Y

តម្លៃនៃការទទួលផលប្រយោជន៍ពិសេស = 0

តម្លៃកាតព្វកិច្ចសន្តតិកម្ម = ៣00,000 x ១/៣ = ១00,000

ចំនួនទឹកប្រាក់នៃភាគបម្រុង > ចំនួនទឹកប្រាក់ដែលបានដោយសារសន្តតិកម្ម +

តម្លៃនៃការទទួលផលប្រយោជន៍ពិសេស - តម្លៃកាតព្វកិច្ចសន្តតិកម្ម

⇨ ២៨៩,២២២.២២២ > ៦៥0,000 + ៩00,000 - ១00,000

⇨ ២៨៩,២២២.២២២ < ១,៤៥0,000

ដូចនេះ Y មិនត្រូវបានគេបំពានភាគបម្រុងទេ

## ២.២ ការរៀបចំបែងចែកមត៌ក

មាត្រា ១២៦៧._ មូលដ្ឋាននៃការបែងចែក

១-បើពុំបានកំណត់វិធីបែងចែកនៅក្នុងមតកសាសន៍ទេ ការបែងចែកមត៌កនេះ ត្រូវធ្វើដោយពិចារណាទៅលើប្រភេទ និង លក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលមាននៅក្នុងមត៌ក ឬ អាយុ មុខរបរ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត ស្ថានភាពជីវភាព របស់សហសន្តតិជន នីមួយៗ និង ស្ថានភាពផ្សេងទៀត ។

២-ក្នុងករណីដែលការបែងចែកបណ្តាលឱ្យ មានការខូចខាតធ្ងន់ធ្ងរដល់តម្លៃ បើយល់ឃើញថាសមរម្យ សហសន្តតិជនអាចឱ្យសហសន្តតិជនណាម្នាក់ ធ្វើលទ្ធកម្មទ្រព្យសម្បត្តិនោះបាន ដោយដាក់លក្ខខ័ណ្ឌឱ្យ បង់ប្រាក់សម្រួល ចំពោះសហសន្តតិជនផ្សេងទៀត តាមការពិភាក្សា ។

សហសន្តតិជនត្រូវពិចារណាដល់ចំណុចដែលមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ ក្នុងអំឡុងពេលដែលធ្វើការពិភាក្សា បែងចែកមត៌ក។ ក្នុងករណីដែលខ្លឹមសារនៃការព្រមព្រៀង ក្រោយពីការពិភាក្សានេះ ខុសនឹងគោលគំនិតនៃមាត្រានេះក៏មិនចោតជាបញ្ហាធំដែរ តែដាច់ខាតមិនត្រូវផ្ទុយពីសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អទេ។

ក្នុងករណីដែល ការបែងចែកបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់តម្លៃ វិធីបែងចែកតាមវិធីបង់ប្រាក់សម្រួលត្រូវបានយកមកប្រើប្រាស់។ ការបង់ប្រាក់សម្រួលអនុវត្តចំពោះតែករណីដែលតុលាការជាអ្នកធ្វើការបែងចែកមត៌កប៉ុណ្ណោះ។[47] គោលគំនិតបញ្ញត្តិនៃមានអត្ថន័យគឺមានភាពស្រដៀងទៅនឹងការបែងចែកវត្ថុកម្មសិទ្ធិអវិភាគផងដែរ។[48] យ៉ាងណាមិញ បើសហសន្តតិជនបានព្រមព្រៀង ដោយស្ម័គ្រចិត្ត នោះសន្តតិជនទាំងអស់អាចពិភាក្សា ដោយឱ្យជនណាម្នាក់ទទួលមត៌កនោះតែឯង ហើយជននោះបង់ប្រាក់សម្រួលទៅឱ្យសហសន្តតិជនផ្សេងទៀតបាន ។[49]

---

[47] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១២៧០

[48] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា២១២

[49] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា ១២៦៧

### ២.២.១ ការពិភាក្សាបែងចែកមត៌ក

ការបែងចែកមត៌កមានពីរប្រភេទគឺ ការបែងចែកដោយការពិភាក្សារវាងសហសន្តតិជន និងការបែងចែកដោយតុលាការ។[50] ជាគោលការណ៍ ការបែងចែកមត៌ក មត៌កអាចធ្វើការបែងចែកទៅតាមពិភាក្សា និងព្រមព្រៀងរបស់សហសន្តតិជនទាំងអស់។ ប៉ុន្តែប្រសិនបើការពិភាក្សានោះពុំទទួលនូវលទ្ធផលល្អទេ ដោយមិនបានការយល់ព្រម ឯកភាព ឬព្រមព្រៀងគ្នានោះទេ តុលាការគឺជាអ្នកមានសមត្ថកិច្ចក្នុងការបែងចែកមត៌កនោះ ។

#### ២.២.១.១ ការពិភាក្សារវាងសហសន្តតិជន

ការបែងចែកមត៌ក ជាក់ស្តែងទៅអាចជាការដោះដូរទៅវិញទៅមករវាងសន្តតិជនទាំងអស់ នូវចំណែកនៃកម្មសិទ្ធិអវិភាគរបស់សាមីខ្លួនម្នាក់ៗ ចំពោះទ្រព្យសម្បត្តិ ដែលជាកម្មសិទ្ធិអវិភាគនេះ រួចប្តូរកម្មសិទ្ធអវិភាគនោះអោយទៅជា កម្មសិទ្ធិឯករាជ្យដោយឡែករបស់សហសន្តតិជនម្នាក់ ឬ ជាកម្មសិទ្ធិអវិភាគរបស់សហសន្តតិជនកំណត់មួយ។ យោងតាមមាត្រា ១១៤៨ នៅពេលដែលសន្តតិជនមានចំនួនច្រើននាក់ គេចាត់ទុកទ្រព្យទាំងអស់ជាកម្មសិទ្ធិអវិភាគ របស់សហសន្តតិជន ជាមុនសិន ទើប គេប្រើប្រាស់នីតិវិធីនៃការបែងចែកមត៌កដោយធ្វើការផ្ទេរចុងក្រោយនូវមត៌កដល់សន្តតិជន។ ព្រមគ្នានេះដែរ ជំលោះពាក់ព័ន្ធបញ្ហាសន្តតិកម្មច្រើនកើតឡើងនៅពេលបែងចែកមត៌កនេះ។ អាស្រ័យហេតុនេះហើយ ចាំបាច់ត្រូវការមានការពិភាក្សារវាងសហសន្តតិជនទាំងអស់។

ឧទាហរណ៍ ៖ ក្នុងករណីដែលសហសន្តតិជនអាចរៀបចំឱ្យមានការពិភាក្សា ការបែងចែកដីដែលជាសន្តតិកម្មរួមអាចនឹងធ្វើទៅតាមការសម្រេចរបស់សន្តតិជនទាំងអស់គ្នា ដោយពុំចាំបាច់ចែកជាឡូត៍ដីនោះទេ នោះគេអាចទុក ដដែលសម្រាប់ប្រើប្រាស់រួមគ្នា ស្របតាមចំណែកមត៌កក៏បានដែរ។ មតកជនក៏អាចកំណត់នូវវិធីជាក់លាក់សម្រាប់បែងចែកមត៌កបានដែរ នៅក្នុងមតកសាសន៍របស់ខ្លួនដូចមាន អធិប្បាយនៅខាងក្រោមនេះ។[51] ការបែងចែកមត៌កដោយតុលាការ គឺត្រូវធ្វើឡើងដោយផ្អែកតាមនីតិវិធីសវនាការ របស់តុលាការគ្រួសារ ។

ទោះបី អ្នកដែលបានទទួលផលប្រយោជន៍ពិសេសមានចំនួនច្រើន ដោយយោងតាម មាត្រា ១១៦៣ កថាខណ្ឌទី ២ ក៏ដោយការពិភាក្សាបែងចែកមត៌កចាំបាច់ឱ្យសន្តតិជននោះចូលរួម ក្នុងគោលបំណង ឱ្យសន្តតិជនទាំងនោះបញ្ជាក់អំពីការណ៍នេះដែរ។ ក្នុងរយៈពេលមួយខែក្រោយពីការចាប់ផ្តើមសន្តតិកម្ម សហសន្តតិជនអាចពិភាក្សាគ្នាអំពីការបែងចែកមត៌កពេលណាក៏បានដែរ។ នេះគឺគេផ្តល់ពេលវេលាអោយបងប្អូ

[50] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១២៧០
[51] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩០៨

នផ្តល់ការគោរពចំពោះវិញ្ញាណក្ខន្ធមតកជន ជាមុនសិន មិនមែនមតកជនទទួលមរណភាពភ្លាម សន្តតិជននាំគ្នាត្រូវតែពិភាក្សារឿងមត៌កតែម្តងនោះទេ។ ជាក់ស្តែង យើងត្រូវស្វែងរកសហសន្តតិជន (ករណីដូចជាមតកជនមានកូន ពីអាពាហ៍ពិពាហ៍ពីមុន ឬទេ ឬ មានកូនដែលខ្លួនបាន ទទួលស្គាល់ឬទេ?) ហើយដំណាក់កាលបន្ទាប់គឺតើសហសន្តតិជនយល់ព្រម ឬ បោះបង់សន្តតិកម្ម រួចទើបយើងអាចកំណត់នូវទំហំនៃសហសន្តតិជន បន្ទាប់មកទើបអាចមានការពិភាក្សារវាងសហសន្តតិជនដើម្បីបែងចែកមត៌ក ដូច្នេះពេលវេលាត្រូវការច្រើនសមរម្យដែរ។

ក្នុងករណីកសិផលវិញ អាចនឹងមានការខូចខាតប្រសិនបើមិនបានថែទាំ នោះអ្នកគ្រប់គ្រងមត៌កអាចលក់ប្តូរជាប្រាក់បាន ហើយ ទឹកប្រាក់ដែលបានពីកសិផលនេះ គឺជាកម្មវត្ថុនៃការបែងចែកមត៌ក។[52] បន្ថែមពីនេះទៅទៀត ប្រសិនបើការពិភាក្សាទទួលលទ្ធផលល្អក៏ដោយ ក្នុងអំឡុងពេលដែលបានឃាត់នោះគេមិនអាចប្តូរឈ្មោះពីមតកជនទៅឱ្យសន្តតិជនទេ ក្នុងគោលបំណងការពារម្ចាស់បំណុលរបស់មតកជន។[53] ក្នុងករណីដែលមតកជនអាចហាមឃាត់មិនឱ្យធ្វើការបែងចែក មត៌កក្នុងអំឡុងពេលក្រោម ៥ ឆ្នាំដោយធ្វើការផ្អែកលើមាត្រា១១៨៣[54] នោះ ការបែងចែកមត៌កមិនអាចធ្វើទៅបានទេ នៅក្នុងអំឡុងពេលដែលមតកជនបានហាមឃាត់បានឡើយ។[55]

សហសន្តតិជន ដូចដែលបានបរិយាយខាងលើ មិនអាច ដាក់ពាក្យសុំទៅតុលាការដើម្បីធ្វើសម្រេចសេចក្តីអំពីការបែងចែកមត៌កនោះទេ យ៉ាងណាមិញ សហសន្តតិជនទាំងអស់អាចធ្វើការពិភាក្សា ព្រមព្រៀងគ្នាពាក់ព័ន្ធនឹងការបែងចែកមត៌ក ដោយពុំទាក់ទងនឹងមតកសាសន៍ ក្នុងអំឡុងពេលមួយខែ ក្រោយមតកជនបានមរណភាព បានន័យថា ការសម្រួលត្រូវបានអនុញ្ញាត។

មាត្រា ១២៧៤._ ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក

ក្នុងករណីដែលជនដែលបានក្លាយជាសន្តតិជន ដោយសារជននោះត្រូវបានទទួលស្គាល់ ក្រោយពេលមតកជនបានទទួលមរណភាពមានបំណងទាមទារឱ្យបែងចែកមត៌ក បើសហសន្តតិជនផ្សេងទៀត បានបែងចែកមត៌ក ឬ បានធ្វើការចាត់ចែងផ្សេងទៀតចំពោះមត៌ក ជននោះមានសិទ្ធិទាមទារឱ្យសងដោយតម្លៃតែប៉ុណ្ណោះ ។

[52] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១២៦២

[53] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១២៦៦ថ្មី, ១២៧៧

[54] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៨៣

[55] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១២៦៦ថ្មី

ក្នុងករណីដែលការទទួលស្គាល់ក្រោយមរណភាពរបស់មតកជន ត្រូវបានធ្វើឡើងក្រោយការបែងចែកមត៌ក ដោយសារតែការពិភាក្សាដើម្បីបែងចែកមត៌ក ត្រូវបានធ្វើឡើងដោយមានវត្តមានរបស់សហសន្តតិជនទាំងអស់នៅពេលនោះ ដូច្នេះ ការពិភាក្សានោះមានសុពលភាព។

ប្រសិនបើមានករណីដែលមតកជនបានទទួលស្គាល់ជាកូនមុនខ្លួនទទួលមរណភាព តែសន្តតិជនដទៃមិនបានដឹងលឺ ហើយមិនបានរាប់ជនដែលត្រូវបានទទួលស្គាល់ពេលដែល ពិភាក្សាបែងចែកមត៌ក ឬ ក្នុងករណីដែលការទទួលស្គាល់ក្រោយមរណភាពរបស់មតកជនត្រូវបានធ្វើឡើងមុនការបែងចែកមត៌ក ក៏ប៉ុន្តែ សន្តតិជនផ្សេងទៀតមិនបានយកចិត្តទុកដាក់ដោយមិនឱ្យជននោះចូលរួមក្នុងការបែងចែក ដូច្នេះការបែងចែកនោះមោឃៈព្រោះពុំមានវត្តមានរបស់សន្តតិជនទាំងអស់ទេ។ កូនដែលត្រូវបានទទួលស្គាល់ អាចទាមទារចំពោះសន្តតិជនផ្សេងទៀត ឱ្យធ្វើការបែងចែកមត៌កសាជាថ្មី ឡើងវិញបានក្នុងអំឡុងពេល ៥ឆ្នាំ[56]។ ប្រសិនបើការពិភាក្សាបែងចែកមានសុពលភាពហើយ កូនដែលត្រូវបានទទួលស្គាល់នោះ មិនអាចទាមទារឱ្យធ្វើការបែងចែកសាជាថ្មីទៀតទេ ហើយការទទួលស្គាល់នោះមានអានុភាពប្រតិសកម្ម[57]។

ការទាមទារឱ្យសងដោយតម្លៃជាប្រាក់នេះ ក៏ជាការទាមទារឱ្យធ្វើបដិទានសន្តតិកម្មដែរ ដែលត្រូវធ្វើក្នុងអំឡុងពេលដែលបានចែងក្នុងមាត្រា១៣០៤។ ការទាមទារឱ្យទទួលស្គាល់ក្រោយមរណភាព អាចធ្វើបាននៅអំឡុងពេល ១ ឆ្នាំ ក្រោយមតកជនបានមរណភាព។[58] ឯអំឡុងពេលនៃការទាមទារ ឱ្យសងដោយតម្លៃជាប្រាក់នេះមានរយៈពេល ៤ ឆ្នាំ ឬ លើស ចាប់ពីពេលដែលដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់ ដូច្នេះ ពុំមានបញ្ហាអ្វីចំពោះអំឡុងពេលទេ។ ប្រសិនបើសន្តតិជនដទៃបានធ្វើបង្អែតសកម្មភាពពន្យារនីតិវិធីនៃបណ្ដឹង ក្នុងគោលបំណងអោយអំឡុងពេលនេះកន្លងផុតជាការបំពានសិទ្ធិ។[59]

(គោលគំនិតមាត្រានេះ ក៏មានភាពស្រដៀងគ្នាទៅនឹងមាត្រា ៩១០ នៃក្រមរដ្ឋប្បវេណីជប៉ុនដែរ)[60]

---

[56] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១៣០៤

[57] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៩៩

[58] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១០០៩

[59] "សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា ១២៧៤

[60] "ក្រមរដ្ឋប្បវេណីជប៉ុន", Civil Code of Japan (Part IV and Part V (Tentative translation), Act No. 89 of April 27, 1896, Translation date: January 30, 2014

Article 910 In the case where a person who becomes an heir through affiliation after the commencement of inheritance intends to apply for a division of the inherited property, if other heirs have already divided the inherited property or made another disposition, he/she shall only have a claim of payment for value.

### ២.២.១.២ ការបែងចែកដោយតុលាការ

ប្រសិនការពិភាក្សារវាងសហសន្តតិជនទាំងអស់ ពាក់ព័ន្ធនឹងការបែងចែកមត៌ក ពុំបានលទ្ធផលល្អ ឬ ក្នុងករណីដែលសហសន្តតិជនមិនអាចពិភាក្សាទេ នោះសហសន្តតិជនណាម្នាក់ឬច្រើននាក់ត្រូវធ្វើការស្នើទៅតុលាការ ដើម្បីធ្វើការបែងចែកមត៌កនោះ។ បើមិនមានពាក្យសុំពីសហសន្តតិជនទេ តុលាការមិនអាចធ្វើការបែងចែកមត៌កបានទេ ពោលគឺតុលាការមិនអាចប្រើប្រាស់អំណាចឆន្ទានុសិទ្ធិរបស់ខ្លួនបានទេ។

> មាត្រា ១២៧០._ ការបែងចែកដោយតុលាការ
>
> ១-បើការពិភាក្សារវាងសហសន្តតិជន ចំពោះការបែងចែកមត៌ក ពុំបានសម្រេច ឬ បើពុំអាចពិភាក្សា បានទេ សហសន្តតិជនណាម្នាក់ អាចដាក់ពាក្យសុំទៅតុលាការឱ្យធ្វើការបែងចែកមត៌កនោះ បាន ។
>
> ២-ក្នុងការបែងចែកមត៌ក ក្រៅពីបញ្ញត្តិចាប់ពីមាត្រា ១២៦៧ (មូលដ្ឋាននៃការបែងចែក) រហូតដល់មាត្រា ១២៦៩ (សំណងនៃកាតព្វកិច្ចរបស់មតកជនជាអាទិ៍) ខាងលើនេះ តុលាការត្រូវធ្វើការពិចារណានូវទំនៀមទម្លាប់នៅក្នុងតំបន់នោះ និង មតិលើស ពីពាក់កណ្ដាលរបស់សហសន្តតិជន ។

សម្រាប់គោលការណ៍ក្នុងការបែងចែកមត៌កដោយតុលាការ យើងអាចក្រឡេកទៅមើល បញ្ញត្តិចាប់ពីមាត្រា ១២៦៧ ដល់ មាត្រា ១២៦៩ ដែលជាជាគោលការណ៍នៃការបែងចែកមត៌ករវាងសហសន្តតិជនព្រមជាមួយគ្នា និងគោលការណ៍ នៃការបែងចែកមត៌កដោយតុលាការដែរ។[61]

### ២.២.២ សិទ្ធិ និងភាតព្វកិច្ចរបស់សហសន្តតិជន

- សិទ្ធិអាទិភាពរបស់សហព័ទ្ធ

> មាត្រា ១២៦៨._ សិទ្ធិអាទិភាពរបស់សហព័ទ្ធ
>
> ក្នុងករណីដែលសហព័ទ្ធក្លាយជាសន្តតិជន បើមានទ្រព្យសម្បត្តិដែលទទួលបានជាកម្មសិទ្ធិអវិភាគជាមួយនឹងមតកជន ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ នៅក្នុងការបែងចែកមត៌កសហព័ទ្ធនេះមានអាទិភាពជាងសហសន្តតិជនផ្សេងទៀត ក្នុងការទទួលយកចំណែកកម្មសិទ្ធិអវិភាគដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ រហូតដល់គ្រប់ចំនួននៃចំណែកមត៌កនោះ ។

---

Retrieved from: http://www.japaneselawtranslation.go.jp/law/detail/?id=2252&vm=2&re=02&new=1

[61] "សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា ១២៧០

ផ្អែកតាមមាត្រា៩៧៣ នៃក្រមរដ្ឋប្បវេណី ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិដែលប្ដីប្រពន្ធទាំងសងខាង ឬ ម្ខាងបានធ្វើលទ្ធកម្មក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ជាដើម។ ប្រសិនបើប្ដី ឬ ប្រពន្ធណាម្នាក់ទទួលមរណភាព ពាក់កណ្ដាលនៃទ្រព្យសម្បត្តិនោះ ជារបស់សហព័ទ្ធដែលនៅរស់ដោយផ្អែកតាមគោលការណ៍ទ្រព្យរួម[62] ហើយពាក់កណ្ដាលទៀតជាមត៌ក ដោយសហព័ទ្ធជាសន្តតិជនជានិច្ច។[63]

ក្នុងករណីនេះ សហព័ទ្ធដែលនៅរស់មានសិទ្ធិអាទិភាពក្នុងការធ្វើលទ្ធកម្មទ្រព្យដែល ជាទ្រព្យសម្បត្តិរួមរវាងសហព័ទ្ធ និង មតកជនពេលនៅរស់។ ជាធម្មតា សហព័ទ្ធដែលនៅរស់តែងចង់ទទួលបានទ្រព្យដូចជា ផ្ទះ ឬដីនោះ ដើម្បីជាអនុស្សាវរីយ៍រវាងសហព័ទ្ធ និង មតកជនពេលរស់នៅជាមួយគ្នា។ បន្ថែមពីនេះ ការណ៍ដែលសហព័ទ្ធនៅរស់ទទួលបានកម្មសិទ្ធិឯកឯង ទំនាក់ទំនងផ្លូវច្បាប់ពេលក្រោយក៏មិនសូវមានភាពជាបញ្ហាច្រើនដែរ។ អាស្រ័យហេតុនេះ សហព័ទ្ធ មានអាទិភាពជាងសហសន្តតិជនដទៃ ក្នុងការបែងចែកមត៌ក ដោយសហព័ទ្ធនៅរស់អាចទទួលចំណែកកម្មសិទ្ធិអវិភាគរបស់មតកជន និងទ្រព្យសម្បត្តិរួម រហូតដល់គ្រប់ចំនួននូវចំណែកមត៌ករបស់ខ្លួន។[64]

- សំណងនៃកាតព្វកិច្ចរបស់មតកជន

មាត្រា ១២៦៩._ សំណងនៃកាតព្វកិច្ចរបស់មតកជន ជាអាទិ៍

បើមតកជនមានកាតព្វកិច្ច សហសន្តតិជនត្រូវបែងចែកមត៌កដោយពិចារណាពីការណ៍ថា ខ្លួនត្រូវសងកាតព្វកិច្ចនោះនិងមិនអាចប្ដូរភាគបន្ទុកនៃកាតព្វកិច្ចនោះ ដោយគ្មានការយល់ព្រមពីសំណាក់ម្ចាស់បំណុលឡើយ ។

ជាក់ស្ដែងយើងប្រើប្រាស់ គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ នោះក្នុងករណីដែលមាន វិធីបែងចែកមត៌កដោយសារមតកជនមានកាតព្វកិច្ច។ ដូចដែលបានចែងក្នុង មាត្រា ១១៤៨ សហសន្តតិជនត្រូវទទួលបន្តសិទ្ធិរបស់មតកជនទេ និងករណីយកិច្ច ផងដែរ ដោយមើលទៅតាមចំណែកមត៌ករបស់ខ្លួន។

ប្រសិនបើយើងក្រឡេកមើល គោលការណ៍ជម្រះបញ្ជីវិញ សន្តតិជននឹងទទួលសន្តតិកម្មដែលត្រឹមតែជាទ្រព្យដែលសល់ពីការជម្រះបញ្ជីនៃកាតព្វកិច្ចតែប៉ុណ្ណោះ ហើយគេបែងចែកតែមត៌កសកម្មដែលនៅសល់នោះ។ ប៉ុន្តែ

[62] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៧៣

[63] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៦១

[64] "សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា ១២៦៨

វិធីនេះមានលក្ខណៈស្មុគស្មាញ ទើបយើងគោរពតាម គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិវិញ។ ប្រសិនបើកាតព្វកិច្ចដែលសល់ ត្រូវធ្វើសន្តតិកម្មត្រូវបានសងរួចរាល់ហើយ នោះនឹងមិនមានបញ្ហាឡើយ ហើយបញ្ញត្តិនេះក៏ពុំមានការចាំបាច់ដែរ។

ឃ្លា "ដោយពិចារណាពីការណ៍ថា ... មិនអាចប្តូរភាគបន្ទុកនៃកាតព្វកិច្ច ... ដោយគ្មានការយល់ព្រមពីសំណាក់ម្ចាស់បំណុលឡើយ" បង្ហាញថា សន្តតិកម្ម ត្រូវបានបែកចែកដោយស្វ័យប្រវត្តិ ដោយគិតទៅតាមសមាមាត្រនៃចំណែកម្នាក់ៗ ពេលសន្តតិកម្មត្រូវបានចាប់ផ្តើម។ បន្ថែមពីនេះសមាមាត្រនៃបន្ទុកនេះមិនអាចប្តូរបានឡើយទោះបីជា មានការព្រមព្រៀងពីសហសន្តតិជនក៏ដោយ។ ក្នុងករណីដែលមតកជនមានប្រាក់បញ្ញើក្នុងធនាគារ សហសន្តតិជនអាចប្រើប្រាស់ប្រាក់បញ្ញើនេះដើម្បីដោះស្រាយនឹងបញ្ហាបំណុលសិន ឬ សហសន្តតិជនអាច ព្រមព្រៀងលក់ ទ្រព្យសម្បត្តិបានកំណត់ ហើយយកប្រាក់ទទួលបានពីការលក់ទ្រព្យនោះ ទៅដោះស្រាយនឹងបញ្ហាបំណុលដែលត្រូវទទួលតាមសន្តតិកម្មជាមុនសិន។ ជាការពិតណាស់ យើងបានយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិមកប្រើ ប៉ុន្តែអត្ថប្រយោជន៍នៃគោលការណ៍ជម្រះបញ្ជីក៏មានក្នុងនោះផងដែរ។

**កំណត់សម្គាល់**

ក្នុងករណីដែលមតកជនបានធ្វើអាជីវកម្មអ្វីមួយ ហើយមានទ្រព្យសកម្មផង និងទ្រព្យអកម្មផង ដើម្បីធ្វើការព្រមព្រៀង ឱ្យសហសន្តតិជនណាម្នាក់ ឬច្រើននាក់ ទទួលកាតព្វកិច្ចពាក់ព័ន្ធនឹងអាជីវកម្មនោះ ជំនួសឱ្យការទទួលបន្តអាជីវកម្ម ទាល់តែមានការយល់ព្រមពីម្ចាស់បំណុល ហើយមាត្រានេះក៏បានចែងច្បាស់លាស់អំពីចំណុចនេះ។

ចំពោះម្ចាស់បំណុលវិញ គេនឹងពិចារណាថា តើសន្តតិជនដែលបានទទួលបន្តនូវអាជីវកម្មនោះ មានទេពកោសល្យដែរឬទេ តើទ្រព្យសកម្មដែល ជននោះបានធ្វើលទ្ធកម្មមានប៉ុន្មានជាអាទិ៍ ហើយយល់ព្រម ឬ ជ្រើសរើសការបែងចែកសិទ្ធិលើបំណុលរបស់ខ្លួននេះ ទៅឱ្យសហសន្តតិជនម្នាក់ៗទទួលខុសត្រូវ ។ [65]

- ការប្តូរជាប្រាក់ដោយការលក់

មាត្រា ១២៧១._ ការប្តូរជាប្រាក់ដោយការលក់

ចំពោះទ្រព្យសម្បត្តិដែលមិនអាចទទួលការព្រមព្រៀងអំពីការបែងចែក ឬ អំពីបុគ្គលដែលត្រូវទទួល រវាងសហសន្តតិជនទេ តុលាការអាចលក់ ហើយធ្វើការបែងចែក ប្រាក់ដែលបានមកពីការលក់នោះបាន ។

[65] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា១២៦៩

ក្នុងករណីដែលមត៌កមានតែដីមានការខ្វែងគំនិតគ្នារវាងសហសន្តតិជនដោយទាមទារដីឡូតិ៍ ឬ ខ្វែងគំនិតគ្នាពាក់ព័ន្ធវិធីបែងចែក ព្រោះតម្លៃនៃដីនោះបានធ្លាក់ជាដើម។ ដីនោះអាចផ្តល់ទៅសន្តតិជនណាម្នាក់ ហើយឱ្យជននោះបង់ជាប្រាក់សម្រួលទៅឱ្យសន្តតិជន[66] ផ្សេងទៀត ប៉ុន្តែ ប្រសិនបើពុំមានសន្តតិជនណាម្នាក់ អាចបង់ប្រាក់ សម្រួលនោះ តុលាការអាចដាក់មត៌កនោះលក់ដើម្បីបែងចែកមត៌ក។ សម្រាប់នីតិវិធីនៃការលក់មត៌កវិញត្រូវមាន ការបង្គាប់ដោយតុលាការ ឱ្យសហសន្តតិជនលក់តាមវិធីលក់ឡាយឡុង ដោយយោងតាមមាត្រា ២១២ ស្តីពីវិធីបែងចែកវត្ថុកម្មសិទ្ធិអវិភាគ ។ ប៉ុន្តែបើសាលក្រមអំពីការបែងចែកមត៌កមិនក្លាយជាស្ថាពរ នោះការលក់គឺមិនអាចធ្វើទៅបានទេ។

ដូច្នេះ សេចក្តីសម្រេចបញ្ចប់នៃសាលក្រម ត្រូវមានចែងដូចជា "ត្រូវលក់អចលនវត្ថុដែលមាននៅក្នុងបញ្ជីសារពើភ័ណ្ឌដែលភ្ជាប់ជាមួយនេះ ហើយកាត់នូវសោហ៊ុយចាំបាច់ ពីថ្លៃលក់នោះ ហើយនៅសល់ប៉ុន្មាន សន្តតិជន A, B និង C ទទួលជាសន្តតិកម្ម ស្មើភាគគ្នា"។[67]

- ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្មដោយផ្អែកលើការចាត់ចែងទ្រព្យសម្បត្តិ នៅមុនពេលបែងចែក

មាត្រា១២៧២._ ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្មដោយផ្អែកលើការចាត់ចែងទ្រព្យសម្បត្តិ នៅមុនពេលបែងចែក ជាអាទិ៍

ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម ដោយការសងជំនួសការ បាត់បង់ ការខូចខាត ឬ ការបំពានយកកម្មវត្ថុមត៌ក ឬ តាមកិច្ចសន្យាដែលយកមកជាកម្មវត្ថុ ដោយផ្អែកលើសិទ្ធិ ដែលស្ថិតនៅក្នុងមត៌កនោះ ត្រូវស្ថិតនៅក្នុងមត៌ក ។

"ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្មដោយផ្អែកលើសិទ្ធិដែលស្ថិតនៅក្នុងមត៌កនោះ" គឺមានដូចជាផលដូចជាតាមរយៈធម្មជាតិ ឬ ស៊ីវិលដែលកើតចេញមត៌ក ដូចជា ការប្រាក់ដែលកើតមានក្រោយពេលចាប់ផ្តើមសន្តតិកម្ម។ ឧទាហរណ៍៖ មត៌កដែលជាប្រាក់បញ្ញើក្នុង ធនាគារ។ ឃ្លា "ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម ដោយការសងជំនួសការបាត់បង់ ការខូចខាត ឬ ការបំពានយកកម្មវត្ថុមត៌ក" សំដៅទៅសិទ្ធិលើបំណុលដែលអាចទាមទារសំណងនៃការខូចខាត ឬ ប្រាក់សំណងនៃ ការខូចខាត។ ឧទាហរណ៍ សហសន្តតិជនឬ តតិយជនណាមួយ មានកាតព្វកិច្ចត្រូវសងសំណងនៃការខូចខាតព្រោះបានធ្វើឱ្យបាត់បង់មត៌កជាដើម។ ម្យ៉ាងទៀត "ទ្រព្យដែលត្រូវបានធ្វើ លទ្ធកម្ម តាមកិច្ចសន្យាដែលយកមកជាកម្មវត្ថុ" សំដៅទៅ ប្រាក់ដែលទទួលពីការ

[66] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១២៦៧ កថាខណ្ឌទី ២

[67] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា ១២៧១

លក់មត៌កដោយសហសន្តតិជនទាំងអស់ ឬ ដោយតុលាការ។ សរុបមក ប្រាក់ដែលបានបរិយាយខាងលើ សុទ្ធតែជាវត្ថុជំនួសមត៌ក និង ជាភាគនៃមត៌កផងដែរ ដូច្នេះ ប្រាក់នោះ ជាកម្មវត្ថុនៃការបែងចែក។[68]

- អានុភាពនៃការបែងចែក

មាត្រា ១២៧៣._ អានុភាពនៃការបែងចែក

១-ការបែងចែកមត៌ក មានអានុភាពប្រតិសកម្ម គិតចាប់ពីពេលដែលបានចាប់ផ្ដើម សន្តតិកម្ម ។ ប៉ុន្តែ ការបែងចែកនេះ ពុំអាចបំពានសិទ្ធិរបស់តតិយជនដែលបានចុះបញ្ជី ឬ បានទទួលល័ក្ខខ័ណ្ឌតតាំង បានឡើយ ។

ក្នុងបរិបទប្រទេសកម្ពុជា យើងទទួលស្គាល់នូវអានុភាពប្រតិសកម្ម ព្រោះយើងយកមនោសញ្ចេតនា សន្តតិជនមកពិចារណា។ ការទទួលស្គាល់នូវអានុភាពប្រតិសកម្មនេះបានសេចក្ដីថា សន្តតិជនត្រូវទទួលមត៌ក ពីមតកជនផ្ទាល់ មិនមែនទទួលពីសហសន្តតិជនទេ ដោយសារសន្តតិជនអាចមានមនោសញ្ចេតនាពិសេស ចំពោះមត៌កដូចជា ផ្ទះឡានជាដើម។

ម្យ៉ាងទៀត នីតិវិធីនៃការចុះបញ្ជីអចលនវត្ថុ មិនត្រូវការឆ្លងកាត់តាម ដំណាក់កាលចុះបញ្ជីនូវកម្មសិទ្ធិអវិភាគ របស់សហសន្តតិជន ព្រោះយើងអាចប្រើប្រាស់នីតិវិធីផ្ទេរកម្មសិទ្ធិផ្ទាល់ពីមតកជន ទៅសន្តតិជនដែលបាន លទ្ធកម្មដោយការបែងចែកនោះតែម្ដង។ ប្រសិនបើមានករណីបែងចែកមត៌កដែលជាអចលនវត្ថុ ដោយឱ្យ សន្តតិជនណាម្នាក់ត្រូវទទួលទ្រព្យនោះតែឯង បញ្ញត្តិនៃមាត្រា ១៣៥ មិនយកមកអនុវត្តឡើយ ព្រោះការចុះបញ្ជី ក្នុងករណីនេះត្រូវបកស្រាយដោយប្រើប្រាស់ ល័ក្ខខ័ណ្ឌតតាំងដូចមានបញ្ញត្តិក្នុងមាត្រា ១៣៤ កថាខណ្ឌទី ១ ។

- ⇨ ក្នុងករណីដែលអចលនវត្ថុស្ថិតក្នុងស្ថានភាពកម្មសិទ្ធិអវិភាគ សហសន្តតិជនអាចប្រើប្រាស់ និង អាស្រ័យផលអចលនវត្ថុដែលជាមត៌កនោះបាន ដោយការគ្រប់គ្រងអចលនវត្ថុ ដែលជាមត៌កនោះនៅ ក្រោមលក្ខណៈត្រួតគ្នា។
- ⇨ ក្នុងករណីដែលឱ្យសហសន្តតិជនម្នាក់ ទទួលកម្មសិទ្ធិតែឯងតាមរយៈការបែងចែកមត៌ក នោះ អាចចុះ បញ្ជីផ្ទេរកម្មសិទ្ធិដោយផ្ទាល់របស់មតកជនទៅឱ្យសន្តតិជននោះបាន។

[68] "សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា ១២៧២

⇨ ម្យ៉ាងទៀតក្នុងករណីដែលសន្តតិជន ២ឬច្រើននាក់ ត្រូវបានចុះបញ្ជីជាម្ចាស់កម្មសិទ្ធិអវិភាគ តាមរយៈសន្តតិកម្មតាមច្បាប់ យើងអាចប្រើប្រាស់ការផ្ទេរចំណែកកម្មសិទ្ធិអវិភាគរបស់ សន្តតិជនម្នាក់ទៅសន្តតិជនម្នាក់ទៀត ក្រោមលក្ខណៈបច្ចេកទេសប៉ុណ្ណោះ។

បន្ថែមពីនេះទៅទៀត ដើម្បីឱ្យការផ្ទេរសិទ្ធិនេះធ្វើឡើងមិនមានការយឺតយ៉ាវ សន្តតិជនដែលបានលទ្ធកម្មនូវសិទ្ធិលើប្រាក់បញ្ញើរបស់មតកជន មានសិទ្ធិទទួលយកសៀវភៅគណនីធនាគារពីសន្តតិជនដែលបានរក្សាសៀវភៅគណនីនោះទុកបានដោយផ្អែកតាម មាត្រា ១២៧៣ កថាខណ្ឌទី ២។[69]

- ល័ក្ខខ័ណ្ឌតតាំង ជាអាទិ៍ នៃការបែងចែកសិទ្ធិលើបំណុល

មាត្រា ១២៧៥._ ល័ក្ខខ័ណ្ឌតតាំង ជាអាទិ៍ នៃការបែងចែកសិទ្ធិលើបំណុល

១- នៅក្នុងការបែងចែកមត៌ក ក្នុងករណីដែលបានបែងចែកសិទ្ធិលើបំណុលដែលមតកជនមានទៅតាមភាគក្រៅពីចំណែកមត៌កដែលកំណត់ដោយច្បាប់ បើសហសន្តតិជនទាំងអស់មិនបានជូនដំណឹងពីការបែងចែកនោះ ឬ បើការបែងចែកមត៌កនោះ ត្រូវបានធ្វើដោយលិខិតយថាភូត តែមិនបានបង្ហាញលិខិតនោះ ប្រគល់លិខិតចម្លងនោះ ទៅឱ្យកូនបំណុលទេ ពុំអាចតតាំងជាមួយកូនបំណុលបានឡើយ ។

២- កូនបំណុលនៃមតកជនដែលបានសងសំណង តាមចំណែកមត៌ក ដែលកំណត់ដោយច្បាប់ ចំពោះសហសន្តតិជន នៅមុនពេលបានទទួលដំណឹង ដូចបានកំណត់នៅក្នុង កថាខណ្ឌទី១ ខាងលើនេះ អាចតតាំងចំពោះសហសន្តតិជនដែលបានធ្វើលទ្ធកម្មសិទ្ធិលើបំណុល តាមការបែងចែកមត៌កនោះ បាន ។

សិទ្ធិលើបំណុលរបស់មតកជនដែលយើងអាចធ្វើការបែងចែកបាន រួមមានដូចជាប្រាក់បញ្ញើ។ ក្នុងករណីនេះ យើងធ្វើការបែងចែកប្រាក់បញ្ញើនេះដោយស្វ័យប្រវត្តិដល់សហសន្តតិជន តាមចំណែកដែលកំណត់ដោយច្បាប់។[70]

បើមានការព្រមព្រៀងគ្នារវាងសហសន្តតិជន សិទ្ធិលើបំណុលនោះក្លាយជាកម្មវត្ថុ នៃការបែងចែកមត៌ក និងអាចបែងចែកទៅតាមភាគក្រៅពីចំណែកមត៌កកំណត់ដោយច្បាប់បានដែរ ។

[69] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា ១២៧៣

[70] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១១៤៨ កថាខណ្ឌ ទី ១

កូនបំណុលដែលមានកាតព្វកិច្ចចំពោះសិទ្ធិលើបំណុលនេះ ការបែងចែកទៅតាមភាគក្រៅពីចំណែកមត៌កកំណត់ដោយច្បាប់ គឺសំដៅទៅលើការធ្វើអនុប្បទានសិទ្ធិលើបំណុល នោះក្នុងករណីដែលអនុប្បទាយីមិនបានផ្តល់ដំណឹង[71] កូនបំណុលនេះពុំចាំបាច់ធ្វើតាមការបែងចែកមត៌កនោះទេ។

សរុបមក សន្តតិជនទាំងអស់ត្រូវតែជូនដំណឹងដល់ កូនបំណុល បើមិនដូច្នោះទេ ការបែងចែកមត៌កនោះ នឹងគ្មានអត្ថន័យទេ។ អាស្រ័យហេតុនេះទើប វិធីជូនដំណឹងពិសេសនេះមានលក្ខណៈចាំបាច់ហើយក៏មានភាពស្រដៀងគ្នាទៅនឹង មាត្រា៥០៣ ដែរ ។[72]

- ការទទួលខុសត្រូវក្នុងការធានា របស់សហសន្តតិជន

មាត្រា ១២៧៦._ ការទទួលខុសត្រូវក្នុងការធានា របស់សហសន្តតិជន

សហសន្តតិជនម្នាក់ៗ ត្រូវមានបន្ទុកទទួលខុសត្រូវក្នុងការធានា ទៅតាមសមាមាត្រ នៃចំណែកមត៌កនោះ ដូចជាអ្នកលក់ដែរ ចំពោះសហសន្តតិជនដទៃទៀត ។

តាមតែអ្វីដែលយើងបានសិក្សាកន្លងមក ការបែងចែកមត៌ក គឺជាការផ្លាស់ប្តូរមត៌កដែលមានលក្ខណៈជាកម្មសិទ្ធិអវិភាគរបស់សហសន្តតិជនទាំងអស់ ឱ្យទៅជា កម្មសិទ្ធិតែម្នាក់ ក្រោយពីបានធ្វើការពិភាក្សារវាងសហសន្តតិជន។ ស្ថានភាពនេះស្រដៀងទៅនឹងការលក់ទិញ ឬ ការដូរដែរ។
សហសន្តតិជនផ្សេងត្រូវទទួលខុសត្រូវក្នុងការធានា ដែលស្ថានភាពនេះប្រៀបដូចទៅនឹងអ្នកលក់ដែរ ដូចជាក្នុងករណីដែលវត្ថុ ឬ សិទ្ធិដែលសន្តតិជនបានក្រោយការព្រមព្រៀងនៃការបែងចែកមត៌កមានវិការៈ។[73]

## ២.៣ លំហូរនៃការបែងចែកមត៌ក

[71] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៥០៣
[72] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា ១២៧៥
[73] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា ១២៧៦




*74

### ២.៣.១ ទំហំនៃសន្តតិជន

ដើម្បីបែងចែកមត៌ក យើងចាំបាច់ត្រូវស្គាល់បុគ្គលដែលមានផលប្រយោជន៍ដែល ពាក់ព័ន្ធនឹងមត៌ករបស់មតកជន។ បន្ទាប់ពីការកំណត់អត្តសញ្ញាណសន្តតិជនរួចហើយ យើងត្រូវកំណត់លំដាប់សន្តតិជន ដូចជាសន្តតិជននោះជា បច្ឆាញាតិផ្ទាល់ ឬបុព្វញាតិផ្ទាល់ សន្តតិកម្មជំនួស ឬជាសហព័ទ្ធ ជាអាទិ៍។[75]

ឧទាហរណ៍៖ A បានទទួលមរណភាពនៅថ្ងៃទី ខែ ឆ្នាំ ហើយសន្តតិកម្មបានចាប់ផ្តើម។ សន្តតិជនមាន ប្រពន្ធ X ឪពុក U។

### ២.៣.២ ចំណែកសន្តតិកម្មតាមច្បាប់

ក្រោយពេលដែលយើង អាចកំណត់ចំនួន និងអត្តសញ្ញាណរបស់សន្តតិជនរួច យើងត្រូវពិនិត្យមើលថា តើមតកជនបាន ទុកលិខិតបណ្តាំ ឬទេ? បើទេនោះ យើងត្រូវបែងចែកមត៌កតាមច្បាប់ ក្នុងចំណោមសន្តតិជនទាំងនោះ។

ឧទាហរណ៍៖ ចំណែកសន្តតិកម្មតាមច្បាប់ X បាន ១ ភាគ ២ និង U បាន ១ ភាគ ២។

---

[74] ដកស្រង់ពី UMEMOTO Yumi ការអនុវត្តជាក់ស្តែងនៃការបែងចែកមត៌ក

[75] អ៊ីវ ប៉ូលី, "ការបែងចែកមត៌ក", ១២ មករា ២០១៨

### ២.៣.៣ ទំហំនៃមត៌ក

ជាដំបូងយើងត្រូវធ្វើការស្រាវជ្រាវមត៌កដែលជាកម្មវត្ថុនៃការបែងចែក ដូចជាទ្រព្យសកម្មដែលមិនទាន់បានបែងចែកនៅពេលបែងចែកមត៌កនៅក្នុងចំណោមសិទ្ធិនិងករណីយកិច្ចនៃទ្រព្យសម្បត្តិរបស់មតកជន នៅពេលចាប់ផ្តើមសន្តតិកម្ម។[76] ប្រសិនបើមានវិវាទពាក់ព័ន្ធនឹងការទទួលយកមត៌កត្រូវដោះស្រាយតាមនីតិវិធីរដ្ឋប្បវេណី។

- សិទ្ធិលើបំណុល

ក្នុងករណីដែលកម្មវត្ថុនៃមត៌កជាសិទ្ធិលើបំណុលជាប្រាក់ សិទ្ធិលើបំណុលអាចធ្វើការបែងចែកទៅតាមចំណែកនៃសន្តតិកម្មតាមច្បាប់។ សិទ្ធិលើបំណុលនោះអាចជាកម្មវត្ថុនៃការបែងចែកផងដែរប្រសិនបើមានការព្រមព្រៀងរវាងសន្តតិជន។

- កាតព្វកិច្ច

ជាគោលការណ៍ កាតព្វកិច្ចមិនមែនជាកម្មវត្ថុនៃការបែងចែកមត៌កនោះទេ។[77]

- វត្ថុជំនួស[78]

កម្មវត្ថុនៃការបែងចែកមត៌កដទៃ ក៏មានដូចជា ផលពីសិទ្ធិនៃសន្តតិកម្ម ប្រាក់សំណងការខូចខាត ជាអាទិ៍ ដែលបានធ្វើលទ្ធកម្ម ដោយការសងជំនួសការបាត់បង់ ការខូចខាតឬការបំពានកម្មវត្ថុនៃទ្រព្យសម្បត្តិសន្តតិកម្ម ប្រាក់លក់ដែលបានធ្វើលទ្ធកម្មជាអាទិ៍ ដោយកិច្ចសន្យាដែលយកមត៌កជាកម្មវត្ថុ នឹងក្លាយជាផងដែរ។

### ២.៣.៤. ការវាយតម្លៃមត៌ក

ការវាយតម្លៃមត៌ក ត្រូវធ្វើឡើងតាមរយៈការព្រមព្រៀងអំពីចំនួន ឬការជ្រើសតាំងអ្នកវាយតម្លៃ ឬការសន្មតនូវចំនួនជាក់លាក់ណាមួយ។[79] ប្រសិនបើយើងក្រឡេកមើលនៅប្រទេសជប៉ុន តុលាការអាចបង្គាប់ឱ្យដាក់ឯកសារដូចជា លិខិតវាយតម្លៃអចលនវត្ថុ លិខិតប្រកាសពន្ធសន្តតិកម្ម និងលិខិតវាយតម្លៃរបស់ក្រុមហ៊ុនអចលនវត្ថុ ដើម្បីសម្រប សម្រួលយោបល់របស់ភាគី និងឈានទៅដល់ការព្រមព្រៀង។ បើពុំអាច

---

[76] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៤៧ កថាខណ្ឌទី ១

[77] ដកស្រង់ពី UMEMOTO Yumi ការអនុវត្តជាក់ស្តែងនៃការបែងចែកមត៌ក

[78] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១២៧២

[79] អ៊ីវ ប៉ូលី, "ការបែងចែកមត៌ក", ១២ មករា ២០១៨

ឈានដល់ការព្រមព្រៀងនោះទេ តុលាការនឹងធ្វើការជ្រើសរើសអ្នកវាយតម្លៃដែលជា បុគ្គលមានចំណេះដឹងដូចជា អ្នកជំនាញវាយតម្លៃអចលនវត្ថុ ជាអាទិ៍ ដើម្បីមកធ្វើការវាយតម្លៃ។[80]

### ២.៣.៥. ការកំណត់ចំណែកមត៌កជាក់ស្តែង

ចំណែកសន្តតិកម្មជាក់ស្តែង សំដៅទៅអត្រាចំណែមត៌កចុងក្រោយដែលត្រូវបានសម្រួលរួចរាល់ ដោយពិចារណាលើចំណែកសន្តតិកម្ម តាមច្បាប់ជាមួយនឹងការទទួលផលប្រយោជន៍ពិសេស[81] និងភាគនៃវិភាគទាន[82] ដើម្បីអោយមានសមភាពជាក់ស្តែងនៃទ្រព្យសន្តតិកម្ម។ ទ្រព្យសន្តតិកម្មនៅពេលចាប់ផ្តើមសន្តតិកម្មត្រូវបូកនឹងផលប្រយោជន៍ពិសេស និងដកភាគនៃវិភាគទានចេញ ហើយនេះគឺជាចំនួនមត៌ក។

- សន្តតិកម្មរបស់សន្តតិជនទាំងអស់ត្រូវគណនាទៅតាមចំណែកសន្តតិកម្មតាមច្បាប់។
- ជនដែលទទួលបានផលប្រយោជន៍ពិសេស ត្រូវទទួលបានចំណែកមត៌ក ដែលដកផលប្រយោជន៍ពិសេស។
- សន្តតិជនដែលទទួលបានវិភាគទាន ត្រូវទទួលចំណែកមត៌កបូកនឹងភាគនៃវិភាគទាន។[83]

### ២.៣.៦. វិធីសម្រេចបែងចែកមត៌ក

តុលាការត្រូវសម្រេចពីវិធីបែងចែកមត៌ក ដោយពិចារណាទៅលើកត្តាមួយចំនួន។ ប្រភេទនៃវិធីបែងចែកមានដូចជា៖

1) ការបែងចែកវត្ថុដោយផ្ទាល់
2) ការបែងចែកដោយសងជំនួស
3) ការបែងចែកដោយប្តូរជាប្រាក់
4) ការបែងចែកជាវត្ថុអវិភាគ

---

[80] ដកស្រង់ពី UMEMOTO Yumi ការអនុវត្តជាក់ស្តែងនៃការបែងចែកមត៌ក

[81] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៦៣

[82] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១១៦៦

[83] អ៊ីវ ប៉ូលី, "ការបែងចែកមត៌ក", ១២ មករា ២០១៨

បន្ថែមពីនេះទៅទៀត តុលាការក៏ត្រូវធ្វើការពិចារណាដល់ស្ថានភាពរបស់សហាសន្តតិជន ដូចជា អាយុ មុខរបរ សុខភាព ជីវភាព វត្ថុឬប្រភេទនៃសិទ្ធិដែលមានចំពោះមត៌ក[84] សិទ្ធិអាទិភាពរបស់សហាព័ទ្ធ[85] សំណាងនៃកាតព្វកិច្ចរបស់មតកជន[86] ទំនៀមទម្លាប់នៅក្នុងតំបន់ និងមតិយោបល់របស់សហាសន្តតិជន[87] ជាដើម។[88]

[84] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១២៦៧ កថាខណ្ឌទី ១

[85] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១២៦៨

[86] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១២៦៩

[87] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១២៧០ កថាខណ្ឌទី ២

[88] អ៊ឹរ ប៉ូលី, "ការបែងចែកមត៌ក", ១២ មករា ២០១៨

# ជំពូកទី៣

# ការយល់ព្រម និងការបោះបង់សន្តតិកម្ម

សន្តតិកម្ម អាចជាកម្មវត្ថុនៃការទទួលយក ឬបោះបង់បានដោយអាស្រ័យទៅលើផលប្រយោជន៍ដែលសន្តតិជនអាចទទួលបាន ដើម្បីអោយសន្តតិជនជៀសវាងពីក្ស័យធន ឬការរងកាតព្វកិច្ចធ្ងន់ធ្ងរដោយសារតែសន្តតិកម្មមួយ។ អាស្រ័យហេតុនេះ យើងនឹងធ្វើការសិក្សាទៅលើការយល់ព្រម និងការបោះបង់សន្តតិកម្មនេះ។

## ៣.១ ការយល់ព្រមសន្តតិកម្ម

សន្តតិជន ត្រូវធ្វើការយល់ព្រមទាំងស្រុង ឬដោយកម្រិតនៅក្នុងអំឡុងពេលបីខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានកើតឡើង។ ប៉ុន្តែអំឡុងពេលនេះ អាចពន្យារទៀតបាន តាមពាក្យសុំរបស់សន្តតិជនទៅតុលាការ ។

### ៣.១.១ ការយល់ព្រមទាំងស្រុង

មាត្រា ១២៥៥._ ការយល់ព្រមទាំងស្រុងតាមច្បាប់
ក្នុងករណីដែលកំណត់ដូចខាងក្រោមនេះ ត្រូវចាត់ទុកថា សន្តតិជន បានយល់ព្រម ទាំងស្រុងតាមច្បាប់
ក-បើសន្តតិជន បានចាត់ចែងមត៌កនោះ ទាំងអស់ ឬមួយភាគ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពរក្សា និង សកម្មភាពត្រឹមតែជា ការគ្រប់គ្រង ។
ខ-បើសន្តតិជនមិន បានយល់ព្រមដោយកម្រិត ឬ បោះបង់ នៅក្នុងអំឡុងពេល ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។
គ-ទោះបីជាសន្តតិជន បានយល់ព្រមដោយកម្រិត ឬ បោះបង់ ក៏ដោយ បើសន្តតិជន បានលាក់មត៌កទាំងអស់ ឬមួយភាគ ឬ បានប្រើប្រាស់មត៌កនោះដើម្បីខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ នៅក្រោយពេលដែលជនដែល បានក្លាយជា សន្តតិជនដោយសារការបោះបង់របស់សន្តតិជនលំដាប់មុន បានយល់ព្រម ។

ក្នុងករណីដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវចាត់ទុកថា សន្តតិជនបានយល់ព្រមទាំងស្រុងដោយត្រូវទទួលកាតព្វកិច្ច និងសិទ្ធបន្តពីមតកជននោះ ៖

(១) ក្នុងករណីដែលសន្តតិជន បានចាត់ចែងមត៌កនោះទាំងអស់ ឬមួយភាគ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកអនុវត្តឡើយ លើអំពើសកម្មភាពរក្សា និងសកម្មភាពត្រឹមតែជាការគ្រប់គ្រង។

(២) បើសន្តតិជនមិនបានយល់ព្រមដោយកម្រិត ឬបោះបង់នៅក្នុងអំឡុងពេលបីខែ។[89]

(៣) ទោះបីជាសន្តតិជនបានយល់ព្រមដោយកម្រិត ឬបោះបង់ក៏ដោយ បើសន្តតិជនបានលាក់មត៌កទាំងអស់ ឬមួយភាគ ឬបានប្រើប្រាស់មត៌កនោះដើម្បីខ្លួន។[90]

### ៣.១.២ ការយល់ព្រមដោយមានកម្រិត

មាត្រា ១២៥៦._ ការយល់ព្រមដោយមានកម្រិត
១-សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និង អច្ច័យទានរបស់មតកជន បានត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួន បានទទួលតាមរយៈសន្តតិកម្មតែប៉ុណ្ណោះ។
២-បើសន្តតិជនមានច្រើននាក់ ការយល់ព្រមដោយកម្រិតនេះ អាចធ្វើបាន លុះត្រា តែសហសន្តតិជននោះ បានធ្វើដោយរួមគ្នាទាំងអស់ ។

សន្តតិជន អាចយល់ព្រមដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និងអច្ច័យទានរបស់មតកជនបាន ដោយសងត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលទទួលបានពីសន្តតិកម្មតែប៉ុណ្ណោះ។[91] សន្តតិជនដែលយល់ព្រមដោយកម្រិតនេះក៏អាចសងលើសពីមត៌កដែលខ្លួនទទួលបានផងដែរ ដែលការសងនេះមានសុពលភាព។ ផ្អែកតាមទ្រឹស្តីសិក្សាចំណែកនៃកាតព្វកិច្ច ដែលលើសមត៌កសកម្មនេះ ត្រូវបានហៅថា កាតព្វកិច្ចធម្មជាតិ។[92] ក្នុងករណីដែលសន្តតិជនមានច្រើននាក់ នោះការយល់ព្រមដោយមានកម្រិតត្រូវធ្វើឡើងរួមគ្នា។[93] នៅពេលដែលមានករណីបែបនេះកើតឡើង នីតិវិធីជម្រះចាំបាច់ត្រូវកើតមានឡើង ពីព្រោះសហសន្តតិជនត្រូវមានឯកភាពក្នុងការសង និង សមភាពចំពោះការសងចំពោះម្ចាស់បំណុល។[94]

សន្តតិជនដែលមានបំណងចង់យល់ព្រមដោយកម្រិត ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ[95] ហើយត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតនោះទៅតុលាការ នៅក្នុងអំឡុងពេលបីខែ។[96]

---

[89] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១២៤៨
[90] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១២៥៥
[91] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១២៥៦-១
[92] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា១២៥៦
[93] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១២៥៦-២
[94] "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា១២៥៦
[95] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១២៥៧
[96] "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១២៤៨

## ៣.២ ការបោះបង់នូវសន្តតិកម្ម

មាត្រា ១២៦០._ ការបោះបង់សន្តតិកម្ម
បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំការបោះបង់សន្តតិកម្ម នោះ ទៅតុលាការ ។

ការបោះបង់សន្តតិកម្ម ត្រូវធ្វើឡើងបាន តាមរយៈពាក្យសុំរបស់សន្តតិជន ទៅតុលាការ។[97] អំឡុងពេលនៃការដាក់ពាក្យសុំនេះ ត្រូវធ្វើឡើងតាមមាត្រា ១២៤៨[98] នោះការបោះបង់សន្តតិកម្ម ត្រូវធ្វើឡើង នៅក្នុងអំឡុងពេលបីខែ គិតចាប់ពីពេលដែលសន្តតិជនបានដឹងថា សន្តតិកម្មចំពោះខ្លួនបានកើតឡើង។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារទៀតបាន តាមរយៈពាក្យសុំរបស់សន្តតិជនទៅតុលាការ។

ការបោះបង់នេះមានអានុភាពលុះត្រាតែបុគ្គល ដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គល នោះមិនមែនជាសន្តតិជនចំពោះសន្តតិកម្មនោះតាំងពីដំបូងមកម្ល៉េះ។[99][100]

ក្នុងចំណោមសហសន្តតិជន ប្រសិនបើមានតែជនមួយចំនួនទេដែលបានបោះបង់ សន្តតិកម្ម សន្តតិជន ផ្សេងទៀតជាអ្នកទទួលសន្តតិកម្ម ។ អ្នកដែលមានលំដាប់បន្ទាប់ អាចទទួលសន្តតិកម្មបាន ក្នុងករណីដែល សហសន្តតិជនលំដាប់មុនទាំងអស់បានបោះបង់ ។

**កំណត់សម្គាល់៖**

ក្នុងករណីដែលឪពុកឈ្មោះ A បានទទួលមរណភាព ហើយម្តាយឈ្មោះ B ក៏បានទទួលមរណភាពជាបន្តបន្ទាប់ កូនឈ្មោះ C របស់អ្នកទាំងពីរនេះ អាចបោះបង់តែសន្តតិកម្ម ចំពោះ A បាន ឬក៏អាចបោះបង់តែសន្តតិកម្មចំពោះ B ក៏បាន តែក្នុងករណីនេះ គ្មានឥទ្ធិពលទៅវិញទៅមកទេ ។

---

97 "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១២៦០

98 "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, មាត្រា១២៦០

99 "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១២៦១ថ្មី

100 "ក្រមរដ្ឋប្បវេណីជប៉ុន", Civil Code of Japan (Part IV and Part V (Tentative translation), Act No. 89 of April 27, 1896, Translation date: January 30, 2014

Article 939 A person who has renounced inheritance shall be deemed as not originally having been an heir to the inheritance.

Retrieved from: http://www.japaneselawtranslation.go.jp/law/detail/?id=2252&vm=2&re=02&new=1

ក្នុងករណីដែល C បានបោះបង់សន្តតិកម្មចំពោះតែ A សន្តតិកម្មរបស់ A នឹងត្រូវធ្លាក់ទៅលើ B ព្រមទាំងបងប្អូនបង្កើតផ្សេងទៀត ឬ ជនដែលមានលំដាប់បន្ទាប់ (បុព្វញាតិផ្ទាល់ ជាអាទិ៍) ។ ដូច្នេះ ប្រសិនបើ B មិនបានបោះបង់សន្តតិកម្ម ហើយ C ក៏មិនបានបោះបង់តាមការចែងនៃមាត្រា ១២៤៩ ដែរនោះ C អាចទទួលសន្តតិកម្មរួមទាំងចំណែកដែល B បានទទួលសន្តតិកម្មពី A ដែរ ដោយសារការទទួលសន្តតិកម្មពី B នេះ ។

ផ្ទុយទៅវិញ ប្រសិនបើ C បានបោះបង់ សន្តតិកម្មតែពី B នោះ C អាចទទួលសន្តតិកម្មនូវមត៌កសកម្ម ព្រមទាំងអកម្មរបស់ A ពាក់កណ្តាល តែមិនអាច ទទួលសន្តតិកម្មនូវមត៌ករបស់ B ព្រមទាំងចំណែកមត៌កដែល B បានទទួលពី A ដោយសន្តតិកម្មទេ ។ ម្យ៉ាងទៀត ចំពោះការគ្រប់គ្រងមត៌ក ក្រោយមានការបោះបង់សន្តតិកម្ម មានចែងក្នុងមាត្រា ១២៦២ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២។[101]

[101] “សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩”, ២០១០, មាត្រា ១២៦១ ថ្មី

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាយ៉ាងលំអិតទៅលើប្រធានបទមួយនេះ អ្នកអានមួយចំនួនប្រហែលជាបានយល់ដឹងអំពីសិទ្ធិ និងករណីយកិច្ចចំពោះសហសន្តតិជន នៅពេលដែលសន្តិកម្មចាប់ផ្តើម។ ទ្រព្យ និង បំណុលដែលនៅសេសសល់ នឹងក្លាយទៅជាកម្មវត្ថុនៃសន្តតិកម្ម។ ជាទូទៅ នីតិសន្តតិកម្ម ដែលបកស្រាយទៅលើការបែងចែកមត៌កមិនត្រូវបាន អនុវត្តទូលំទូលាយឡើយ។ មូលហេតុគឺមកពី ប្រជាពលរដ្ឋមានការយល់ដឹងតិចតួចអំពីការបែងចែក ហើយមិនសូវបានព្យាយាមរកការប្រឹក្សាផ្នែកច្បាប់ឡើយ។ អាស្រ័យហេតុនេះហើយ ទើប ការផ្ទេរលទ្ធកម្មទ្រព្យពីមតកជនដែលបានទទួលមរណភាព ទៅសន្តតិជនមានលក្ខណៈស្មុគស្មាញ។ ប្រសិនបើមតកជនមានសិទ្ធិលើបំណុលជាប្រាក់ចំពោះតតិយជន ច្បាប់នឹងធ្វើការបែងចែកសិទ្ធិលើបំណុលនេះ តាមចំណែកមត៌កចំពោះសហសន្តតិជននីមួយៗ ដោយស្វ័យប្រវត្តិ ដោយមិនចាំបាច់រង់ចាំពេលបែងចែកមត៌កទេ។ បើកាតព្វកិច្ចដែលជាសន្តតិកម្មនោះមានលក្ខណៈធ្ងន់ធ្ងរនោះ សន្តតិកម្ម ក៏អាចជាកម្មវត្ថុនៃការទទួលយកឬបោះបង់បានដែរ ប៉ុន្តែប្រជាពលរដ្ឋមួយចំនួនមិនទាន់យល់ដឹងអំពីជម្រើសដែលខ្លួនមាននៅឡើយ។ ក្នុងករណីដែលមតកសាសន៍ ឬបណ្តាំដែលបានធ្វើឡើងដោយមតកជននោះត្រូវចាត់ទុកជាមោឃៈប្រសិនបើមានបញ្ហាជាមួយនឹងទម្រង់ជាដើម។ ការណ៍នេះ អាចធ្វើអោយប៉ះពាល់ដល់លំហូរនៃការបែងចែកមត៌ក និងជួបប្រទះនឹងផលវិបាក មួយចំនួន ដែលអាចកើតមានពាក់ព័ន្ធទៅនឹងភាពអយុត្តិធម៌នៃការបែងចែកនោះ។ មូលហេតុនេះហើយទើបការយល់ដឹងពី លំហូរនៃការបែងចែកមត៌កនិងកាតព្វកិច្ចអាចការពារកុំអោយសន្តតិជនបាត់បង់ផលប្រយោជន៍ ដោយអំពាវនាវអំពី អត្ថភាព ឬ នត្ថិភាពនៃការបំពានភាគបម្រុង ជាដើម។

សរុបសេចក្តីមក ការបែងចែកមត៌កពិតជាមានសារៈសំខាន់ខ្លាំងសម្រាប់អ្នកសិក្សាស្រាវជ្រាវទាំងឡាយដើម្បីយកជាទុនសិក្សា។ ករណីសិក្សាដែលពាក់ព័ន្ធនឹងប្រធានបទនេះ ក៏អាចផ្តល់នូវការជំនួយស្មារតីច្រើនដូចគ្នា ពីព្រោះប្រធានបទនេះគឺតែងតែត្រូវក្រឡេកទៅមើលអង្គហេតុជាមុនសិន ទើបយើងអាចយល់ពីការបែងចែកមត៌កនេះបានត្រឹមត្រូវ និងសមហេតុសមផល។

# អនុសាសន៍

ឆ្លងកាត់តាមការបកស្រាយខ្លឹមសារកន្លងមកនេះ យើងអាចកត់សម្គាល់បានថា ការបែងចែកមត៌កពិតជាមានភាពស្មុគស្មាញ ហើយមនុស្សគ្រប់រូបនឹងជួបប្រទះភាពស្មុគស្មាញនេះជាច្រើនលើកក្នុងឆាកជីវិតរបស់ខ្លួនផងដែរ។ ជួនកាល យើងអាចមានមតកជនដែលជាឪពុកម្តាយ កូន ជីដូនជីតា។ល។

ជាក់ស្តែង ប្រជាពលរដ្ឋខ្មែរមួយចំនួនយល់ដឹងពីមត៌ករួចហើយ ពីព្រោះទ្រព្យសម្បត្តិគឺជាអ្វីដែលគ្រប់គ្នាមានដើម្បីរស់រានមានជីវិតក្នុងសង្គមស៊ីវិល។ ជាពិសេសនោះ ក្រមរដ្ឋប្បវេណីកម្ពុជាបានយកអត្ថន័យស្ទើរតែទាំងអស់ពីក្រមរដ្ឋប្បវេណីជប៉ុន ដែលក្រមនោះគឺជាឧបករណ៍ច្បាប់ដ៏ស្មុគស្មាញមួយ។ នៅមានអ្នកច្បាប់ និងប្រជាពលរដ្ឋចំនួនតិចណាស់ ដែលពួកគាត់អាចយល់ទៅថាអ្វីជាភាគបម្រុង? អ្វីទៅជាអភ័ព្វបុគ្គល? អ្វីទៅជាកម្មសិទ្ធិអវិភាគ? ជាធម្មតា ប្រជាពលរដ្ឋខ្មែរ មិនបានស្វែងយល់ពីសិទ្ធិដែលកំណត់ក្នុងច្បាប់នោះទេ ទើបធ្វើអោយការបែងចែកមត៌កមានការផ្ទុះធ្លោយច្រើន។ អាស្រ័យហេតុនេះ នៅពេលដែលសន្តតិកម្មកើតឡើង ការស្វែងរកដំបូន្មានផ្នែកច្បាប់មានលក្ខណៈសំខាន់ ហើយអាចការពារទ្រព្យដែលមត៌កនោះ។ ជួនកាលកាតព្វកិច្ចដែលមានភ្ជាប់ទៅនឹងសន្តតិកម្មអាចធ្វើអោយសន្តតិជនពិបាកក្នុងការជម្រះបញ្ជីជាមួយម្ចាស់បំណុល ប៉ុន្តែសន្តតិជនអាចបោះបង់សន្តតិកម្មនោះបាន។ ហេតុនេះហើយ ទើបសន្តតិជនមួយចំនួនគួរយល់ដឹងពីបញ្ហាដែលអាចកើតមាន ក្នុងរឿងក្តីសន្តតិកម្ម។

ដូច្នេះហើយដើម្បីគេចវេសពីបញ្ហាទាំងអស់នេះ ការបែងចែកមត៌កគួរតែជាប្រធានបទមួយដែលគួរតែត្រូវបានផ្សព្វផ្សាយអោយទូលំទូលាយដើម្បីជាទុនសម្រាប់និស្សិតច្បាប់ និងប្រជាពលរដ្ឋមួយចំនួនអោយបានយល់ដឹង។

ជាអនុសាសន៍៖

- ⇨ ក្រសួងយុត្តិធម៌គួរផ្សព្វផ្សាយអំពីប្រធានបទការបែងចែកមត៌ក ដល់សិស្សនិស្សិត និងប្រជាពលរដ្ឋតាមរយៈបណ្តាញសង្គមដែលពេញនិយម
- ⇨ ចែកចាយឯកសារដូចជា កូនសៀវភៅជាដើម ពាក់ព័ន្ធនឹងប្រធានបទនេះដល់និស្សិតច្បាប់និងប្រជាពលរដ្ឋ ដើម្បីអោយពួកគាត់យល់ដឹងពីសារៈសំខាន់នៃទ្រព្យសម្បត្តិនិងកាតព្វកិច្ចទាំងនេះ
- ⇨ បង្កើតអោយមានសិក្ខាសាលាដោយមានវាគ្មិនពីប្រទេសជប៉ុនបន្ថែមសម្រាប់និស្សិតច្បាប់ និងរាប់បញ្ចូលទាំងប្រជាពលរដ្ឋដើម្បីអោយពួកគាត់បានចូលរួមសិក្សាអំពីការបែងចែកមត៌ក។

# ឯកសារយោង


## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- "ក្រមរដ្ឋប្បវេណីកម្ពុជា", លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
- "ក្រមរដ្ឋប្បវេណីជប៉ុន", Civil Code of Japan (Part IV and Part V (Tentative translation), Act No. 89 of April 27, 1896, Translation date: January 30, 2014, ដកស្រង់ពីគំណាវេបសាយ៖ http://www.japaneselawtranslation.go.jp/law/detail/?id=2252&vm=2&re=02&new=1
- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី ២០០៩, "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ ៖ គន្ថីទី៨ - ទី៩", ២០១០, ISBN: 9789995083359

## សៀវភៅ

- អ៊ីវ ប៉ូលី, "ការបែងចែកមត៌ក", ១២ មករា ២០១៨
- UMEMOTO Yumi, "ការអនុវត្តជាក់ស្តែងនៃការបែងចែកមត៌ក", ដកស្រង់ពីគំណាវេបសាយ៖ https://www.jica.go.jp/project/english/cambodia/025/materials/c8h0vm0000c54sbn-att/code_03_04.pdf

## គេហទំព័រ

- ប៊ុន វិទូ និង ឡេង ពុទ្ធិតារា, "យល់ដឹងផ្នែកច្បាប់៖ របបភាគបម្រុង" , ដកស្រង់ពីគំណាវេបសាយ៖ http://ciclg.com/en/article/235

# ឧបសម្ព័ន្ធ

# គំរូ ពាក្យស្នើសុំអោយបែងចែកមត៌ក

## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

**<u>គម្រូពាក្យសុំសម្រាប់ករណីសិក្សាទី១</u>**

## <u>ពាក្យស្នើសុំឲ្យបែងចែកមត៌ក</u>

**អ្នកដាក់ពាក្យសុំ** ៖ ឈ្មោះ A អាយុ ៥០ ឆ្នាំ មុខរបរពាណិជ្ជករ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ០២ ផ្លូវលេខ ១៧៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ** "អ្នកដាក់ពាក្យសុំ[1]" ៖ ខ្ញុំ P ជាមេធាវីនៃក្រុមហ៊ុនមេធាវី.................. ដែលមានអាសយដ្ឋានស្ថិតនៅ...............មហាវិថី............... សង្កាត់.............. ខណ្ឌ......... រាជធានីភ្នំពេញ ដោយមានលេខទូរស័ព្ទ ............។

ទីកន្លែងបញ្ជូន ៖ ក្រុមហ៊ុនមេធាវី.................[2]

**ភាគីម្ខាងទៀតនៃពាក្យសុំ** ៖ ឈ្មោះ B អាយុ ៥២ ឆ្នាំ មុខរបរពាណិជ្ជករ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ៣៥ ផ្លូវលេខ៦៦ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

### <u>សូមគោរពចូលមក</u>

### ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ[3]

**ក**-ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ

១.អ្នកដាក់ពាក្យសុំធ្វើលទ្ធកម្មនូវអចលនវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ១ ស្តីពីមតិកដែលបានភ្ជាប់ជាមួយនេះ។

---

[1] មានករណីមួយចំនួនដែលការពិភាក្សាលក្ខណៈសារធាតុរវាងសហសន្តតិជនបានធ្វើឡើងរួចរាល់ ប៉ុន្តែ ចំណុចនេះបង្ហាញតែអំពីឧទាហរណ៍ដែលមេធាវីបានដាក់ពាក្យសុំក្នុងនាមជាអ្នកតំណាងដោយអាណត្តិឲ្យសន្តតិជនតែម្នាក់គត់ក្នុងចំណោមសហសន្តតិជន។ ប្រសិនបើមេធាវីបានដាក់ពាក្យសុំក្នុងនាមតំណាងឲ្យសន្តតិជនច្រើននាក់ក្នុងចំណោមសហសន្តតិជន (រួមបញ្ចូលទាំងករណីដែលធ្វើការតំណាងឲ្យសន្តតិជនទាំងអស់ផងដែរ) នឹងធ្វើឲ្យមានការព្រួយបារម្ភអំពីភាពផ្ទុយគ្នានៃផលប្រយោជន៍ ហេតុនេះមេធាវីចាំបាច់ត្រូវតែពន្យល់ឲ្យបានច្បាស់លាស់អំពីចំនុចនេះទៅកាន់អតិថិជន និងត្រូវទទួលការយល់ព្រមពីអតិថិជនផងដែរ។ យ៉ាងណាមិញ គេគិតថា វិធីដែលសន្តតិជនណាម្នាក់ក្នុងចំណោមសហសន្តតិជនតំណាងឲ្យសហសន្តតិជនផ្សេងទៀត ហើយបានដាក់ពាក្យសុំ នឹងធ្វើឲ្យមានការព្រួយបារម្ភថាខ្វះការធានាចំពោះនីតិវិធីសម្រាប់សហសន្តតិជនផ្សេងទៀត ហើយពួកគេនឹងមិនពេញចិត្ត។

[2] មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការដាក់ពីទីកន្លែងដែលត្រូវបញ្ជូន មិនមែនជាកាតព្វកិច្ចនោះទេ។ ទោះបីជាមិនដាក់ពីកន្លែងដែលត្រូវបញ្ជូនក៏ដោយ ក៏ជាទូទៅគឺត្រូវធ្វើការបញ្ជូនទៅការិយាល័យមេធាវីនៃបណ្តឹង។ ប៉ុន្តែ ដើម្បីឲ្យមានភាពច្បាស់លាស់ពីទីកន្លែងដែលត្រូវបញ្ជូន វាជាការល្អដែលដាក់ពីទីកន្លែងដែលត្រូវបញ្ជូន។ ជាពិសេស ក្នុងករណីដែលមានមេធាវីច្រើនធ្វើជាអ្នកតំណាងរបស់ដើមចោទ នោះដើម្បីឲ្យមានភាពច្បាស់លាស់ក្នុងការបញ្ជូនទៅការិយាល័យមេធាវីណាមួយ នោះត្រូវដាក់ពីទីកន្លែងដែលត្រូវបញ្ជូន។

[3] តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការនៃទីកន្លែងចាប់ផ្តើមសន្តតិកម្ម (តារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។ ហើយទីកន្លែងចាប់ផ្តើមសន្តតិកម្ម គឺជាអាសយដ្ឋាននៅពេលមរណភាពរបស់មតកជន (ក្រមរដ្ឋប្បវេណីមាត្រា១១៩៦)។

២.ភាគីម្ខាងទៀត......ធ្វើលទ្ធកម្មនូវប្រាក់បញ្ញើដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ២ស្តីពីមតិក និងសាច់ប្រាក់ដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ៣ស្តីពីមតិក ដែលបានភ្ជាប់ជាមួយនេះ ។

**ខ-អង្គហេតុដែលជាមូលហេតុនៃការទាមទារ**

១.មតកជន...... បានទទួលមរណភាពនៅថ្ងៃទី......ខែ......ឆ្នាំ...... ហើយមតិកដែលដឹងច្បាស់នាពេលបច្ចុប្បន្ន មានដូចទៅនឹងការសរសេរនៅក្នុងបញ្ជីសារពើភ័ណ្ឌស្តីពីមតិកដែលបានភ្ជាប់ជាមួយនេះ (តទៅនេះហៅថា "មតិកនៃរឿងក្តីនេះ")។

២.នៅពេលទទួលមរណភាព មតកជន.............មានប្រពន្ធ..............ហើយរវាងមតកជននិងប្រពន្ធ.......នោះ មានកូន..........១នាក់។ មតកជនមិនមានកូនផ្សេងទៀតទេ។ មតកជន......មិនបានបន្សល់ទុកមតកសាសន៍ឡើយ[4]។

៣.សន្តតិជនរបស់មតកជនដែលជាអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត បានពិភាក្សាគ្នាអំពីការបែងចែកមតិកនៃរឿងក្តីនេះ។ ជាលទ្ធផលនៃការពិភាក្សា ភាគីម្ខាងទៀតមានផ្ទះដែលជាកម្មសិទ្ធិផ្ទាល់ខ្លួនរួចទៅហើយ ប៉ុន្តែ ដោយសារតែគាត់មានអាយុច្រើន និង មិនមានប្រាក់ចំណូល ដូច្នេះ គាត់ត្រូវការចាំបាច់នូវសាច់ប្រាក់និង ប្រាក់បញ្ញើក្នុងធនាគារ សម្រាប់ជីវភាពរបស់គាត់ក្នុងពេលខាងមុខ។ ចំណែកឯអ្នកដាក់ពាក្យសុំវិញ គឺជាបុគ្គលិកក្រុមហ៊ុនដែលមានប្រាក់ចំណូល ប៉ុន្តែ គាត់មិនទាន់មានផ្ទះដែលជាកម្មសិទ្ធិផ្ទាល់ខ្លួននៅឡើយទេ ដូច្នេះហើយ អ្នកដាក់ពាក្យសុំ ត្រូវធ្វើលទ្ធកម្មនូវអចលនវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ១ស្តីពីមតិកដែលបានភ្ជាប់ជាមួយនេះ ហើយភាគីម្ខាងទៀតត្រូវធ្វើលទ្ធកម្មនូវសាច់ប្រាក់ និងប្រាក់បញ្ញើក្នុងធនាគារដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ ២ និង ៣ ស្តីពីមតិកដែលបានភ្ជាប់ជាមួយនេះ។ បន្ថែមពីនេះទៀត តម្លៃទីផ្សារនៃអចលនវត្ថុ ដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ១ ស្តីពីមតិកដែលបានភ្ជាប់ជាមួយនេះ គឺប្រហែល......ដុល្លារ ហើយ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃនៃការបូកសរុបប្រាក់បញ្ញើនៅក្នុងធនាគារ និងសាច់ប្រាក់សុទ្ធដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ ២ និង ៣ ស្តីពីមតិកដែលបានភ្ជាប់ជាមួយនេះ។ ដូចនេះ នៅថ្ងៃទី......ខែ.......ឆ្នាំ២០១៧ ភាគីទាំង២ បានបង្កើត[5]នូវការព្រមព្រៀងដូចមាននៅក្នុងការសរសេរនៃចំណុចទី១ ខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ។

៤.អាស្រ័យហេតុនេះ អ្នកដាក់ពាក្យសុំសូមឲ្យតុលាការចេញដីកាសម្រេចតាមការសរសេរនៅក្នុងចំណុចទី១ ខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ ចំពោះពាក្យសុំនៃរឿងក្តីនេះ។

---

[4] បើសិនជាមានមតកសាសន៍ ករណីនេះនឹងក្លាយជាសន្តតិកម្មអនុវត្តតាមមតកសាសន៍ (សន្តតិកម្មតាមមតកសាសន៍)(ក្រមរដ្ឋប្បវេណី មាត្រា ១១៩៥ និង ចាប់ពីមាត្រា ១១៦៨)។

[5] ដើម្បីឲ្យតុលាការចេញដីកាសម្រេចទៅតាមខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ តើរវាងសហន្តតិជនបានបង្កើតនូវការព្រមព្រៀងពិតប្រាកដដែរឬទេ? (តើសហសន្តតិជនទាំងអស់បានយល់ព្រមតាមការបែងចែកដូចនៅក្នុងខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញដែរឬទេ?)គឺជាចំណុចសំខាន់។ ដូច្នេះហើយ ត្រង់ចំណុចនេះ គួរតែមានការពន្យល់អំពីមូលហេតុលម្អិត ថាតើហេតុអ្វីបានជាបែងចែកតាមវិធីបែបនេះ?

**គ.ភស្តុតាងជាឯកសារ**[6]

១.សំបុត្រមរណភាពរបស់មតកជន

២.សំបុត្រកំណើតរបស់អ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត

៣.ច្បាប់ចម្លងនៃសៀវភៅគ្រួសារ

៤.ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ

៥.លិខិតបញ្ជាក់ប្រាក់ដែលនៅសល់ក្នុងគណនីប្រាក់បញ្ញើ

សេចក្តីដូចមានកំណត់ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាត ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៨

**<u>ឯកសារភ្ជាប់</u>**

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

៣-លិខិតបញ្ជាក់អះអាងអំពីតម្លៃដី "ចំនួន ០២ ច្បាប់"

**អ្នកតំណាងដោយអាណត្តិ**

**P**

[6] ចំពោះឯកសារបញ្ជាក់ដំបូង ចាំបាច់ត្រូវតែដាក់ឯកសារដែលចាំបាច់ និងគ្រប់គ្រាន់ទៅតុលាការ ដើម្បីឲ្យតុលាការទទួលស្គាល់នូវខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ ប៉ុន្តែ ដំណើរការនៃការព្រមព្រៀងទាក់ទងនឹងវិធីបែងចែកមតិកជាដើម អំពីចំណុចដែលមិនមានឯកសារត្រឹមត្រូវ នឹងក្លាយជាការពន្យល់នៅក្នុងការសួរជំនួសនៅតុលាការ (ច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងមាត្រា ២៨ កថាខណ្ឌទី២) ។

## បញ្ជីសារពើភ័ណ្ឌស្តីពីមតិក[7]

១.អចលនវត្ថុ[8]

ទីតាំងស្ថិតនៅ ៖ ភូមិ...... សង្កាត់ ផ្សារកណ្តាល ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ

លេខវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ៖

លេខក្បាលដី ៖

កម្មសិទ្ធិករ ៖ ឈ្មោះ និង អាសយដ្ឋាន

អាគារដែលជាសមាសភាពនៃដីខាងលើ

២.ប្រាក់បញ្ញើក្នុងធនាគារ[9]

ធនាគារ ៖ ប្រទេសកម្ពុជា ធនាគារពាណិជ្ជទី១

សាខា ៖ សាខាតាមដងមហាវិថីព្រះមុន្នីវង្ស

លេខគណនីធនាគារ ៖

ឈ្មោះម្ចាស់គណនី ៖

៣.សាច់ប្រាក់ ៖ (អ្នកថែរក្សាគ្រប់គ្រង)[10]

ប្រាក់......រៀល

[7] បញ្ជីសារពើភ័ណ្ឌនៃមតិក ត្រូវសរសេរខ្លឹមសារដែលអាចឲ្យតុលាការយកមកប្រើប្រាស់ក្នុងដីកាសម្រេចបានតែម្តង។

[8] អចលនវត្ថុ ចាំបាច់ត្រូវធ្វើនូវបញ្ជីសារពើភ័ណ្ឌដែលមានទម្រង់ ឬ ខ្លឹមសារដែលអាចយកទៅធ្វើការចុះបញ្ជីបាន។

[9] ប្រាក់បញ្ញើក្នុងធនាគារ ចាំបាច់ត្រូវកំណត់ឲ្យបានច្បាស់លាស់អំពីខ្លឹមសារនៃប្រាក់បញ្ញើ ដើម្បីអាចតតាំងដោយភាពត្រឹមត្រូវជាមួយនឹងធនាគារ (ក្រមរដ្ឋប្បវេណី១២៧៥ កថាខណ្ឌទី១)។

[10] សាច់ប្រាក់ភាគច្រើនត្រូវកំណត់ដោយដាក់ឈ្មោះរបស់អ្នកថែរក្សាគ្រប់គ្រង ដោយសារតែវាមានភាពពិបាកក្នុងការកំណត់។

# គំរូដីកាសម្រេចបែងចែកមត៌ក

សាលាដំបូងរាជធានីភ្នំពេញ

## ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

<u>**គម្រូដីកាសម្រេចសម្រាប់ករណីសិក្សាទី១**</u>

**<u>ដីកាសម្រេចបែងចែកម៌ក</u>**

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងរដ្ឋប្បវេណីដែល មិនមែនជាបណ្ដឹងលេខ១៥៩ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០១៧ ដីកាសម្រេចលេខ ១២៣ "ង" ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨

-បានឃើញច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី ១៦-០៧-២០១៤

-បានឃើញមាត្រា **២៦**នៃច្បាប់ស្ដីពីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

-បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃ**ទី១៥ ខែមករា ឆ្នាំ២០១៨** និងបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃ**ទី០៧ ខែធ្នូ ឆ្នាំ២០១៧** ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

លោក J ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោកស្រី C ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

**អង្គហេតុ និងការអះអាងរបស់គាគី**

**ក.ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារឲ្យតុលាការចេញ**

១. អ្នកដាក់ពាក្យសុំ A ធ្វើលទ្ធកម្មចំណែកអវិភាគ ១ភាគ២នៃអចលនវត្ថុដូចក្នុងបញ្ជីសារពើភ័ណ្ឌ១ និង រថយន្តដូចក្នុងបញ្ជីសារពើភ័ណ្ឌ៣។

២. ភាគីម្ខាងទៀតនៃពាក្យសុំ B ធ្វើលទ្ធកម្មប្រាក់ក្នុងគណនីដូចក្នុងបញ្ជីសារពើភ័ណ្ឌ២។

ទី៣ បង្គាប់ឲ្យអ្នកដាក់ពាក្យសុំ A បង់ប្រាក់ចំនួន 35,000$ ដែលជាប្រាក់សម្រួលនៃលទ្ធកម្មមត៌កខាងលើឲ្យទៅភាគីម្ខាងទៀតនៃពាក្យសុំ B។

**ខ. អង្គហេតុ**

**ខ.១ ការសង្ខេបរឿងក្ដី**

កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៤

**ខ.២. ការអះអាងរបស់ភាគី**

**-ការអះអាងរបស់អ្នកដាក់ពាក្យសុំ A**

អ្នកដាក់ពាក្យសុំបាន

**-ការអះអាងរបស់ភាគីម្ខាងទៀតនៃពាក្យសុំ B**

ភាគីម្ខាងទៀតនៃពាក្យសុំបានអះអាងថា

**សំអាងហេតុ**

**ក. ស្តីពីចំណុចទាមទារទី១**

**ក.១. អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់**

-ករណីរឿងក្តីនេះ

-

**ក.២. ការវិនិច្ឆ័យអំពីចំណុចទាមទារ**

-ករណីនេះ

-

**ខ. ស្តីពីចំណុចទាមទារទី២**

**ខ.១. អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់**

-ករណីនេះ

-

**ខ.២.ការវិនិច្ឆ័យអំពីចំណុចទាមទារ**

-ករណីនេះ

-

**គ. ស្តីពីចំណុចទាមទារទី៣**

**គ.១. អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់**

២ (ពីរ) សប្តាហ៍មុន

**គ.២.ការវិនិច្ឆ័យអំពីចំណុចទាមទារ**

សាក្សី B បានអះអាងថា

**ឃ.សេចក្តីសន្និដ្ឋាន**

-

-

ជាសរុប តុលាការនឹងសម្រេចរឿងក្តីនេះ ដូចខាងក្រោម ៖

**សេចក្តីសម្រេចបញ្ចប់**

១.អ្នកដាក់ពាក្យសុំធ្វើលទ្ធកម្មនូវអចលនវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ១ស្តីពីមត៌ក ដែលបានភ្ជាប់ជាមួយនេះ។

២.ភាគីម្ខាងទៀត......ធ្វើលទ្ធកម្មនូវប្រាក់បញ្ញើដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ២ស្តីពីមត៌ក និងសាច់ប្រាក់ដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ៣ស្តីពីមត៌ក ដែលបានភ្ជាប់ជាមួយនេះ ។

ដីកាសម្រេចនេះប្រកាសជាសាធារណៈនៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៨ ចំពោះមុខភាគី និងអ្នកតំណាងដោយអាណត្តិរបស់ភាគី។ ទុកសិទ្ធិឲ្យភាគីប្តឹងជំទាស់ក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតដីកាសម្រេចនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៨

**ចៅក្រម**